# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ជុំ នៅ ភេទស្រី K08607(ម្ចាស់ប្រវត្តិរូប)

## មុខងារៈ យុទ្ធនារីព្រៃស

## សម្ភាសន៍ជាមួយ ជុំ នៅ អាយុ ៥៦ ឆ្នាំជាម្ចាស់ប្រវត្តិរូប

## រស់នៅភូមិឯការាម ឃុំជើងទឹក ស្រុកកំពង់លាវ ខេត្តព្រៃវែង

## នៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៥

## សម្ភាសន៍ដោយៈ ផាន់ សុផា និង វ៉ា ឆាយវ៉ាន់

## សរុបៈ ៦២ទំព័រ

សុផាៈ តាមការសម្ភាសន៍ជាមួយយើងនឹងមីង ជុំ នៅ ហៅ ជុំ ភី យើងខ្ញុំផ្ទាល់មានការសង្កេតចំណុចមួយចំនួន ទីមួយចំពោះការចូលបដិវត្តន៍របស់គាត់ មីងបានចូលបដិវត្តន៍តាំងពីឆ្នាំ ១៩៧០ ចុងឆ្នាំ១៩៧០ហ្នឹង ហើយគាត់ត្រូវបានគេឲ្យធ្វើជាប្រធាននារីភូមិរហូតដល់ស្រុក តែគាត់អត់បាននៅតំបន់ទេគឺគាត់ឡើងទៅដល់ភូមិភាគ ហើយចំណុចដែលយើងកត់សំគាល់ហ្នឹងគឺចំពោះសាលាស២០០ៗនេះគឺយើងមកដល់ប្រជាជនដែល គាត់ចូលបដិវត្តន៍ហើយនៅម្តុំអូររាំងឪ, កំពង់ចាម, ស្វាយយអន្ទរ, ស្រុកព្រៃវែងអីហ្នឹង គឺវានៅតំបន់២០ហ្នឹងភាគច្រើនអ្នកចូលបដិវត្តន៍ហ្នឹង គេស្គាល់សាលាស២០០ហ្នឹងៗ សាលាស២០០ហ្នឹងតាមសំដីរបស់មីងគឺជាសាលាដែលគេស្វរពល គេហៅ មីងគាត់ និយាយថាសាលាដែលគេស្វរពល ហើយយើងបានសួរទៀតថាស្វរពលហ្នឹងបានន័យថាម៉េច? គេបង្រៀនទ័ពឲ្យចេះក្បួនយុទ្ធសាស្ត្រ បំពាក់បំប៉នវគ្គនយោបាយអីហ្នឹង ហើយបានឲ្យឡើងទៅសមរភូមិៗ ការសម្ភាសន៍យើងជាមួយពូម្នាក់នៅភូមិជីក្លាងដែរ គាត់ឈ្មោះ រួន ចក់ ហ្នឹងក៏គាត់បានឆ្លងកាត់សាលាស២០០ ដែរតែសាលាស២០០ ហ្នឹងគឺមានទីតាំងនៅ ម្តុំគេហៅភូមិពានាឃុំពានាហ្នឹងវានៅជាប់ស្រុកអូររាំងឪ-ស្រុកព្រៃវែង-ស្រុក ស៊ីធរកណ្តាល ប្រជុំ៣ស្រុកៗ តាមសំដីរបស់មីងគាត់ថា ស២០០ហ្នឹងមិនមែនមាន តែម្តុំទេ គឺមានច្រើនកន្លែងអញ្ចឹង យើងភ្ជាប់សំដីរបស់គាត់មក ជាមួយសំដីពូមុនហ្នឹង យើងថា សាលាស២០០ហ្នឹងគឺជា

ពិសេសភូមិភាគបូព៌ា យុទ្ធជនទាំងអស់គឺត្រូវបានឆ្លង កាត់សាលាស២០០ហ្នឹងជាពិសេស អ្នកដែល នៅក្នុងតំបន់២០ហ្នឹងហើយគេចែកកន្លែង មនុស្សស្រី និងយុទ្ធជនផ្សេងគ្នា អញ្ចឹងទោះបីជាមីងហើយនឹងពូមុនហ្នឹងយើងសម្ភាសន៍ទៅនិយាយទីតាំង ខុសគ្នា តែចាត់ទុកថាទីតាំងហ្នឹងខុសគ្នាមែនតែវានៅក្នុងចង្កោម របស់សាលាស២០០ដែរ ។ ហើយមួយទៀតអំពីរឿងវ៉ាន់បោះគាត់នៅពេលដែលគាត់គេឲ្យទៅធ្វើការនៅភ្នំពេញ ពេលរៀនចប់សាលា២០០ហ្នឹងគេរើបែកភ្នំពេញហើយ គឺគាត់គេឲ្យឡើងទៅនៅភស្តុភារ សេនាធិការនៅឃ្លាំងគ្រាប់នៅទួលគោក ហើយពេលក្រោយ មកមីងបានរៀបការជាមួយ ប្តីមីងហ្នឹងនៅចុងឆ្នាំ ៧៦ តែប្តីមីងហ្នឹងគឺជាអ្នកទ័ពខាងភូមិភាគឧត្តរទេ ហើយយើងសន្និដ្ឋានថាកន្លែងហ្នឹងគេចំរុះគ្នា គឺអត់ថាផ្លូវគាត់ឲ្យនៅខាងបូព៌ា រឺក៏ខាងនិរតី ខាងឧត្តរខាងបស្ចិមទេ ដូចថាគាត់ទ័ពមួយចំនួនពីបូព៌ា ទៅចូលសេនាធិការ គាត់ទ័ពពីឧត្តរមួយចំនួនទៅចូលសេនាធិការ អញ្ចឹងពេលហ្នឹងហើយ ដែលគាត់មានឱកាស ជួបប្តីគាត់រៀបការជាមួយគាត់ហើយ ដល់ពេលក្រោយមកប្តីគាត់ ហ្នឹងត្រូវបានគេចាប់ តែគាត់និយាយថាជាប់ទាក់ទិនជាមួយការចាប់ ធុច, ចាប់ អឿន ដែលជាប្រធានកងពល៣១០ នៅភូមិភាគឧត្តរហ្នឹង ពេលប្តីគាត់មុនគេចាប់ហ្នឹង គាត់ដឹងខ្លួនថាគាត់ហ្នឹងត្រូវបានគេ ចាប់ហើយ ៗមីងក៏ត្រូវបានគេដកឲ្យទៅធ្វើការលុតដំនៅព្រៃសដែរ កន្លែងហ្នឹងការចាប់ របស់មីងហ្នឹងបើតាមខ្ញុំដឹងប្រហែលជាមិនសូវជាទាក់ទងនឹងរឿងរ៉ាវរបស់គាត់ នៅខាងបូព៌ាទេ គឺទាក់ទងច្រើនជាមួយនឹងប្តីមីង ឃើញហើយតាមសំដីរបស់មីងហ្នឹងថាគាត់ មានពាក់ព័ន្ធ ដែរចំពោះរឿងបងថ្លៃរបស់គាត់មួយដែលជាគណៈតំបន់២០ នៅភូមិភាគបូព៌ាហ្នឹង ធ្លាប់ជាយុទ្ធជន ជាកម្មាភិបាលនៅភូមិភាគខាងជើង តែនេះជាការពាក់ព័ន្ធដល់ប្រវត្តិរូបរបស់មីងទេ ហើយទីបីគឺគាត់បានស្គាល់ ឌុច ដែលជាប្រធានគុកទួលស្លែងហ្នឹង គាត់ស្គាល់ឌុច ច្បាស់ណាស់ព្រោះគាត់ធ្លាប់ជួបធ្លាប់ស្គាល់ឌុច ហ្នឹងជាញឹកញាប់នៅក្នុងមន្ទីរស២១ នៅព្រៃស នៅស្ទឹងជ្រៅ ។ អញ្ចឹងចំពោះទស្សនៈខ្ញុំ ៗចាប់អារម្មណ៍បីហ្នឹង ។

វ៉ាន់: ចំពោះខ្ញុំៗ ចាប់អារម្មណ៍កាលពីដើមសម្ភាសន៍គាត់និយាយថា គាត់អត់សូវចង់និយាយរឿងហ្នឹង ខ្ញុំតាមរយៈសម្ភាសន៍ពីមុនៗមកខ្ញុំយល់ឃើញថា កាលដែល ប្រជាជនចាប់ផ្តើមលែងចង់និយាយរឿងខ្មែរក្រហម អាចមានហេតុផលពីរយ៉ាង ទីមួយដោយសារតែ

រយៈពេលយូពេកហើយគាត់គិតថារឿងខ្មែរក្រហមក្លាយទៅជារឿង គ្មានប្រយោជន៍ ហើយដោយសារតែគ្មានការនឹកនានិងការអប់រំពីខាងរដ្ឋាភិបាលផង អញ្ចឹងគាត់រឿងខ្មែរក្រហមកាន់តែខ្សោយ ធ្លាក់ចុះមែនទែន អត់សូវមានការនិយាយច្រើន ហើយជាពិសេសនិយាយប្រាប់ក្មេងៗវីក៏ចាស់ៗគ្នាគាត់ក៏លែងមានដែរ ហើយហេតុផលទី ពីរអាចដោយសារតែគាត់ប៉ះពាល់ខ្លាំងកាលពីជំនាន់ខ្មែរក្រហម ហើយពេលណាគាត់រំលឹក ទៅអាចប៉ះពាល់ដល់អារម្មណ៍គាត់ ហើយអាចប៉ះពាល់ដល់ជីវភាពគាត់ផ្ទាល់ខ្លួន ដូច្នេះការនិយាយរឿងហ្នឹងកាន់តែធ្លាក់ចុះមែនទែនទៀត ។

សុជាៈ អញ្ចឹងខ្ញុំថែមលើសំដី ឆាយ វ៉ាន់ មិញនិយាយថាដោយសារគ្មានការយកចិត្តទុកដាក់ចងក្រងឯកសារអីហ្នឹងធ្វើឲ្យប្រជាជនហ្នឹងគាត់អត់សូវចង់និយាយ ដោយសារនិយាយទៅវាអត់បានការ តែនៅក្នុងបទសម្ភាស៍ហ្នឹងយើងបានសួរគាត់បញ្ជាក់ថា ចុះមីងដូចថាអត់ចង់និយាយ អញ្ចឹងដល់ពួកខ្ញុំមកនិយាយអញ្ចឹងវាម៉េចដែរ មីងគាត់ថាគាត់ចាប់អារម្មណ៍វិញហើយគាត់ ចង់និយាយប្រាប់យើងព្រោះថា និយាយទៅវាមានអ្នកសរសេរ ហើយបើគាត់ចេះតែ និយាយចោលៗអត់មានសរសេរចងក្រងអីអញ្ចឹងវាអាចជាភ្លេច អាចបាត់បង់អញ្ចឹង គាត់សប្បាយចិត្តចំពោះអ៊ីដែលគាត់និយាយប្រាប់យើង ហើយយើងបានយកទៅសរសេរ ចុងក្រោយមកគាត់បានសំណូមពរឲ្យយើងហ្នឹងសរសេរ អត្ថបទមួយហើយទុកយកឲ្យគាត់មើលផង អានេះជារឿងមួយល្អដែរចំពោះទស្សនៈគាត់ ផ្ទាល់ដែលគាត់បញ្ចេញមកប្រាប់យើង ហើយបុគ្គលិកលក្ខណៈរបស់មីងយើងមើលទៅដូចថា គាត់ស្ថានភាពគាត់រស់នៅរាល់ថ្ងៃ គាត់ជាអ្នកមួយថាទទួលបានព័ត៌មានច្រើន មានការអប់រំខ្ពស់គួសម អញ្ចឹងការនិយាយស្តីរបស់គាត់គឺបានល្អជាងអ្នកដែលយើង សម្ភាសន៍មុនៗ ជាពិសេសមនុស្សស្រី អគុណ ។

សុជាៈ មីងអត់ទោសមីងខ្ញុំ មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលសរសេរសៀវភៅពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយខ្ញុំមកសុំជួបមីងហ្នឹងដើម្បីចង់ដឹងពីប្រវត្តិរឿងរ៉ាវរបស់មីងដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហមហ្នឹង ដើម្បីយកទៅទុកឲ្យក្មេងៗជំនាន់ក្រោយ ហ្នឹងបានដឹងអំពីរឿងរ៉ាវប្រវត្តិកាលជំនាន់ហ្នឹង ។ មីងឈ្មោះអីដែរមីង?

នៅៈ ចា៎! មីងឈ្មោះ ដុំ នៅ ។

សុជាៈ ជុំ នៅ ហ្នឹងដដែលអ្ហែស?

នៅៈ ចាំ! ហើយក្នុងឈ្មោះដែលយើងធ្វើការនៅខ្មែរក្រហមឈ្មោះ ភី, ជុំ ភី ណាំ ។

សុជាៈ ចុះមីងអាយុប៉ុន្មានហើយ រាល់ថ្ងៃ?

នៅៈ អាហ្នឹងយើងគិតថាយើងដាក់ឆ្នាំ ១៩៤៩ ទៅឃើញ គុណទៅសងទៅណាំ ។

សុជាៈ ៤៩ ។

នៅៈ ១៩៤៩ ឆ្នាំកំណើតអ្ហាស់ ។

សុជាៈ ៥៦ ឆ្នាំ ។ ហើយមីងនៅក្នុងភូមិហ្នឹងរាល់ថ្ងៃឈ្មោះភូមិអីដែរ?

នៅៈ ភូមិឯការាម ឃុំជើងទឹក ។

សុជាៈ ឯការាមណាំ........ឃុំជើងទឹកណាំ......ស្រុកអីគេដែរហ្នឹង?

នៅៈ កំពង់លាវ ។

សុជាៈ កំពង់លាវ ខេត្តព្រៃវែង ហើយមីងស្រុកកំណើតកើតជានៅណាដែរ?

នៅៈ ស្រុកកំណើតមានពីរដែលខ្ញុំមករស់នៅព្រៃវែងហ្នឹងស្រុកកំណើតឪពុកអ្ហាស់ ហើយស្រុក កំណើតម្តាយនៅភូមិព្រៃឫស្សីហ្នឹង....

សុជាៈ ចុះមីងកើតជា?

នៅៈ កើតជានៅព្រៃវែង ។

សុជាៈ នៅទីរួមខេត្តហ្នឹង?

នៅៈ ចាំ!

សុជាៈ នៅហ្នឹងអ្ហែស នៅភូមិ...?

នៅៈ អត់ទេនៅព្រៃវែង ។

សុជាៈ នៅភូមិអី ឃុំអីដែរ?

នៅៈ នៅភូមិវាល ពីដើមគេហៅភូមិវាល តែឥឡូវគេហៅភូមិលេខ៨អ្ហាស់ ។ ភូមិវាល ឃុំកំពង់ លាវ ស្រុកកំពង់លាវ ពីដើមអត់មាន ពីដើមដែនទីពីដើមវាជាស្រុកព្រៃវែងអ្ហាស់ តែយើងប្រើអញ្ចឹងទៅ ។

សុជាៈ ឪពុកមីងឈ្មោះអីដែរមីង?

នៅៈ ឪពុកខ្ញុំឈ្មោះ មាឃ ជុំ ។

សុជាៈ មាយ ជុំៗ ម្ដាយ?

នៅៈ ឈ្មោះ វ៉ែក សុខៗ

សុជាៈ គាត់នៅរស់ដែរទេ?

នៅៈ ស្លាប់ គាត់ចាស់ៗហើយ ស្លាប់យូរហើយ ។

សុជាៈ មិនមែនស្លាប់ជំនាន់ប៉ុល ពត ទេ?

នៅៈ តែឪពុកខ្ញុំស្លាប់ដោយជំងឺទេណា៎ នៅស្រែហ្នឹង ខ្ញុំបានទៅគាស់សពគាត់យកមកធ្វើបុណ្យ ហើយនៅឆ្នាំ៨០ ។ ហើយម្ដាយខ្ញុំគេជម្លៀសទៅនៅពោធិ៍សាត់ គេហៅសហករណ៍ព្រះម្លូ ។

សុជាៈ ហើយស្លាប់នៅហ្នឹងទៅ?

នៅៈ ប្រហែលជាស្លាប់ហើយតាមខ្ញុំចាំបានម្ដាយខ្ញុំហ្នឹងគាត់អាយុតំណាលសម្ដេច ។

សុជាៈ តែពេលដែលបែក ៧៩ អត់ឃើញត្រឡប់មកផ្ទះវិញទេ ។ មីងមានបងប្អូនប៉ុន្មាននាក់ដែរ?

នៅៈ បងប្អូនខ្ញុំ៤នាក់ ៤នាក់ទាំងខ្ញុំ ។

សុជាៈ ហើយនៅរស់ប៉ុន្មានដែរ?

នៅៈ នៅរស់តែខ្ញុំមួយ ។

សុជាៈ អ! ចុះ៣នាក់ទៀតគាត់ទៅតាមម្ដាយ....?

នៅៈ ចា៎! គាត់ស្លាប់ៗ ម្នាក់ទៀតយើងដឹងថាស្លាប់នៅជំនាន់ឆ្នាំ ៧៧, ៧៨ហ្នឹងដែលយើងមកដល់ភូមិហ្នឹងយើងសួរទៅថាជីករទេះសេះទៅបាត់តែម្ដងទៅណា៎ ។ ហើយពីរនាក់ទៀតទៅតាមម៉ែខ្ញុំ ហើយកូនបងខ្ញុំបងទីពីរហ្នឹងទៅតាមម៉ែខ្ញុំទាំងអស់ទាំងបងថ្លៃខ្ញុំអីហ្នឹង ដល់អញ្ចឹងទៅបាត់ទាំងអស់ ។

សុជាៈ បាត់នៅហ្នឹងទៅ ។

នៅៈ បាត់ទាំងអស់ ។

សុជាៈ ដល់ពេលត្រឡប់មកផ្ទះវិញ ៧៩ហ្នឹង...?

នៅៈ ត្រឡប់មកផ្ទះនៅសល់តែក្មួយខ្ញុំមួយដែលនៅព្រៃឫស្សីហ្នឹង ...ចា៎.. តែខ្ញុំសួរទៅវាថាឆ្នាំ៧៩ហ្នឹងបងប្អូនខ្ញុំ និងម៉ែខ្ញុំនៅទាំងអស់ ។

សុជាៈ បាត់មិនដឹងទៅណា?

នៅៈ ចាំ! ព្រោះឆ្នាំ ៧៩ហ្នឹងយើងមិនវៀតណាមចូលវាវក់វី ដល់វក់វីអញ្ចឹងទៅវានៅកង ចល័តវាក៏ប្រាស់មកវាមិនបានទៅកន្លែងដើមវិញទេណា៎ តែគ្រាន់តែដឹងដំណឹងថានៅឆ្នាំ៧៩ គឺគ្រួសារយើងអត់ទាន់ស្លាប់ទេនៅទាំងអស់ តែក្រោយពីហ្នឹងមកបាត់ដំណឹងសូន្យទល់សព្វថ្ងៃ ។

សុជាៈ ចុះមីងមកនៅទីនេះតាំងពីឆ្នាំណាដែរ?

នៅៈ មីងមកនៅទីនេះឆ្នាំ៨៩....៨៨....៨៩ ។

សុជាៈ ៨៨, ៨៩យូរដែរ ចុះមុនហ្នឹង?

នៅៈ មុនហ្នឹងមីងនៅព្រៃវែង ។

សុជាៈ នៅព្រៃវែងហ្នឹង នៅក្នុងខេត្តហ្នឹង ។

នៅៈ ចាំ! នៅជាមួយបងជីដូនមួយ ដល់យើងមានគ្រួសារមួយទៀតទៅមានកូន ។ ហើយគ្រួសារយើងមុនដែលឈ្មោះមឿន នេះមានកូនមួយដែរ តែស្លាប់កាលជំនាន់ដែលនៅព្រៃស ព្រោះកាលមីងនៅជាប់គុកព្រៃសមីងទំងន់៥ខែ ហើយពេលមីងឆ្លងទន្លេក៏ឆ្លងទន្លេនៅហ្នឹង ហើយដល់កូនមីងបាន....មិនចាំទេ....កូនមីងបានប៉ុន្មានខែទេវាកើតកញ្ជ្រឹល វាកើតកញ្ជ្រិលហើយគេក៏ៗយកវាទៅដេកពេទ្យនៅភ្នំពេញ កាលហ្នឹងតែដល់ពេលគេលួងមិនស្ងៀមគេក៏ យកមីងទៅ ។ ពេលដែលវាកើតហ្នឹងវាអត់បានបៅដោះយើង ដល់ពេលយើងទៅដល់ឡូវាបៅវាលាប់ ។

សុជាៈ បាក់ទឹកដោះ?

នៅៈ គេហៅលាប់កញ្ជ្រឹល ។

សុជាៈ កូនស្រី កូនប្រុស?

នៅៈ ប្រុស ។

សុជាៈ ប្រុស ចុះប្ដីមីងគាត់ស្លាប់ដោយសារមូលហេតុអី?

នៅៈ អឺ! ប្ដីមីងឈ្មោះមឿន ហ្នឹង....យើងមិនដឹងថាគាត់ស្លាប់ទេ ប៉ុន្តែគាត់ទៅមុនយើង ។

សុជាៈ ទៅណា?

នៅៈ ទៅព្រៃសដែរ មានឃើញឈ្មោះទេ?

សុជាៈ អត់ទេ គាត់ស្រុកកំណើតនៅណា?

នៅៈ នៅស្ទឹៗ ស្រុកចំការលើ កំពង់ចាម ។

សុជាៈ ស្ទឹ? ខ្ញុំទៅធ្វើហ្នឹងហើយក្រែងលោជួប...។

នៅៈ ក្មួយអាចរកមើលលីស(list) ឈ្មោះនៅហ្នឹង មានទេ?

សុជាៈ បាៗ ចាំកត់ឈ្មោះ...?

នៅៈ ក្រែងលោនៅរស់ តែខ្ញុំជឿថាមិនរស់ទេ ។

សុជាៈ ចាំហើយចាំខ្ញុំកត់ឈ្មោះគាត់ទៅតាម...។

នៅៈ តាមឯកសារ....។

សុជាៈ តាមឯកសារណា៎ ព្រោះស្រួលដែរទេឯកសាររបស់ពួកខ្ញុំនេះមិនចាំបាច់បើកមើលទេមានដាក់នៅក្នុងកុំព្យូទ័រអញ្ចឹង ចុចតែឈ្មោះចឹងទៅ អាចចេញមកឲ្យហើយ ។ អញ្ចឹងមីងកាលនៅពីតូចមីងរៀនបានត្រឹមថ្នាក់ណាដែរ?

នៅៈ មីងរៀនថ្នាក់ទី៧ រៀននៅព្រៃវែងហ្នឹង ។

សុជាៈ រៀននៅខេត្តតែម្តង?

នៅៈ ចា៎! នៅខេត្តហ្នឹង នៅសាលាក្រាំងក្អែកហ្នឹង ។

សុជាៈ ក្រាំងក្អែក?

នៅៈ ក្រាំងក្អែក ។

សុជាៈ កាឯក?

នៅៈ ក្រាំងក្អែក ។

សុជាៈ ចុះក្រោយមកឈប់រៀន មិនរៀនបន្តទៀត?

នៅៈ អឺ....មីងគ្រួសារមីងពិបាកដែរពីសង្គម ឪពុកមីងជាអ្នករត់រ៉ឺម៉ក ពីដើមយើងអត់មាន ស៊ីក្លូទេ មានតែរ៉ឺម៉ក ហើយធ្វើប្រាំងផង ធ្វើប្រាំងនៅខាងលិចព្រៃវែង ដល់អញ្ចឹងទៅយើងជាកូនដែលធំពេញវ័យហើយត្រូវតែចាប់បន្ទុចិត្តយើងឲ្យឈប់....។

សុជាៈ ជួយធ្វើការងារផ្ទះ?

នៅៈ ចា៎! ជួយធ្វើការងារឪពុកម្តាយហ្នឹងធ្វើស្រែធ្វើអីអញ្ចឹងទៅ ហ្នឹងមីងតាមពិតមីងឈប់តាំងពីឆ្នាំ៦៨ ។

សុជាៈ ឈប់រៀនហ្នឹង?

នៅៈ ចាំ! ឈប់រៀននៅឆ្នាំ៦៨ ហើយដល់មកឆ្នាំ៧០ហ្នឹងទទួលយើងព្រឹត្តការណ៍ មានខ្មែរក្រហមមានអីវ៉ែក្នាអីអញ្ចឹងយើងក៏ចេញ អញ្ចឹងយើងចេញពីព្រៃវែងហ្នឹងតាំងពីឆ្នាំ៧០ ហើយដល់ពេលទៅហ្នឹង អាហ្នឹងយើងនៅក្នុងសង្គមយើងត្រូវបត់តាមគេ បើយើងមិនបត់តាមគេវាអត់រស់បានទេណាំ អញ្ចឹងយើងក៏ចូលធ្វើការធ្វើអីធម្មតាដំបូងមីងនៅឃុំហ្នឹងអ្នាស់ ហើយដល់ក្រោយមកមីងក៏ចូលធ្វើការទៅមីងក៏ អាហ្នឹងវាការពិតទៅយើងស្ម័គ្រចិត្តដែរទេណាំ ។

សុជាៈ មុនដំបូង.....ចូលតាំងពីឆ្នាំណាដែរ?

នៅៈ មីងចូលធ្វើការតាំងពីឆ្នាំ៧០ មកម៉េះនៅជាមួយខ្មែរក្រហមហ្នឹង ប៉ុន្តែដំបូងយើងនៅក្នុងភូមិទេជានារីបំរើភូមិ ដូចថាយើងដឹកជញ្ជូនឲ្យកងទ័ពអីអញ្ចឹង ហើយដល់ឆ្នាំ៧៣ក៏មីងឡើងមកឃុំ គេរើសមកនារីឃុំទៀត ដល់ពាក់កណ្តាលឆ្នាំ៧៣ហ្នឹងមីងឡើងទៅកងទ័ពនារីស្រុកព្រៃវែង ។ ដល់មកពាក់កណ្តាល៧៤ បានឡើងទៅកងទ័ពនារីភូមិភាគបូព៌ា ដល់បែក៧៥ ៗ គេបញ្ជូនមីងទៅភ្នំពេញ ណឹងយើងនិយាយខ្លីៗ ព្រោះមីងមិនចាំថ្ងៃខែទេ តែមីងអាចចាំបានឆ្នាំ ។

សុជាៈ អញ្ចឹងខ្ញុំសួរពីកំណាត់...?

នៅៈ បើសួរវិញស្រួលឆ្លើយ ។

សុជាៈ ត្រឹមឆ្នាំ៧០មកណាំ អញ្ចឹងពេលដែលរដ្ឋប្រហាហ្នឹង ថ្ងៃ១៨មិនាហ្នឹង មីង គ្រួសារមីងចុះទៅស្រុកកំណើតខាងម្តាយហ្នឹង?

នៅៈ យើងអត់ទាន់ទៅភ្លាមទេទាល់តែព្រៃវែងហ្នឹងវ៉ៃលើកទីមួយ ។

សុជាៈ វ៉ៃឆ្នាំណាលើកទីមួយ?

នៅៈ ឆ្នាំ៧០ហ្នឹង ។

សុជាៈ ៧០ហ្នឹងថ្ងៃប៉ុន្មាន ខែប៉ុន្មាន?

នៅៈ មិនចាំទេក្មួយអើយ ក្រោយព្រឹត្តិការណ៍១៨មិនា យូរដែរណាំ ប្រហែលជាចុងឆ្នាំ ។

សុជាៈ ចុងឆ្នាំ៧១....៧០?

នោះ៖ ៧០ មិនចូលដល់៧១ទេ នៅឆ្នាំ៧០ហ្នឹងតែមីងមិនចាំខែទេ គ្រាន់តែចាំថាពេលដែលមីងចេញពីព្រៃវែងទៅគឺនៅ នៅពេលដែលយើង គេវៃលើកទីមួយ ព្រោះព្រៃវែងវៃលើកទីមួយទីពីរ វៃច្រើនដំណាក់កាល ។

សុជា៖ ចុះពេលដែលរដ្ឋប្រហារហ្នឹងហើយនៅក្នុងទីរួមខេត្តព្រៃវែងហ្នឹង?

នោះ៖ ចា៎! មីងនៅព្រោះមីងមានប្អូនប្រុសមួយឈ្មោះជុំ មក ។ ប្អូនប្រុសហ្នឹងវាទៅធ្វើបាតុកម្មជាមួយគេជាមួយឯងព្រោះកាលហ្នឹង យើងមិនផ្ទុះបាតុកម្មទូទាំងប្រទេសមួយណា៎វាទៅ ។

សុជា៖ ទៅដល់ណា?

នោះ៖ ទៅដល់វាលស្បូវ គេក៏បាញ់ហើយវាក៏ប្រាស់មកវិញ ហើយដល់ហើយទៅវាដូចថាបាក់ស្បាត១ វាមិនចង់នៅវាក៏អន្ទូកអន្ទេញគ្រួសារបងប្អូនខ្ញុំហ្នឹង ទទួលគេវៃ លើកទីមួយក៏ចេញទៅនៅអីស្រុកកំណើតខាងម៉ែខ្ញុំនៅព្រៃវែងហ្នឹងទៅ ។

សុជា៖ អាហ្នឹងជាមូលហេតុដែលគ្រួសារមីងចេញទៅនៅភូមិកំណើតវិញ? ពេលហ្នឹងគ្រាន់តែបែកឆ្នាំ៧០ហ្នឹងរដ្ឋប្រហាហ្នឹងហើយ នៅទីនេះលន់ នល់ គ្រប់គ្រង ឬក៏សីហនុ គ្រប់គ្រងខ្មែរក្រហមនៅគ្រប់គ្រង?

នោះ៖ លន់ នល់ ។

សុជា៖ លន់ នល់?

នោះ៖ ចា៎!

សុជា៖ អញ្ចឹងចៅហ្វាយខេត្តកាលជំនាន់ សីហនុ ចាស់ហ្នឹងដូរហើយអញ្ចឹង?

នោះ៖ អឺ! មីងមិនដឹងទេព្រោះកាលហ្នឹង យើងនិយាយថាកិច្ចការងាររាជការយើងអត់សូវដឹងអត់ដឹងថាអ្នកណាឈ្មោះអី១ ទេយើងអត់សូវចាប់អារម្មណ៍សួរនាំព្រោះយើងអត់សូវមានទំនាក់ទំនងជាមួយរាជការ ។

សុជា៖ បាទ! បាទ! អញ្ចឹងដល់ពេលទៅនៅហ្នឹងទៅនៅទាំងអស់គ្នាតែម្តង?

នោះ៖ ទៅទាំងអស់គ្រួសារខ្ញុំ តែបងខ្ញុំទីពីរគាត់មានប្រពន្ធនៅស្រុកហ្នឹង ។

សុជា៖ ហ្នឹងគេហៅឃុំអីដែរនៅព្រែកឫស្សីហ្នឹង?

នោះ៖ ឃុំជីក្វាង ស្រុកព្រៃវែង ។

សុជា៖ ទៅដល់ហ្នឹងដំបូងមីងធ្វើអីដែរ?

នៅៈ ទៅដល់ហ្នឹងដំបូងគេបោះឆ្នោតឲ្យធ្វើប្រធាននារីភូមិ ។

សុជាៈ នៅឆ្នាំណា?

នៅៈ ឆ្នាំ៧០ហ្នឹង ដឹកនាំកំលាំងដឹកជញ្ជូនអីអញ្ចឹង ។

សុជាៈ ពីណាគេបោះឆ្នោតឲ្យ?

នៅៈ កាលហ្នឹងពួកខ្មែរក្រហមចូលមករៀបចំក្នុយ ។

សុជាៈ កាលគេបោះឆ្នោតឲ្យហ្នឹងគេបោះពីប្រជាជនដែររឺក៏?

នៅៈ បោះពីប្រជាជន ដូចថាគេប្រជុំប្រជាជនអញ្ចឹងគេរើសសមត្ថភាពអញ្ចឹងទៅ ហើយណាមួយយើងមិន គេមិនចាត់ទុកថាយើងជាប្រជាជនថ្មីទេកាលហ្នឹង ព្រោះស្រុកកំណើតយើង គេស្គាល់យើងគ្រប់គ្នាតាំងពីអើយមក ។ តាមពិតមីងមិនចង់និយាយពីប្រវត្តិទេ ព្រោះមីងមិនមែនភ្លេចទេ តែមីងមិនចង់រំលឹក វាដូចថាវា យើងគិតច្រើនទៅវាលំបាក ទើបតែឥឡូវទេមីងកាត់ចិត្តដូចថាបាន មីងនិយាយទៅចង់តែទឹកភ្នែកទេ ។

សុជាៈ ចុះដល់ពេលធ្វើកិច្ចការនារីភូមិហ្នឹងគេឲ្យធ្វើអីដែរទៅ?

នៅៈ កាលហ្នឹងយើងដឹកជញ្ជូន យើងនាំកំលាំងឧទាហរណ៍ថាគេត្រៀម ដូចថាវ៉ៃសមរភូមិអញ្ចឹងគេឲ្យយើងដឹកជញ្ជូនយុទ្ធជន កង់ យើងឌុបកង់ តែយើងស្រីអញ្ចឹងយើងមិនឌុបគេទេ គេឌុបយើងដល់ពេលទៅដល់កន្លែងហ្នឹងយើងជិះកង់មកវិញមក អញ្ចឹងយើងគ្រាន់តែយកកង់ទៅវិញទៅមកទេ យើងដឹកពីព្រៃឬស្សីមកដល់ស្វាយអន្ទរ វាមានដំណាក់ៗវា ឧទាហរណ៍ថាយុទ្ធជនណាដែលត្រូវទៅបំពេញការងារនៅកន្លែងណា គេមានកង់ត្រៀមសំរាប់ ជួយកង់ ។

សុជាៈ អាណឹងជូនទាំងយុទ្ធជនទាំងស្បៀងទាំងអីទៅទាំងអស់?

នៅៈ ចា៎! គេមានដំណាក់ៗវា តែគេមិនប្រើយើងរាល់ថ្ងៃទេ ឧទាហរណ៍ថាម៉ោអាទិត្យដល់វេនយើងម្តងអីចឹងអ្នកស្រ៉ុ ភូមិនេះ៥នាក់ ភូមិនោះ៥នាក់អីអញ្ចឹងទៅ សំរាប់ចាំដឹកជញ្ជូនកាលនោះគ្មានឡានគ្មានម៉ូតូទេមានតែកង់អ្នកស្រ៉ុ ។

សុជាៈ មីងធ្វើការជាប្រធានសំរាប់នារីភូមិហ្នឹងដល់ឆ្នាំណាដែរ?

នៅៈ ៧២ ។ ៧២ មីងឡើងមកឃុំ ។

សុជាៈ មកធ្វើអីដែរ?

នៅៈ មកឃុំហ្នឹងយើងជាប្រធាននារីឃុំ ប្រធានយុវជនឃុំដឹកនាំកំលាំងដឹកជញ្ជូនដែរ ប៉ុន្តែយើងក្តាប់ឃុំ ។ ហ្នឹងចង់ថតមីងស្លៀកខោអាវហ្នឹង វាអត់សមទេ ។

សុជាៈ មានអីមីង ។

នៅៈ អត់ទេខ្ញុំមិនចង់ឲ្យថតស្លៀកពាក់ខោអាវហ្នឹងវាអត់សម ។

សុជាៈ អញ្ចឹង ។

នៅៈ កុំអាលថត ។

សុជាៈ បាទ....បាទ..អញ្ចឹងមីងដល់ពេលយើងឡើងទៅដល់ឃុំអញ្ចឹងការងារដូចតែភូមិអញ្ចឹងដែរ?

នៅៈ ការងារធ្ងន់ជាងភូមិ ។

សុជាៈ ធ្ងន់យ៉ាងម៉េចទៅ?

នៅៈ ឃុំកាលហ្នឹងយើងគ្រប់គ្រងយុវជននារីនៅក្នុងឃុំទាំងមូល កាលយើងនៅភូមិយើងគ្រប់គ្រងតែម៉ាភូមិយើងទេ ដល់ពេលឡើងដល់ឃុំយើងគ្រប់គ្រងកំលាំងយុវជននារីពេញម៉ាឃុំដីក្លាងតែម្តង ។

សុជាៈ អ្ហ៎ គេឲ្យដឹកស្បៀងដឹកអីអញ្ចឹងដដែលក៏ មានការងារអីផ្សេងទៀត?

នៅៈ មានច្រើនការងារពិសេសការងារអប់រំ សីលធម៌ ។

សុជាៈ សីលធម៌ ចុះដូចការងារដើរប្រជាជនអីចលនាអី អាហ្នឹងយើងធ្វើដែរទេ?

នៅៈ ចា៎! យើងធ្វើ ។

សុជាៈ យើងធ្វើដែរ?

នៅៈ ចា៎!

សុជាៈ អាហ្នឹងគេអប់រំដូចថាទទួលការបំផុសហ្នឹងពីណាមក? ដូចថាពីថ្នាក់លើគេឲ្យយើងដើរ ។

នៅៈ ពីថ្នាក់លើគេឲ្យយើងសិក្សា អញ្ចឹងយើងឆ្លងកាត់រៀនសិក្សាហ្នឹងជាទ្រឹស្តីដែលយើងទទួលបានពីគេយើងពាំនាំពាក្យហ្នឹងមកផ្សព្វផ្សាយបន្តនៅក្រោមអញ្ចឹងកាលហ្នឹង អ្វីដែលគេនិយាយហ្នឹងគេមិនដែលនិយាយឲ្យយើង យើងចង់និយាយថាគេយកអាពាក្យជិះជាន់មកប្រើ ដើម្បីឲ្យយើងប្រៀបធៀបពីសង្គមមួយទៅសង្គមមួយអីអញ្ចឹងទៅណា៎ ដល់យើងផ្សព្វផ្សាយតគ្នាកាលហ្នឹងសំខាន់យើងមាន គេហៅសីលធម៌ ១២យ៉ាង ។

សុជាៈ មីងចាំខ្លះទេ?

នោះៈ មិនចាំទេក្មួយអើយ គ្រាន់តែថាចាំបានសីលធម៌ទី៦ហ្នឹង យុវជននារីទាក់ទងគ្នាចាំបានតែអាហ្នឹងមួយទេ គេមិនឲ្យយើងទាក់ទងគ្នាអាសីលធ៌មទី៦ហ្នឹង ចាំបានអាហ្នឹងមួយច្រើនជាងគេ ក្រៅពីហ្នឹងមិនដឹង ។ សីលធ៌មដែលគេនិយាយមកគឺសុទ្ធតែល្អហើយណា៎.....។

សុជាៈ អញ្ចឹងយើងដើរបំផុសអីអញ្ចឹងគេមានគោលការគេពីលើមកបង្រៀនយើងដែរណា៎ ។

នោះៈ ចា៎!

សុជាៈ ហើយអ្នកបង្រៀនហ្នឹងគេថ្នាក់ណាដែរ?

នោះៈ វាមានខ្សែចាត់តាំងគេ វាមានថ្នាក់ស្រុក ថ្នាក់តំបន់ថ្នាក់ភូមិភាគអីអញ្ចឹង ហើយយើងឆ្លងកាត់ក្នុងវគ្គហ្នឹងបានយើងយកមកផ្សព្វផ្សាយតាមមូលដ្ឋាន ។

សុជាៈ ថ្នាក់ស្រុកគេមកបង្រៀនយើង?

នោះៈ គេហៅយើងទៅជាវគ្គ ។

សុជាៈ កាលហ្នឹងគណៈឃុំមីងឈ្មោះអីដែរ?

នោះៈ ស្លាប់អស់ហើយ ។

សុជាៈ ចាំឈ្មោះគេទេ?

នោះៈ មិនចាំ នៅចុងៗមាត់ព្រោះយើងបែកពីគេទៅយូដែរ ព្រោះដល់មៅឆ្នាំ៧៣ មីងឡើងផុតពីឃុំហ្នឹងទៅស្រុកទៀត ។

សុជាៈ ចុះគណៈស្រុកគេឈ្មោះអី?

នោះៈ គណៈស្រុកកាលដែលមីងនៅធ្វើការជាមួយហ្នឹងឈ្មោះ តាសុខ ហើយមួយទៀតឈ្មោះគេហៅតាចង្អូមៗហ្នឹង ហ្នឹងឈ្មោះងារដែលគេហៅគាត់ទេណា៎ មីងមិនដឹងថាគាត់ឈ្មោះពិត ដុនគាត់ឈ្មោះអីទេ ។

សុជាៈ ចុះគាត់មក អ្នកមកនៅហ្នឹងគាត់មកពីខាងស្រុក ខេត្តណាដែរ?

នោះៈ មីងអត់សូវដឹងដែរ ។

សុជាៈ អត់ដឹងថាគាត់មកពីខាងណាដែរ? មិនមែនអ្នកស្រុកជីក្លាងយើងទេ?

នោះៈ មិនមែនទេ ។

សុជាៈ ហើយដល់ពេលឆ្នាំ៧៣មីងឡើងទៅជាប្រធាននារីស្រុកទៀតរឺអត់ទេ?

នោះៈ អត់ទេ មីងឡើងទៅកងទ័ពនារីស្រុក ។

សុជាៈ ឋានៈអីដែរ?

នៅៈ ប្រធានក្រុម ថាអញ្ចឹងចុះ ។

សុជាៈ ចុះដល់ពេលឡើងទៅអញ្ចឹងកាលនៅជានារីឃុំអីចឹងយើងអត់មានឡើងកាន់កាំភ្លើងទៅទេ?

នៅៈ អត់ទេ ។

សុជាៈ ចុះឡើងនារីឃុំ អ្ហីឡើងយុទ្ធនារីស្រុក?

នៅៈ យើងក៏មិនមានឡើងទៅវិដែរព្រោះតួនាទីកាលហ្នឹង យើងដឹកស្បៀងចូលសមរភូមិផ្ទាល់ ។ កាលដែលយើងនៅត្រឹមភូមិ ត្រឹមឃុំយើងដឹកជញ្ជូនតែយុទ្ធជនយុទ្ធនារីឲ្យគេទៅ តែដល់ពេលយើងឡើងទៅដល់ស្រុកហ្នឹងគឺយើងដឹកស្បៀងផ្ទាល់ទៅ ដូចថានាំស្បៀងនាំគ្រាប់ហ្នឹងដល់យុទ្ធជនសមរភូមិមុខតែម្ដង ។

សុជាៈ ហើយកាលហ្នឹងបងប្អូនមីងផ្សេងៗទៀតគេចូលទេ មានគេឲ្យចូលទេ?

នៅៈ បងប្អូនមីងដែលនៅផ្ទះហ្នឹងគេនៅក្នុងសហករធម្មតា ។

សុជាៈ នៅតែមីងមួយទៅ?

នៅៈ មានតែមីង ។

សុជាៈ មីងកូនបងគេ?

នៅៈ ទី៣ ។

សុជាៈ ទី៣ អ! អញ្ចឹងបងៗទៀតគាត់មានគ្រួសារហើយ?

នៅៈ បងស្រីខ្ញុំគាត់ៗចូលធ្វើការដែរតែគាត់នៅខាងគាត់ដែរ ។ ហើយបងប្រុសខ្ញុំមានប្រពន្ធហើយនៅសហករណ៍ ហើយប្អូនខ្ញុំប្អូនពៅ នៅជាមួយម៉ែខ្ញុំនៅក្នុងសហករណ៍ ។

សុជាៈ កាលមីងចូលដំបូងមីងអាយុប៉ុន្មានហើយមីង?

នៅៈ គិតទៅប្រហែលជា២២ សងមើលត្រូវពី.... ។

សុជាៈ ឆ្នាំ៧០ហ្នឹង?

នៅៈ ៧០ហ្នឹងតែម្ដងទៅ ប្រហែលជា២២ សងទៅត្រូវទេមើ ។

សុជាៈ ប្រហែលជាត្រូវហើយមើលទៅ ។

នៅៈ កំពុងតែពេញអ្ហាស៎ ពេញកំលាំងអ្ហាស៎ ។

សុជាៈ បាទ...ហើយគេមកឃោសនាថាម៉េចបានយើងស្ម័គ្រចិត្តចូលទៅ មុនដំបូង?

នៅៈ  អាហ្នឹងដូចថាវាតាមៗគ្នា  ព្រោះកាលហ្នឹងនៅឯស្រែហ្នឹងវាគ្មានវិគ្មានសង្រ្គាមអីទេ  ដូចថាខ្មែរក្រហមមករុញៗចូលមកព្រៃវែងអីអញ្ចឹង ។  ហើយអញ្ចឹងអ៊ីដែលយើងរស់  នៅក្នុងសង្គមគេយើងត្រូវតែតាមគេយើងមិនអាចប្រឆាំងបានទេ ។

សុជាៈ  តែពេលហ្នឹងគេឃោសនាដែរ?

នៅៈ  គេឃោសនាដែរ  គេថាគេនឹងរំដោះឲ្យរួចផុតពីការជិះជាន់  គេច្រើនប្រើពាក្យសក្តិភូមិ ប្រើពាក្យអភិជន រឺគេបែងចែកវណ្ណៈឲ្យយើងស្អប់ៗការជិះជាន់ និយាយអញ្ចឹងចុះ ។

សុជាៈ  ហើយកាលហ្នឹងមីងមានឮដូចថាការអំពាវនាវពី?

នៅៈ  មាន ចា៎! យើងស្តាប់យើងមានវិទ្យុមួយស្តាប់ការអំពាវនាវរបស់សម្តេចពីចិនមក ពីព្រៃម៉ាគឺមកអីចឹង ។  ហើយយើងក៏នឹកឃើញថាយើងមានជំហរ  មានបង្គោលរឹងមាំដែរ អញ្ចឹងយើងមិនខ្លាចអីនឹងចូលទេណា៎ ។

សុជាៈ  បាទ! បាទ! អ្វីដូចថាសម្តេចសីហនុ បើនិយាយទៅគាត់ជាស្តេចណា៎ ហើយគាត់បើនិយាយពីវណ្ណៈគាត់ វណ្ណៈសក្តិភូមិហើយ ព្រោះយើងប្រើពាក្យនេះណា៎ តែដល់ពេលយើងគេ ឃោសនាយើងឲ្យប្រឆាំងនឹងរបបជិះជាន់សក្តិភូមិមូលធនអីអញ្ចឹង វាមិនប៉ះពាល់ដល់គាត់មីងដូចថា?

នៅៈ  យើងៗចង់និយាយថាកាលហ្នឹងសម្តេចក៏គាត់ដាក់ខ្លួនជាមួយខ្មែរក្រហមដែរ  អញ្ចឹងយើងគិតថាមិនដឹងគិតថាម៉េចទេ  នឹកឃើញថាគាំទ្រគាត់ដើម្បីឲ្យគាត់មកគ្រប់គ្រងប្រទេសវិញ យើងៗមិនគិតថា  តែតាមពិតទៅយើបត់តាមគេមិនទាន់ទេ  គេជ្រៅណាស់ហើយទុកគេខ្ចី ហើយយើងវែងអញ្ចឹងយើងមិនអាចប្រឆាំងគេបានទេ ។  កាលហ្នឹងបើយើងនិយាយទៅគឺថាយើងនៅក្នុងការប្រមូលកំលាំងជាប្រជាជាតិអីអញ្ចឹង ប្រមូលកំលាំងដើម្បីរំដោះទឹកដី ។

សុជាៈ  ហើយមីង អ្នកភូមិចូលជំនាន់មីងហ្នឹងច្រើនគ្នាដែរទេ?

នៅៈ  គឺទាំងអស់ហ្នឹងណា៎ ។

សុជាៈ  នៅទាំងអស់ម៉េច ។

នៅៈ  នៅទាំងអស់មួយភូមិៗអញ្ចឹង  ប៉ុន្តែគ្រាន់ថាមួយទៅដាច់ទៅផ្ញើនៅជាមួយអង្គភាពវាដាច់ហើយមួយទៀតនៅក្នុងភូមិ ។ ជាទូទៅមិនអាចមានពីណាមិនចូលមិន ទោះបីថាមិន ពេញចិត្តក៏ត្រូវតែសម្ងំសិនដែរ យើងនិយាយអញ្ចឹងចុះ ។ មិនអញ្ចឹង?

សុជាៈ បាទ! បាទ ។

នៅៈ តែក្មួយឯងសង្ស័យកើតមិនទាន់ទេ ។

សុជាៈ ខ្ញុំកើតអត់ទាន់ កើត៧៧កើតនៅនេះកើតនៅក្រោយ...បើចេញតាមនេះទៅជិតដែរទេនៅព្រែកតាសនេះ នៅពារាំងយើង ។ ហើយមីងដល់ពេលមីងឡើងទៅនារីស្រុកធ្វើការបានយូរទេ?

នៅៈ ៧៣, ៧៤មីងឡើងទៅទ័ពនារីភូមិភាគ ។

សុជាៈ ឡើងតទៅទៀត ។

នៅៈ ឡើងតរហូតគិតទៅសកម្មណាស់ ។ យើងដល់ពេលយើងឡើងទៅទ័ពនារីភូមិភាគហ្នឹងវាមានបីវរសេនាតូច អញ្ចឹងមីងនៅក្នុងអនុសេនាតូចលេខ២, មាន៣អនុសេនា, ៤អនុសេនាធំ ។

សុជាៈ អញ្ចឹងបើនិយាយទៅផ្ទោះ១តំបន់?

នៅៈ ចា៎! ផ្ទោះតំបន់ឡើងទៅភូមិភាគតែម្ដង កាលហ្នឹងវាអត់ទាន់មានទ័ពតំបន់ទេគេបង្កើតទ័ពនារីនៅភូមិភាគតែម្ដង ភូមិភាគបូព៌ា ។

សុជាៈ បាទ! ដូចមីងនៅទ័ពស្រុកអញ្ចឹងយើងអត់បានកាន់កាំភ្លើងទេ គ្រាន់តែដឹកជញ្ជូនស្បៀងរំសេវអីចូលទេណា៎ ។

នៅៈ អាចមានដែរកាំភ្លើងសំរាប់ការពារខ្លួន ។

សុជាៈ ចុះគេមានបង្ហាត់បង្រៀនឲ្យបេះក្បួនទេ?

នៅៈ បង្រៀន ។

សុជាៈ បង្រៀនដែរ?

នៅៈ បង្រៀនដែរប៉ុន្តែយើងអត់មានបានទៅប្រយុទ្ធនឹងគេទេគ្រាន់តែការពារខ្លួនទេ ប៉ុន្តែសំខាន់គេឲ្យយើងដឹកជញ្ជូនដល់សមរភូមិទាំងយប់ ពិសេសយើងប្រើពេលវេលាយប់ ថ្ងៃយើងសំរាក ។

សុជាៈ ថ្ងៃសំរាក ពីណាគេបង្ហាត់អ្នកដូចថាមើលការខុសត្រូវអីដឹកនាំ?

នៅៈ នារីមួយជាប្រធានហ្នឹងសព្វថ្ងៃនៅរស់ដែរតើ ។

សុជាៈ ឈ្មោះអីគេដែរ?

នោះ: ឈ្មោះ កុយ សៀ សព្វថ្ងៃនៅភូមិត្រពាំងព្រីង ឃុំជីរីពួន សព្វថ្ងៃគាត់នៅរស់ដែរតើ ប៉ុន្តែការដែលគេបន្ទាត់ហ្នឹងមិនមែនជាក្បួនយុទ្ធសាស្ត្រអីទេ គ្រាន់តែកាលដែលយើងនៅទ័ព ស្រុកហ្នឹងគ្រាន់តែឲ្យយើងចេះបាញ់ ហើយចេះកាន់តែប៉ុណ្ណឹងទេណា៎ ។

សុជា: កុយ គាត់ឈ្មោះកុយ សុខ?

នោះ: កុយ សៀ ។

សុជា: កុយ សៀ ។

នោះ: ស្រី ។

សុជា: នៅភូមិអីដែរ?

នោះ: ភូមិត្រពាំងព្រីង ។

សុជា: ស្រុកព្រៃវែងហ្នឹង?

នោះ: ស្រុកព្រៃវែង ។

សុជា: ចុះកាលហ្នឹងគណៈស្រុកហ្នឹងនៅឈ្មោះហ្នឹងដដែល? ឈ្មោះអីគេដែលមីងប្រាប់មិញ?

នោះ: ឈ្មោះ អឺ កាលដែលជំនាន់មីងនៅហ្នឹងឈ្មោះ គាជីកូម និងគាសុកហ្នឹងតែដល់ក្រោយ មកឮថាគេផ្លាស់ប្ដូរច្រើនអ្នកតទៅទៀតណា៎ តែមីងមិនចាំទេ ។ មីងចាំតែជំនាន់មីងនៅ ព្រោះមីងវានៅតិចដែរអ្ហាស៎ ខុទាហរណ៍ដូចថាយើងទៅមួយកន្លែង១ ។

សុជា: ចុះដល់ពេលគេមករើសមីងឲ្យទៅអញ្ចឹង ដល់យើងចូលទៅសមរភូមិមានដឹងថាទៅសមរភូមិ ណាខ្លះអីខ្លះទេ?

នោះ: យើងនៅសមរភូមិបារាយណ៍មួយ ហើយនឹងសមរភូមិខាងស្វាយសុខោ ។

សុជា: កាលហ្នឹងវៃ១ ចូលព្រៃវែងហ្នឹង?

នោះ: ចា៎! ចូលព្រៃវែងហ្នឹងតែយើងមិនមែនអ្នកវៃទេយើងជាអ្នកដឹកជញ្ជូន យើងនាំកំលាំង ស្បៀងទៅឲ្យទ័ពត្រៀមនៅខ្សែត្រៀមមុខ ហ្នឹងយើងយើងផុតពីការឃោសនាតាមភូមិ-ឃុំ ហើយ ពេលដែលយើងចូលទ័ពស្រុកហើយយើងអត់ ។

សុជា: ដល់ពេលមីងទៅអញ្ចឹង អឺ យើងទៅឡើងពីស្រុកមិញដោះដំបន់ នៅឆ្នាំណាដែរមីង ថាចិត ប៉ុន្មាន៧៤?

នោះ: ៧៤...ពាក់កណ្ដាលឆ្នាំ៧៤ មីងភ្លេចខែហើយចាំតែឆ្នាំ ។

សុជា៖ ភូមិភាគៗ អីគេដែរមិញ?

នោះ៖ បូព៌ា ។

សុជា៖ ហើយតំបន់អីនៅម៉្តុំភូមិមីងនៅហ្នឹង?

នោះ៖ វាដល់ពេលយើងឡើងទៅហ្នឹងវាចលត័ វានៅច្រើនកន្លែង ប៉ុន្តែកាលដែលយើង ទៅនៅទ័ពនារីភូមិភាគហ្នឹង យើងមិនទាន់បានចុះបំរើការងារទេគឺយើងនៅសិក្សាក្បួនយុទ្ធសាស្ត្រដល់៦ខែគឺបែកភ្នំពេញតែម្តង ។

សុជា៖ អត់បានវៃអីដែរ?

នោះ៖ អត់ទេយើងសាលារហូតនៅសាលា ស២០០ ។

សុជា៖ ស២០០ នៅម៉្តុំណា ស២០០?

នោះ៖ នៅស្រែស្តែយើងពាមជាំងហ្នឹង

សុជា៖ ពាមជាំង ។

នោះ៖ ប៉ុន្តែយើង ។

សុជា៖ ពាមជាំង?

នោះ៖ វានៅស្រុកអូរាំងឪ ។

សុជា៖ នៅម៉្តុំពានាអីហ្នឹង?

នោះ៖ អត់ទេ ទៅដល់ជប់ពាមជាំងអីនោះ ស្គាល់ទេ?

សុជា៖ អាណឹងគេហៅសាលា ស២០០?

នោះ៖ ចា៎! ប៉ុន្តែមីងទៅនៅអីឃុំប្រាសាទ ហ្នឹងភ្លេចអស់ហើយគ្រាន់តែដឹងថាសាលាស២០០ហ្នឹងបើយើងនិយាយតាមប្រវត្តិវាៗ ជាសាលាស្វាពលណា៎ ។

សុជា៖ ស្វាពលម៉េចមីង?

នោះ៖ អាហ្នឹងយើងទាំងនារីទាំងយុទ្ធជនអីវាឆ្លងកាត់សាលាហ្នឹងអ្នកាស៎ ។

សុជា៖ បាទ!បាទ! អញ្ចឹងគេហៅស្វាពល?

នោះ៖ ពេលណាខ្វះទ័ពអីគេដកចេញពីហ្នឹងទៅ ។

សុជា៖ ស្វា បានន័យថាធ្វើឲ្យទ័ពហ្នឹងស៊ាំចេះអាក្បួនយុទ្ធសាស្ត្រហ្នឹងទៅ បានឡើងបញ្ជូនទៅមុខ ។

នោះ៖ ចា៎!

សុជាៈ  អាហ្នឹងគេហៅស្វពលហ្នឹង?

នៅៈ  យើងហៅសាមញ្ញទៅវាស្រួលស្តាប់ ។

សុជាៈ  ហើយមីងនៅហ្នឹងគេហៅតំបន់ប៉ុន្មាន ខាងព្រៃវែងស្រុកព្រៃវែង អូរាំងឪអីហ្នឹង?

នៅៈ  មីងបើកាលហ្នឹងគេហៅតំបន់២៨ ប៉ុន្តែមីងអត់បានឆ្លងកាត់នៅក្នុងតំបន់យើងឡើងទៅ ភូមិភាគតែម្តងអញ្ចឹង ។

សុជាៈ  តំបន់២៨ដូចហៅខាងនោះ ។

នៅៈ  ២៨, ២០គត់អីហ្នឹងវានៅក្នុងតំបន់ភូមិភាគហ្នឹង ។

សុជាៈ  ភូមិភាគបូព៌ាហ្នឹង?

នៅៈ  ចា៎! ភូមិភាគបូព៌ា ។

សុជាៈ  អញ្ចឹងអាហ្នឹង២០ ឬក៏២០?

នៅៈ  ២២, ២៨ អីហ្នឹងវានៅក្នុងភូមិភាគបូព៌ា ។

សុជាៈ  បើខ្ញុំទៅសួរគេខាងណោះ ខាងព្រះស្តេច, ខាងពាមជរខាងអីនោះវា២៨ ។ ប្រហែលជាតំបន់២០ ឬក៏២០ ។

នៅៈ  ២០ ។

សុជាៈ  បាទ! ២០ ។

នៅៈ  ២២ វានៅខាងតំបន់ ស្រុកកោះសូទិនអីណោះ ។

សុជាៈ  អញ្ចឹង ២២ នៅកោះសូទិនវិញ?

នៅៈ  ចា៎!

សុជាៈ  គណៈតំបន់មីងស្គាល់ឈ្មោះគេទេ?

នៅៈ  ភ្លេចហើយ ។

សុជាៈ  ភ្លេចហើយ?

នៅៈ  ចា៎!

សុជាៈ  ចុះគណៈភូមិភាគ?

នៅៈ  កាលហ្នឹងនៅ សោ ភឹម ។ តែមីងមិនស្គាល់ទេគ្រាន់តែដឹងតែឈ្មោះ ។

សុជាៈ  ចុះអ្នកគ្រប់គ្រងទ័ពមីងស្រីហ្នឹងឈ្មោះអីដែរនៅភូមិភាគហ្នឹង?

នៅ៖ នៅសាលាស្គាល់នៅសាលាទេ? ឈ្មោះ អឺ ឈ្មោះ ស៊ិន តែមិនដឹងស្អីស៊ិនទេ។

សុជា៖ ឈ្មោះស៊ិន។

នៅ៖ យើងហៅបងស៊ិនៗ អញ្ចឹងអ្នាស់។

សុជា៖ នារីដែរ?

នៅ៖ ប្រុស។

សុជា៖ អីដែរស៊ិនហ្នឹង?

នៅ៖ គ្រប់គ្រងនារីទ័ពនារីហ្នឹងតែម្ដងដូចថាផ្នែកនយោបាយ ផ្នែកគ្រប់គ្រងផ្នែកនយោបាយ។

សុជា៖ នៅណា?

នៅ៖ អត់ស្គាល់ អត់ដឹងទីលំនៅទេ។

សុជា៖ អត់ទេ តែគ្រប់គ្រងហ្នឹងនៅ?

នៅ៖ នៅសាលា។

សុជា៖ នៅសាលា ស២០០ហ្នឹង?

នៅ៖ សាលា ស២០០។

សុជា៖ ចុះដល់ពេលមីងនៅហ្នឹងហាត់រៀនហ្នឹងមានតែស៊ិហ្នឹងមួយឬក៏មានអ្នកផ្សេងៗទៀត?

នៅ៖ មានច្រើន។

សុជា៖ គេមកបង្ហាត់។

នៅ៖ ក្នុងៗ ទ័ពនារីហ្នឹងវាមានដូចថាម៉ាអនុសេនាធំវាមានជំនួយការពីអ្នកប្រុសៗអ្នាស់ សំរាប់ផ្ទាល់ពិភាក្សាផ្ទាល់ នៅជាមួយយើងផ្ទាល់តែម្ដងមានប្រុសៗពីរនាក់ជួយ។

សុជា៖ អ្ហីហាត់រៀនហ្នឹងហាត់តែយុទ្ធសាស្ត្រទេ រឺក៏មានបង្រៀនពីនយោបាយអីខ្លះដែរ?

នៅ៖ មានដែរ។

សុជា៖ មានដែរ?

នៅ៖ ចា៎! ប៉ុន្តែភាគច្រើនគេច្រើនតែនិយាយពីទ្រឹស្ដីប្រយុទ្ធ។

សុជា៖ ទ្រឹស្ដីប្រយុទ្ធ?

នៅ៖ ចា៎!

សុជា៖ ហើយគ្រូៗគេហ្នឹងគ្រូមកពីណាវិញ?

នៅៈ គ្រូមិនដឹងជាមកពីណាៗទេព្រោះយើងមិនបានស្គាល់ប្រវត្តិគេ ដូចថាគេមកបង្រៀនយើង

សុជាៈ ស២០០ហ្នឹងបើតាមមីងដឹងកើតយូរហើយឬនៅ?

នៅៈ កើតយូរហើយ ។

សុជាៈ តាំពីឆ្នាំណា?

នៅៈ ទេមិនដឹងទេ គ្រាន់តែដឹងថាទ័ពចេញពីសាលាស២០០ ទៅទ័ពដែលគេដូចថាហ៊ឹកហ៊ឺន ។

សុជាៈ មីងមានដឹងមូលហេតុអីបានជាគេដាក់ ស២០០?

នៅៈ មិនដឹង ។

សុជាៈ អត់ដឹងដែរ?

នៅៈ ចា៎! តែយើងហៅធម្មតាថាសាលា ស២០០ សំរាប់កន្លែងសួពលយើងប្រើពាក្យសាមញ្ញ អញ្ចឹង ។ ហើយយើងក៏ធ្លាប់ឆ្លងកាត់នៅកន្លែងហ្នឹងអស់រយៈពេល៦ខែ ។ ៦ខែហើយ ចប់បែកភ្នំពេញតែម្តង ។

សុជាៈ អ្នកគ្រប់គ្រងធំនៅហ្នឹងឈ្មោះអីដែរមានដឹងទេ?

នៅៈ ភ្លេចហើយមិនដឹង មិនចាំទេ ។

សុជាៈ សាលាហ្នឹងនៅក្នុងចំការកៅស៊ូហ្នឹងតែម្តង?

នៅៈ មិនទេ មិននៅចំការកៅស៊ូទេវានៅម្តុំ សាលាគេមិនមែនមានតែមួយកន្លែងទេវាមានច្រើនកន្លែង អញ្ចឹងគ្រាន់តែយើងដឹងថាទីតាំងធំគេនៅស្រែស្តែហ្នឹង ។

សុជាៈ ស្រែស្តែហ្នឹង?

នៅៈ ចា៎! ម្តុំភូមិគោកគង់ ភ្លេចអស់ហើយ ម្តុំភូមិត្នោតភូមិអីហ្នឹងតែមីងភ្លេច..

សុជាៈ បាទ! បាទ! គោកគង់ គោកអីហ្នឹងណា៎ ។ ចុះសាលាហ្នឹងលឺគេថាមានដូច នៅពានានេះក៏មានដែរ ឬក៏មានសាលាស២០០ ឈ្មោះ ស២០០ដែរ?

នៅៈ ចា៎! គេបំបែកកន្លែងរៀន វាមិនមែននៅម្តុំទេ ។

សុជាៈ អញ្ចឹងរាប់ពាន់នាក់ រាប់ម៉ឺននាក់ដែរសាលាហ្នឹង?

នៅៈ ម៉ា៉ជំនាន់មីងរៀនហ្នឹងយើងគិតថានារីម៉ា៉ៗ វរសេនាតូចវាមាន ៥០០ដាង អញ្ចឹងវានមានបីវរៈវា៥០០ដាង សុទ្ធតែនារី ។

សុជាៈ សុទ្ធតែកាន់កាំភ្លើង?

នៅៈ អត់មានទេយើងទៅរៀនអញ្ចឹងគេមិនឲ្យយើងកាន់ទេ យើងទៅរៀន ។

សុជាៈ ចុះដល់ពេលរៀនបាញ់រៀនអីម៉េចទៅ?

នៅៈ កាន់តែដល់ហើយទៅគេមិនឲ្យយើងកាន់ជាប់នៅនឹងខ្លួនទេ អាហ្នឹងគេហៅរៀនវាមិននៅជាប់នឹងខ្លួនទេ រៀនតែម៉ាពេលហើយគេយកចេញ ។

សុជាៈ បាទ! យកចេញ ។ កន្លែងមីងហ្នឹងសុទ្ធតែយុទ្ធនារីសុទ្ធតែម្តង អត់មានបុរសអត់ មានអីទេ?

នៅៈ បុរសមានតែជំនួយការទេ ជំនួយការពិភាក្សាបង្រៀនយើងផ្ទាល់ ។

សុជាៈ ចុះទ័ពប្រុសៗហ្នឹងគេរៀនសាលាផ្សេងទៀត?

នៅៈ ចាំ! ផ្សេងអត់មានចូលគ្នាទេ ។

សុជាៈ អត់មានចូលគ្នាទេ?

នៅៈ ចាំ! គឺយើងអត់ដែលឃើញ គឺថាបំបែកកន្លែងយើងរៀនអីអញ្ចឹង ។

សុជាៈ គេមានពន្យល់ថាហេតុអីបានជាគេដាក់ ស ហេតុអីបានជាគេដាក់លេខ ២០០ហ្នឹងមានដឹងដែរទេ?

នៅៈ វាដូចជាមាន ២០០ជាងអីអញ្ចឹង ប៉ុន្តែវាមានកំរិតថ្នាក់គេបានមីងមិនដឹងដែរ ។

សុជាៈ ២០០ជាងម៉េច?

នៅៈ ២០២, ២០៣, ២០១ អីអញ្ចឹងឧទាហរណ៍ ។ តែមីងទៅរៀននៅកន្លែងស២០០យើងគ្រាន់តែដឹងតែប៉ុណ្ណឹង តែក្រវិចក្រវៀនដែលគេដាក់ឈ្មោះហ្នឹងយើងមិនបានសួរ ដេញដោលហើយយើងក៏មិនបានស៊ើបឲ្យដឹង ពីប្រវត្តិម៉េចបានគេដាក់អាហ្នឹងយើងអត់ដឹង ។

សុជាៈ បាទ! ទាហានឬក៏យុទ្ធជន យុទ្ធនារីហ្នឹងដែលឆ្លងកាត់ ទំរាំតែបានឡើងទៅវ៉ៃសមរភូមិហ្នឹងរៀននៅហ្នឹងប៉ុន្មានខែទំរាំបានចេញទៅវ៉ៃ?

នៅៈ ៦ខែ ។

សុជាៈ ៦ខែ?

នៅៈ ចាំ!

សុជាៈ អញ្ចឹងមានទាហានណាដែលគេយកឡើងសមរភូមិអត់ៗ បានចេញពីកន្លែងបង្ហាត់ហ្នឹងដែរទេ?

នៅៈ	អត់ទេ ន៎ែ មិនដឹងដែរ ប៉ុន្តែតាមមឹងដឹងអ្នកដែលគេរើសទាហានដែលទៅវ៉ៃ ភាគច្រើនគេឆ្លងកាត់សាលាហ្នឹងសិន ។

សុជាៈ	សាលាហ្នឹងនៅក្នុងភូមិភាគយើង?

នៅៈ	ភូមិភាគបូព៌ា ។

សុជាៈ	បូព៌ាហ្នឹងដែរ? មិនមែន សោ ភឹម ទេអ៊ែ្ហសអ្នកគ្រប់គ្រងធំ?

នៅៈ	សោ ភឹម គ្រាន់តែជាគណៈភូមិភាគតែអ្នកគ្រប់គ្រងសាលាហ្នឹងវាជារឿងផ្សេង អ្នកផ្សេង ។

សុជាៈ	មានឈ្មោះអី ស្គាល់ឈ្មោះទេ?

នៅៈ	មិនស្គាល់ ។ ព្រោះកាលហ្នឹងពិបាកនឹងស្គាល់គេដែរ ព្រោះ អី ទំរាំយើងដល់ខាងលើហ្នឹងវាមានអ្នកឆ្លងពីក្រោមទៅពីរបីកន្ទាក់ ទំរាំតែដល់ លើអញ្ចឹងឋានៈប្រហែលយើងៗ មិនអាចទៅជួបនឹងមេផ្ទាល់បានទេ អ្នកពាំនាំពាក្យអញ្ចឹង យើងមិនអាច ហើយឈ្មោះកាលហ្នឹងឧទាហរណ៍ ដូចឈ្មោះខ្ញុំអញ្ចឹងខ្លួនយើងម្នាក់យើងដឹង ហើយយើងឈ្មោះ នៅពិតប្រាកដដែលម៉ែឪដាក់ឲ្យ តែដល់យើងទៅហ្នឹងយើង ប្រែឈ្មោះមួយទៀត ។

សុជាៈ	ដូរឈ្មោះ ។

នៅៈ	ចា៎! ដូរឈ្មោះ ។

សុជាៈ	អញ្ចឹងភីហ្នឹងដូនៅពេលហ្នឹងរឺក៏រឹដូរពេលណា?

នៅៈ	ប៉ុន្តែ ដូរៗកាលដែលយើងចូលនៅឆ្នាំ៧០ហ្នឹងតែម្តង ។

សុជាៈ	៧០ហ្នឹង?

នៅៈ	ចា៎! អញ្ចឹងជាទូទៅអ្នដែលគេធ្លាប់ធ្វើការជាមួយយើងគេស្គាល់ឈ្មោះពិត ឈ្មោះពិតយើងគេអត់សូវស្គាល់ទេ ។

សុជាៈ	គេស្គាល់ឈ្មោះទីពីរ ។

នៅៈ	ចា៎!

សុជាៈ	ចុះទៅដល់ហ្នឹងលែងដូរហើយ?

នៅៈ	លែងដូរហើយ ។

សុជាៈ	ដាក់ឈ្មោះ នៅ ភី, ជុំ ភី អញ្ចឹងទៅ?

នោះ: ចាំ! ដូចទីវ អុល មីងស្គាល់នៅឆ្នាំ៧៣ អញ្ចឹង ទីវ អុល ដែលគាត់ធ្លាប់ធ្វើសាស្ត្រាចារ្យនៅអន្តខ្វងអ្នាស់ អញ្ចឹងដល់ពេលដែលយើងឃើញគាត់អ្នាស់ យើងស្គាល់កាលហ្នឹងយើងស្គាល់ដោយសារយើងទៅបំរើគេបើកវគ្គធំអ្នាស់ នៅជីក្ងាវហ្នឹងគេហៅយើង ទៅបំរើការងារដាំបាយ ដល់ពេលយើងស្គាល់គាត់យើងអត់...គាត់មិនមែនឈ្មោះទីវ អុល ទេ គាត់ឈ្មោះស្រអែម ។ តែដល់ពេលយើងឃើញមុខ បានយើងថា អ៊ីបងខ្ញុំស្គាល់ច្បាស់ណាស់ ដល់អញ្ចឹងគាត់ថាស្គាល់ច្បាស់ថាខ្ញុំនៅឯណា ខ្ញុំថាខ្ញុំស្គាល់ ធ្លាប់ធ្វើនៅសាលាធ្លាប់ធ្វើគ្រូនៅអន្តខ្វង បានគាត់បិទយើងមិនឲ្យយើងនិយាយ ថាបើស្គាល់ៗត្រឹមយើងបានហើយ ។ អញ្ចឹងគេប្រែឈ្មោះអញ្ចឹង ទាល់តែយើងធ្លាប់ស្គាល់ឈ្មោះមនុស្សហ្នឹងទើបយើងទៅប៉ាច់តែម្តង ។

សុជា: ទីវ អុល ហ្នឹងគាត់ពីមុនឆ្នាំ៧០ ហ្នឹងគាត់គ្រូនៅអន្តខ្វងហ្នឹង?

នោះ: ចាំ! សាស្ត្រាចារ្យ ។

សុជា: អ្ហ៎ ដល់ពេលចលនាខ្មែរក្រហមគាត់ទៅតែម្តង?

នោះ: គាត់ទៅតែម្តង ដល់ពេលយើងឃើញបានវគ្គទៅបានយើងស្គាល់ ។

សុជា: មីងជួបគាត់នៅណា?

នោះ: ជួបនៅជីក្ងាងហ្នឹង ។

សុជា: គាត់ធ្វើអីគេនៅហ្នឹង?

នោះ: គាត់កាន់ខាងអប់រំ ។

សុជា: អប់រំស្រុក? ឃុំ?

នោះ: ទូទាំងប្រទេស គេបើកវគ្គធំអ្នាស់ គេហៅយើងទៅបំរើការងារដាំបាយដល់ពេល យើងដល់យើងឃើញអញ្ចឹងបានយើងស្គាល់ ។

សុជា: ចុះគាត់ៗឆ្នាំណា? នៅឆ្នាំណា? ចិតប៉ុន្មាន?

នោះ: ប្រហែលជា៧៣ ។

សុជា: ៧៣?

នោះ: ចាំ! ៧៣ ។

សុជា: ហើយទីតាំងគាត់មានដឹងថាគាត់មកពីណាអីដែរទេ?

នៅៈ យើងគ្រាន់តែដឹងថាមកអឹមដ្បឹម តែកន្លែងកន្ទុកមិនដឹងទីណាទេតែគេមកបើកវគ្គនៅហ្នឹង ។

សុជាៈ បើកវគ្គនៅហ្នឹងប៉ុន្មាន?

នៅៈ ម៉ាខែ ។

សុជាៈ ម៉ាខែ?

នៅៈ ចា៎!

សុជាៈ ហើយអ្នកដែលចូលរួមគាត់ហ្នឹងឋានៈត្រឹមណាដែរ?

នៅៈ មេឃុំ ។

សុជាៈ ថ្នាក់មេឃុំឡើង?

នៅៈ ថ្នាក់មេឃុំដល់ស្រុកដល់តំបន់ ភូមិភាគ ។

សុជាៈ ភូមិភាគ?

នៅៈ ចា៎!

សុជាៈ អញ្ចឹងធំជាងតាសោ ភឹមទៀត?

នៅៈ ធំជាង ។

សុជាៈ ធំជាង ។ ហើយមានអ្នកមកផ្សេងទៀតទេ ក្រៅពីគាត់?

នៅៈ មាន ។

សុជាៈ ពីណាគេ?

នៅៈ ហ៊ូ យន់, ហ៊ូ នឹម អីហ្នឹង ខៀវ សំផន អីហ្នឹង ។

សុជាៈ សុទ្ធតែសេរីសាស្ត្រាចារ្យ?

នៅៈ ចា៎! សុទ្ធតែសេរីអ្នកកាន់ក្បាលម៉ាស៊ីន ។

សុជាៈ ចុះឥឡូវ ទីវ អុល ហ្នឹងនៅរស់ដែរទេ?

នៅៈ ស្លាប់ហើយ ប្រហែលជាស្លាប់ ។

សុជាៈ នៅតែខៀវ សំផន មួយ ។ មានដែលឃើញខៀវ សំផន ទេពេលដែលមកសាលាហ្នឹង?
ឃើញគាត់ដែរទេ? ឃើញដែរ?

នៅៈ ចា៎!

សុជាៈ គាត់មកនៅហ្នឹងម៉ាខែតែម្តង?

នៅៈ ម៉ាខែ តែគេមិននៅជាប់ដូច ឧទាហរណ៍ថាក្នុងវគ្គហ្នឹងគេមានគ្រូប្រចាំថ្នាក់វា អញ្ចឹងគេគ្រាន់តែមកត្រួតពិនិត្យហើយគេទៅវិញ អញ្ចឹងយើងគ្រាន់តែឃើញម៉ាភ្លែតៗទេ ។

សុជាៈ អត់ដឹងថា?

នៅៈ តែយើងមិនដឹង ដល់ពេលយើងបែកហើយទេ ខៀវ សំផន បានយើងស្គាល់ច្បាស់ទៅតាមរយៈពេលយើងដូចថាសមាធិទៅឃើញថា មនុស្សនេះយើងធ្លាប់ឃើញកាលពីឆ្នាំនេះ ។

សុជាៈ កាល ៧៣ហ្នឹងគាត់អត់បានខទ្វេសនាមគាត់ថា គាត់ឈ្មោះ ខៀវ សំផន អីទេ?

នៅៈ អត់ទេគេប្រែឈ្មោះទាំងអស់ ។

សុជាៈ មានដឹងថាគាត់ឈ្មោះអីទេ ឈ្មោះប្រែ?

នៅៈ មិនដឹងទេ ខ្ញុំស្គាល់ច្បាស់តែ ទីង អុល មួយទេ ។

សុជាៈ ទីវ អុល ៗបងស្រអែមណា៎ ។

នៅៈ ឈ្មោះស្រអែម ។

សុជាៈ ចុះហ៊ូ យន់, ហ៊ូ នឹម?

នៅៈ ក៏គេប្រែឈ្មោះដែរ ។

សុជាៈ អញ្ចឹង ហើយសោ ភឹម មានឃើញទេកាលហ្នឹង?

នៅៈ អត់ដែលឃើញទេ ។

សុជាៈ អត់ទាន់ចេញទេ?

នៅៈ ហ្នឹងហើយ ។

សុជាៈ សោ ភឹម បើនិយាយទៅគាត់ជាទ័ពវិញ មិនមែនជាអ្នកឃោសនាអីទេ?

នៅៈ មិនមែនទេ អាហ្នឹងវា អ្នកដែលគ្រប់គ្រងទ័ពហ្នឹងផ្សេង អ្នកដែលគ្រប់គ្រងនយោបាយហ្នឹងផ្សេង ប៉ុន្តែនៅក្នុងចង្កោមគណៈកម្មការគេហ្នឹងមីង របនាសម្ព័ន្ធមីងអត់សូវដឹងទេ យើងដឹងតែម៉ាខ្លួនយើង ម៉ារង្វង់យើងអញ្ចឹងរឿងផ្សេងយើងមិនសូវ យើងមិនដឹងទេ ។

សុជាៈ មីងៗអញ្ចឹងនិយាយបកទៅក្រោយវិញ មីងថាគេឲ្យទៅដាំបាយទទួលពួកអ្នករៀននយោបាយហ្នឹងគេឲ្យមីងទៅស្តាប់ដែរទេ?

នៅៈ អត់ទេ យើងនៅដាំបាយឲ្យ កាលហ្នឹងយើងប្រើពាក្យកម្មាភិបាលអ្វាស់ អញ្ចឹងគេរើស ៗអ្នកទៅដាំបាយហ្នឹងក៏អ្នកហ្នឹងជាកំលាំងស្នូលរបស់គេដែរបានគេឲ្យទៅ ។

សុជាៈ គ្នាប្រហែលប៉ុន្មានអ្នកដែលទៅរៀនហ្នឹង?

នៅៈ ប្រហែលជាបើមិន២០០ ទៅ៣០០នាក់ ។ រៀននៅវត្តជីក្ងាងហ្នឹង វត្តជីក្ងាងយើងស្រុកព្រៃវែងហ្នឹង ហើយយើងទទួលយើងប្រធាននារីឃុំជីក្ងាងហ្នឹងអញ្ចឹងយើងមានមុខទៅដាំបាយបំរើគេ ហើយយើងមិនបានស្តាប់គេនិយាយពីអីទេ ។

សុជាៈ ហើយមានដឹង អត់បានស្តាប់អញ្ចឹងតើមានដឹងថាគេនិយាយពីស្អីៗដែរទេ?

នៅៈ អាហ្នឹងគេ ស្តាប់អីបើយើងអត់មានបានចូលក្បែរ ។

សុជាៈ ក្រែងលោអ្នកដែលគេមកហូបបាយអី ។

នៅៈ អ! សូន្យ ។

សុជាៈ គេអត់មាននិយាយអីទេ?

នៅៈ ឧទាហរណ៍ថាយើង ម៉ាផ្ទះអញ្ចឹងគេចែកនៅគ្នាបួនប្រាំនាក់អញ្ចឹងជាមួយអ្នកផ្ទះអញ្ចឹងហើយយើងនៅដាំបាយខាងក្រោមទេណា៎ យើងចងអង្រឹងដេកខាងក្រោមទេ ហើយគេនៅដេកខាងលើហ្នឹងអញ្ចឹងពេលដែលគេមកដល់ផ្ទះហ្នឹង គេមិននិយាយពីរឿងសាលាហ្នឹងទេ អញ្ចឹងយើងមិនដឹងថាសាលាហ្នឹងគេនិយាយពីស្អីអ្វាស់ ។ យើងគ្រាន់តែមានតួនាទីយើងដាំបាយឲ្យគេហូប មកងចេញមកគេមានបាយហូបទាន់ពេលវេលា ហើយពេលដែលយើង...ម្ហូបម្ហារត្រីសាច់អង្កអីយើងអត់មានទៅណាក្រៅពីភូមិហ្នឹងទេយើង គេមានអ្នកគេដឹកមកដល់ភូមិហ្នឹង ដល់មកងយើងទៅបើកពីកន្លែងក្នុងភូមិហ្នឹងតែម្តង អញ្ចឹងក្នុងម៉ារយៈពេលម៉ាខែហ្នឹងសូម្បីតែយើងចេញក្រៅភូមិក៏គេមិនឲ្យចេញដែរ ។

សុជាៈ ហើយមីងឥឡូវយើងបកទៅមុខបន្តិចវិញ នៅឆ្នាំ៧៨ដែលមីងចេញ នៅសាលាស២០០ហ្នឹងណា៎ ។ ដល់ពេលមីងនិយាយម៉ិញថាអត់មានបានវ៉ៃទេ គ្រាន់តែចេញចប់ពីសាលាហ្នឹង៦ខែមក បែកភ្នំពេញតែម្តង ។ មិនអញ្ចឹងអ្ហែស? ចុះបែកហ្នឹងគេឲ្យមីងទៅណា?

នៅៈ គេបញ្ជូនមីងមកនៅភ្នំពេញ ។

សុជាៈ នៅកន្លែងណា?

នៅៈ មីងមកនៅ អន្តភាព ស៨០ហ្នឹង ក្មេចហើយ ស៨០អញ្ចឹងហើយ ដូចជាច្រើនពាក្យ សៗណាំ មិនដឹងបានន័យថាម៉េចទេ។ ប៉ុន្តែក្នុងចន្លោមភស្តុភាសេនាធិការអ្អាស់ យើងនិយាយអញ្ចឹងចុះ។

សុជាៈ នៅណាដែរទីតាំង?

នៅៈ ទីតាំងនៅទួលគោក កាល៧៥មីងមកនៅភ្នំពេញកាល៧៥ បែក។

សុជាៈ ខែប៉ុន្មាន?

នៅៈ យើងបែកភ្នំពេញខែ៤ ប្រហែលមីងមកខែ៧ មីងចាំដូចចាំ។

សុជាៈ បា..ប៉ុន្មានអ្នកដែលមកជាមួយមីងហ្នឹង?

នៅៈ គេបែងចែកទៅតាមរោងចក្រខ្វះ តែមកនៅជាមួយមីងម៉ាកង បានន័យថាម៉ា គ។

សុជាៈ ម៉ា គ ?

នៅៈ ចាំ! ម៉ា គ ហ្នឹគេចែកជាបីទៀត។ មួយទៅខាងស្បៀង ម៉ាៗ ខ ទៅខាងស្បៀង ម៉ា ខ ទៀតទៅខាងស្អីគេហៅស្អី យានយុទ្ធ អ្អាស់ ខាងជួសជុលកាំភ្លើង...។

សុជាៈ យុទ្ធ យន្តយុទ្ធ?

នៅៈ ហ្នឹងហើយ យានយុទ្ធ។

សុជាៈ យានយុទ្ធ អ្វី យន្តយុទ្ធ?

នៅៈ មិនដឹងទេមិនដឹងគេហៅស្អីទេ គ្រាន់តែដឹងថាកន្លែងហ្នឹងគេជួសជុលកាំភ្លើងអ្អាស់។

សុជាៈ ជួលជុលធ្វើអាគ្រោះ ធ្វើឡានទាហានធ្វើអីហ្នឹងអ្ហែស?

នៅៈ ចាំ! ហើង ខ មីងហ្នឹងនៅកន្លែងគ្រប់គ្រងឃ្លាំងតែម្តង។

សុជាៈ ឃ្លាំងអីគេ?

នៅៈ ឃ្លាំងគ្រាប់។

សុជាៈ ឃ្លាំងគ្រាប់ហ្នឹងតែម្តង?

នៅៈ ចាំ!

សុជាៈ ចុះទៅយើងស្រីៗអញ្ចឹងធ្វើម៉េច អាហ្នឹងគេច្រើនតែដាក់ប្រុសៗអ្វី?

នោះ៖ ប្រុសៗក៏មានដែរ តែគេមិនឲ្យយើងនៅជាមួយគ្នា ឧទាហរណ៍ថាម៉ាកងគ្រប់គ្រងមុំណា ម៉ាកងគ្រប់គ្រងមុំណាអញ្ចឹង គេឲ្យយើងគ្រប់គ្រងដោយឡែកៗពីគ្នា ។ គ្រប់គ្រងហ្នឹង វាមានប៉ុន្មានៗអីអញ្ចឹង ។

សុជា៖ ដាក់វេនគ្នាយាមអីអញ្ចឹងទៅ?

នោះ៖ ដាក់វេនគ្នាយាមហើយយើងទុកដាក់សម្ភារៈ អាវុធយុទ្ធភ័ណ្ឌហ្នឹងគេដឹកជញ្ជូនមកតាមពីខេត្ត ដំបូងមកនៅស្តុកនៅភ្នំពេញហ្នឹង ។ ដឹកជញ្ជូនមកពីកំពង់ឆ្នាំង មកពីក្រចេះ ពីរមុខព្រួញ ហ្នឹង ។

សុជា៖ អាហ្នឹងមីងថាបោះសេនាធិការ ថ្នាក់ក្រសួងការពារជាតិតែម្តងហ្នឹង?

នោះ៖ ចាំ!

សុជា៖ អាហ្នឹងដូចថាយើងលែងនៅក្រោមការគ្រប់គ្រងដំបន់ហើយ អឺ ភូមិភាគហើយ?

នោះ៖ ចាំ! បើនិយាយទៅយើងនៅក្នុងចំនោមភស្តុភារសេនាធិការ តែវាមានច្រើនផ្នែកវាដូចមីង អញ្ចឹងមីងទៅនៅក្នុងគេហៅ ស៨០ហ្នឹង មិនដឹងខុសមិនដឹងត្រូវទេ តែប្រហែលជាហ្នឹង ហើយប្រហែលជាស៨០ហ្នឹងហើយ ព្រោះមីងនៅគ្រប់គ្រងកន្លែងគ្រាប់រំសេវអញ្ចឹងបាន ថាមីងបន្សល់ទុកនៅដូចជាពិការ ពេលដែលមីងបើកគ្រាប់ឲ្យគេ វាផ្ទុះនៅនឹងដៃ ដល់គេ សួរមីងៗច្រើនតែភូតថាខ្ញុំទៅធ្វើពលកម្ម តាមពិត ។

សុជា៖ ដៃហ្នឹង?

នោះ៖ នេះដៃនេះ ឥឡូវវាស្នាមវះហ្នឹង តែអាម៉ាគ្រាប់ហ្នឹងវាត្រូវរើហើយណាំ ពេលដែលយើង ពលកម្មខ្លាំងទៅវារើវានៅ ពេលមីងថតទៅវានៅអំបែង៩ទៀត តែវាអត់ឈឺ វាចេះតែ នៅអញ្ចឹងទៅ ។

សុជា៖ ចុះអាខ្នងដៃនេះ?

នោះ៖ អាខ្នងដៃនេះ មីងទៅស្វាយរៀងដួលម៉ូតូ វារមិចសសៃ អាហ្នឹងរឿងផ្សេងទេ ។

សុជា៖ ចុះដល់ពេលអញ្ចឹងខែរងារខែអីអត់ធ្វើទុក្ខទេអ៊ំស?

នោះ៖ ធ្វើទុក្ខមិនជាខ្លាំងខ្លាទេវា ពេលណាខែរងារ តែមីងបានចាក់ថ្នាំការពារតេតានុសហើយ តែវាបើយើងគិតទៅតាំងពីហ្នឹងដល់ហ្នឹងវាប៉ុន្មានឆ្នាំហើយក្មួយគិតមើតាំងពី៧៦អ្ហាស់?

សុជា៖ ៧៦ មកដល់ ២០០៦ វា៣០ឆ្នាំ ។

នោៈ ៣០ឆ្នាំហើយយើងមិនដែលប្រកាច់អីទេ វាគ្រាន់តែថាដល់ខែរងាររវាពិបាកដកដង្ហើមបន្តិច តែប៉ុណ្ណឹងទេ ។

សុជាៈ ទៅហ្នឹងស្រីៗប៉ុន្មាននាក់? ម៉ា គ ហ្នឹងអ្អែស?

នោៈ តែទៅជាមួយខ្ញុំតែម៉ា ១ ទេ ។ ជាង៣០នាក់ ។

សុជាៈ ៣០នាក់ ។ ដល់ពេលយើងទៅចែកវេនគ្នាយាមចំរុះជាមួយប្រុសៗដែរ រឺក៏យាម ដាច់ពីគ្នា?

នោៈ អត់ទេ ។

សុជាៈ ប្រុសៗគេយាមកន្លែងគេផ្សេង?

នោៈ កន្លែងគេផ្សេង យើងម៉ាប៉ុកយើងហ្នឹងម៉ុំទួលគោកហ្នឹងសុទ្ធតែស្រីៗទាំងអស់ ។

សុជាៈ តែមានអ្នកមកពីភូមិភាគផ្សេងទៅដែរទេ?

នោៈ មាន ស្រីៗហ្នឹង?

សុជាៈ បាទ ។

នោៈ ថ្ងៃក្រោយបានមានប៉ុន្តែដំបូងដែលយើងទៅគ្រប់គ្រងដំបូងដែលយើងពីបូព៌ាទៅ តែពីបូព៌ា ទៅវាមានកំពង់ចាមវាមានស្វាយរៀង វាមានព្រៃវែងវាមានបីខេត្ត ។

សុជាៈ ចុះក្រោយមកមានពួកភូមិភាគផ្សេងហ្នឹងមកពីណា?

នោៈ មីងចេញហើយបានមាន តែកាលមីងនៅហ្នឹងមានតែគ្នាយើងដែលចេញពីបូព៌ាហ្នឹងទៅទេ ។

សុជាៈ ចុះមីងការគ្រួសារមួយមុនថាមានកូនមួយស្លាប់ទៅហ្នឹង រៀបការនៅឆ្នាំណាដែរ?

នោៈ ចុងឆ្នាំ៧៦ ។

សុជាៈ ៧៦? ហ្នឹងពេលមីងនៅណាដែរ?

នោៈ នៅភ្នំពេញ ។

សុជាៈ នៅកន្លែងទួលគោកហ្នឹង?

នោៈ ចា៎!

សុជាៈ ចុះប្តីមីងហ្នឹងគាត់ធ្វើអី?

នោៈ នៅហ្នឹងដែរ តែនៅកងយុទ្ធជន ។

សុជាៈ យុទ្ធជន ដូចមីងនិយាយថាយុទ្ធជនគេយាមម៉ាក្រុមម្នាក់ហ្នឹង?

នៅៈ ចាំ!

សុជាៈ ចុះធ្វើម៉េចបានៗជួបគ្នា?

នៅៈ ចុះយើងទៅ ពេលយើងទៅដឹកជញ្ជូនយើងទៅជាមួយគ្នា ។

សុជាៈ ដឹកពីណាមក?

នៅៈ ដឹកជញ្ជូនហ្នឹងវាអញ្ចែក ជួនកាលវាមានកប៉ាល់មកពីក្រចេះមៅ នៅត្រង់អាម្តុំដៃរក្បាលស្ពានជ្រោយចង្វាហ្នឹងអ្ហាស់ ។ យើងជញ្ជូនចេញពីកប៉ាល់មកលើឡាន ៗចូលមកភ្នំពេញ ។

សុជាៈ គេដឹកគ្រាប់ដឹករំសេវហ្នឹងមកពីក្រចេះវិញ?

នៅៈ មកពីក្រចេះ ។

សុជាៈ ថីបានដឹកពីហ្នឹងមកវិញ គឺយើងគួតែចែកពី...

នៅៈ មិនដឹងដែរព្រោះ សួរគេគ្រាន់ដឹងថាគ្រាប់ហ្នឹងគេដឹកពីចិនមក វាឆ្លងកាត់រតនគិរីមណ្ឌលគិរី មកទល់ក្រចេះហ្នឹង អញ្ចឹងយើងមិនអាចឆ្លងឡានបាន យើងដាក់តាមកប៉ាល់ៗមៅចូលដែរហ្នឹង ។

សុជាៈ អាគ្រាប់ហ្នឹងមកតាំងពីមុនឆ្នាំ ៧៥ រឺក៏មកពេលក្រោយ៧៥?

នៅៈ អាចគ្រាប់ខ្លះមានមុន៧៥ អាចគ្រាប់ខ្លះទើបតែហ្នឹងមកថ្មី ។

សុជាៈ អាមកថ្មីគេដាក់កប៉ាល់ដាយរិចតែម្តងពីកំពង់សោមអីមកអ្ហើស?

នៅៈ អាចមាន ជួនកាលយើងជញ្ជូនពីកំពង់សោម យើងបែងចែកកំលាំងមួយចំនួនទៅ ៗយកពីកំពង់សោម មួយចំនួននៅចាំត្រង់ពោធិ៍វង្សាថ្មីអ្ហាស់ ។

សុជាៈ ព្រោះវាឆ្ងល់ដែរព្រោះ...កាលយើងមុនឆ្នាំ៧៥យើងនៅរំដោះវៃគ្នាជាមួយលន់ ណុលអញ្ចឹងអាវុធទាំងអស់ហ្នឹងវាជញ្ជូនមកចូលពីចិនតាមវៀតណាមតាមអីមកតាមរតនគិរីស្ទឹងត្រែងអីអញ្ចឹងមក ក្រចេះអីអញ្ចឹងមកណាំ យកមកបង្កប់នៅក្នុងព្រៃអីអញ្ចឹងទៅហើយដល់ពេលបែក៧៥ហ្នឹង ប៉ុល ពត វាកាន់តែម្នាក់ឯងទេ ដូចថាដៃកំពង់សោមប្រលានយន្តហោះ រទេះភ្លើងអីប៉ុល ពត គ្រប់គ្រងបានទាំងអស់ហើយណាំ ។ ហើយអាវុធហ្នឹង អាវុធធម្មតាបើយើងដឹកតាមផ្លូវឡានវាពិបាកដែរ វាអាចរលាក់វាផ្ទុះអីអញ្ចឹងណាំតែបើថាដឹកពីចិនមកដាយរិចមកគឺថាប្រហែលជាដាក់កប៉ាល់ ។

នៅៈ វាអញ្ចែក កាលហ្នឹងពេលដែលយើងបែក ៧៥ ហើយយើងទៅនៅក្នុងអង្គភាពហ្នឹង ជាអង្គភាពគ្រប់គ្រងគ្រឿងសាស្ត្រាវុធហ្នឹងគ្រាប់រំសេវ អញ្ចឹងវាមានច្រើនមុខព្រួញ មីងធ្លាប់ទៅកំពង់សោម អញ្ចឹងកំពង់សោមហ្នឹងវាមានកន្លែងគេស្តុក ដែលយើងទៅជិតដល់កំពង់សោមវាមានទួលមួយក្បែរប្រលានយន្តហោះហ្នឹងអ្នាស៎ ទួលទៅពីហ្នឹងទៅខាងស្តាំដៃហ្នឹង តែកាលមីងទៅលេងថ្ងៃមុនគេឆាយរាបហើយ កាលមីងនៅហ្នឹងទួលខ្ពស់តែឥឡូវគេឆាយរាប ។

សុជាៈ អាវុធហ្នឹងដឹកចេញ ដឹកចូលឃ្លាំង? មានដឹកចេញពីឃ្លាំងទេ?

នៅៈ ដឹកចូលៗមកភ្នំពេញទាំងអស់ ។ ដំបូងទេណា៎ ពី៧៥, ៧៦ អីហ្នឹងគឺពីក្រោមកចូលមកភ្នំពេញណែនហើយ ក្នុងហ្នឹងវាមានម្តុំទួលគោកហ្នឹង....ម្តុំទួលទំពូងម្តុំទឹកថ្លា ហើយសូម្បីតែគ្រាប់ដែលយើងស្តុកនៅម្តុំគេហៅវិហារចាម នៅគីឡូលេខ៦ហ្នឹងក៏យើងដឹកចូលមកក្នុងភ្នំពេញដែរ ។ អញ្ចឹងយើងដឹកចេញ ៣ច្រកដែលមីងដឹងធ្លាប់ទៅហ្នឹង កំពង់សោមមួយហើយពីក្រចេះ គឺយើងបែងចែកកំលាំងខ្លះទៅក្រចេះអីអញ្ចឹង កំលាំងខ្លះនៅភ្នំពេញហើយមីងធ្លាប់ចូលៗដល់កំពង់ឆ្នាំងគ្រាប់ហ្នឹងអាហ្នឹង មុនគ្រាប់សល់ពីសង្គ្រាមដែលគេស្តុនៅក្នុងព្រៃយើងទៅយកទៅគាស់ពីត្រង់សេ យើងប្រើពាក្យហ្នឹងយើងដឹកចូលមកភ្នំពេញ ។ គីរីរម្យក៏មីងធាប់ទៅដល់ដែរអញ្ចឹង តែយើងអត់ដឹងថាគ្រាប់ហ្នឹងវាចេញពីឆ្នាំណា វាមកពីចិន ឬក៏គ្រាប់ហ្នឹងស្តុកហើយ តែបើកំពង់ឆ្នាំងមីងច្បាស់ថាគ្រាប់ហ្នឹងគេស្តុកពី សង្គ្រាមហើយគេគាស់ចូលមកភ្នំពេញ តែវាមានច្រកពីរសំខាន់គឺក្រចេះហើយហ្នឹងកំពង់សោម ។

សុជាៈ ចុះគ្រាប់ហ្នឹងផលិតនៅឯណាដែរ?

នៅៈ ចិន ។

សុជាៈ អ! ចុះខុបមាថាវៃបានភ្នំពេញ រឺក៏ទីរួមខេត្តមួយៗវៃបានពីលន់ ណុលអីអញ្ចឹង វាត្រូវមានគ្រាប់សល់ពីពួកហ្នឹងមក ។

នៅៈ តែយើងរាបតាមប្រភេទ ឧទាហរណ៍ថាយើងអ្នកគ្រប់គ្រងនៅហ្នឹងយើងរាបដូចថា គ្រាប់អាកា គ្រាប់កាប៊ីន គ្រាប់ដេកា អាបេ អីអញ្ចឹងយើងរាបតាមប្រភេទ ។

សុជាៈ ចុះបោះៗ អាមេរិចកាំងមានទេ ដូចថាសល់ពី លន់ នល់ អីមក?

នៅៈ មាន ។

សុជាៈ មានដែរ?

នៅៈ ចា៎!

សុជាៈ អាហ្នឹងយើងប្រមូលទុកដែរ?

នៅៈ ចា៎! យើងប្រមូលទុកដែរ ។

សុជាៈ ដល់ពេលប្រមូលទុកអញ្ចឹងរបស់ចិន របស់អាមេរិចអីដាក់លាយគ្នាដែរអ្ហ៎?

នៅៈ អត់ទេ ។

សុជាៈ ដាក់ផ្សេង?

នៅៈ ព្រោះមីងចេះបារាំងខ្លះដែរ អញ្ចឹងឡាំងដែលគេបន្សល់ទុកហ្នឹងវាមានអក្សរបារាំងអញ្ចឹង បងប្អូនយើងដែលនៅក្នុងកងហ្នឹងភាគច្រើនមិនចេះអក្សរបារាំងទេ ចេះតែត្រឹមខ្មែរអីអញ្ចឹង យើងសរសេរទៅយើងថាអាឡាំងនេះ អាកាអីអញ្ចឹងទៅ យើងសេរសេរខ្មែរបិទផ្លាក ដូចជាយើងរាបតាមប្រភេទអីអញ្ចឹង ។

សុជាៈ បោះអាមេរិចកាំងសល់នៅក្នុងទាហានលន់ នល់ នៅក្នុងភ្នំពេញវិញច្រើនដែរទេ?

នៅៈ ច្រើន ។

សុជាៈ ច្រើនដែរ?

នៅៈ ចា៎! យើងមិនថាចោលនៅហ្នឹងទេ តែថ្ងៃក្រោយមកទៀតខ្ញុំមិនដឹងទេណា៎ ។ តែកាលដែលមីងនៅហ្នឹងប្រមូលមកទុកផ្ទុកនៅភ្នំពេញហ្នឹង ។

សុជាៈ ប្រហែលប៉ុន្មានឃ្លាំង?

នៅៈ តាមមីងដឹងនៅៗម្តុំទឹកផ្លាម៉ាកន្លែង ឃ្លាំធំម្តុំទឹកផ្លាស្គាល់ទេ?

សុជាៈ បាទ!

នៅៈ ហើយទួលទំពូងៗហ្នឹងក៏គ្រោះថ្នាក់ដែរព្រោះអាចមានគ្រាប់ខ្លះហ្នឹង បងប្អូនយើងកប់ចោល វាមានអាក្រឡុកមួយមានខឿន តែលឺថាគេធ្វើអីទេខ្ញុំមិនសូវដឹងទេ ហើយនៅម្តុំ ទួលគោក

សុជាៈ ទួលទំពូងនៅម្តុំកន្លែងណា? នៅខាងណាផ្សារ?

នៅៈ មីងមិនសូវចាំទេ ព្រោះមីងមិនចាប់អារម្មណ៍ មីងគ្រាន់តែជិះកាត់ហើយក្រឡេកទៅឃើញ កន្លែងហ្នឹងដូចជាមានគេមិនទាន់ធ្វើអីព្រោះគេខ្លាច វាជាសំបុកគ្រាប់ហើយនៅក្នុងដីហ្នឹង មានគេកប់ច្រើន បងប្អូនយើងកប់ច្រើនណាស់ ។

សុជាៈ កប់ជំនាន់អាពតហ្នឹង?

នៅៈ ចាំ!

សុជាៈ ចុះមីងរៀបការជាមួយប្តីមីងហ្នឹងធ្វើម៉េចទៅបានគាត់រៀបការជាមួយមីង គាត់ស្នើសុំទាក់ទងអីម៉េច?

នៅៈ អាហ្នឹងគេមានប្រធានគេប្រាប់ទៅ កាលការមីងហ្នឹងមានការបើគូ!

សុជាៈ បើគូ?

នៅៈ ចាំ!

សុជាៈ ការនៅអង្គភាពហ្នឹង?

នៅៈ ការនៅអង្គភាពហ្នឹង ។

សុជាៈ គាត់ស្នើតាមប្រធានមីងមក?

នៅៈ ចាំ! ហើយគេហៅយើងសួរទៅ អញ្ចឹងវាៗល្មមដល់ពេលដែលយើងត្រូវយកគ្រួសារហើយ ព្រោះថាយើងកាលហ្នឹងតាមមីងចាំប្រហែលជាអាយុ២៧ ។

សុជាៈ ២៧?

នៅៈ ចាំ! អញ្ចឹងបងប្តីខ្ញុំៗប្រហែលជាបងខ្ញុំម៉ាឆ្នាំ ២៨ ។

សុជាៈ អ្ហឹដល់ពេលការហើយគេឲ្យនៅជាមួយគ្នាណា?

នៅៈ នៅក្នុងអង្គភាពជាមួយគ្នា គ្រាន់តែថាកាលមីងការហ្នឹងដូចជាអត់បានសំរាកទេ ឧទាហរណ៍ថាការហើយថ្ងៃហ្នឹងអញ្ចឹងត្រូវដល់អាសម្ភារៈមកអញ្ចឹង យើងអត់មានបានសំរាកថានៅផ្ទះនៅអីទេ គឺត្រូវតែទៅធ្វើការអញ្ចឹង ។ យើងក៏មិនសុំគេ ហើយគេក៏មិនឲ្យច្បាប់យើងដែរ អញ្ចឹងដល់ពេលយើងទៅៗ ធម្មតា ប៉ុន្តែយើងអាចឆ្លងកាត់ផ្ទះដូចថាប្តីខ្ញុំអាចមកផ្ទះខ្ញុំបាន ខ្ញុំអាចទៅផ្ទះប្តីខ្ញុំបានដោយមិនមានបញ្ហាអីទេ ។ យើងដូចថាយើងនឹកគ្នាយើងចង់ទៅដេកផ្ទះខាងប្តីក៏ទៅៗ អញ្ចឹងអ្នកយាមហ្នឹងគេមិនឃាត់ឃាំងទេ យើងចេញចូលសេរី អញ្ចឹងខាងប្តីខ្ញុំមកកន្លែងខ្ញុំក៏មិនមានបញ្ហាអីដែរមកតាមចិត្ត ។

សុជាៈ ដល់ពេលមីងធ្វើការហ្នឹងដល់ពេលណាដែរ នៅឃ្លាំងហ្នឹង?

នោះ៖ អញ្ចឹងប្រហែលជា យើងៗគិតមើលឥឡូវយើងគិតថាខែ៧ខ្ញុំទៅនៅភ្នំពេញ ៧៥ណា៎ ៧៥ ហើយខែ មិនចាំខែទេគ្រាន់តែមីងចាំបានថាថ្ងៃដែលគេប្រកាសៗ បក្សកុំមុយនីស្ត ដូចថាចេញមុខអញ្ចឹងមីងមិនចាំដែរមីងគេបញ្ជូនទៅព្រៃស ។

សុជាៈ ៧៦?

នោះ៖ ៧៧ហើយ មីងទៅ ។

សុជាៈ ៧៧?

នោះ៖ ចា៎!

សុជាៈ មូលហេតុអីដែរមីង?

នោះ៖ មិនដឹងដែរ អញ្ចឹងគ្រាន់តែមីងដឹងបូងគេមិនបញ្ជូនទៅព្រៃសភ្លាមទេគេឲ្យយើងទៅគេហៅ ម្តុំព្រែកគ្នោត ម្តុំខាងព្រែកគ្នោតអ្នកស៎ នៅមុខវត្តក្រពើហាអ្នកស៎ ស្គាល់ទេ?

សុជាៈ ស្គាល់ ផ្ទះខ្ញុំនៅម្តុំហ្នឹង ។

នោះ៖ អញ្ចឹងអ្វើស គេជូនឡានយើងទៅ យើងទៅពីរនាក់ៗ មួយនៅស្វាយរៀងអ្នកស៎ ។

សុជាៈ តែអ្នកគ្រប់គ្រងឃុំងនៅ និយាយឲ្យចំអ្នកគ្រប់គ្រងឃុំងនៅហ្នឹងឈ្មោះអីគេ?

នោះ៖ រកនឹកបន្តិចសិន ឈ្មោះ ធឹម ។

សុជាៈ ប្រុស?

នោះ៖ ប្រុស ។

សុជាៈ នៅណាដែរស្រុកគេ?

នោះ៖ មិនដឹង អ្វីឈ្មោះពិគេមិនដឹងឈ្មោះអីទេយើងគ្រាន់តែដឹងគេប្រែ ។

សុជាៈ ដល់ពេលយើង មីងនៅហ្នឹងសេនាធិការសេនាធិការហ្នឹងមីងស្គាល់ឈ្មោះពីណាគេមេ?

នោះ៖ មីងស្គាល់ច្បាស់ សុន សេន កាលហ្នឹងគាត់នៅខាងក្រសួងការពារប្រទេសហ្នឹងយើងស្គាល់ ច្បាស់ ។

សុជាៈ ចុះក្រោម សុន សេន? ដែលពុគាណាគអី ចាន់ ចក្រីអីទេ?

នោះ៖ ចាន់ ចក្រី គាត់នៅខាងកងទ័ព ។

សុជាៈ កងពល? គាត់អត់បានឡើងដល់សេនាធិការទេ?

នោះ  មិនដឹងដែរ ។ ពិបាកណាស់ណា ពិបាកដឹងណាស់ណា ព្រោះយើងដឹងតែម៉ាប្រឡុកយើងទេណា៎ យើងមិនអាចសុីបសួរអ្នកនេះនៅណេះអ្នកនោះនៅណោះទេ អញ្ចឹងម៉ាប្លុកយើងហ្នឹងយើងដឹងតែម៉ាវង្វង់យើងហ្នឹងទេ ។

សុជា:  ដល់ពេលយើងរៀបចំកំលាំងអីនៅក្នុងអង្គភាពរបស់មីងហ្នឹង មីងថាក្រោយមកទៀតមានគេបញ្ជូនពីភូមិភាគផ្សេងទៀតមក តែមីងលែងនៅហ្នឹងហើយ មិនអញ្ចឹង?

នោះ  មីង១ គ្រាន់តែដឹងខុទាហរណ៍ថាពេលមីងជាប់គុកនៅព្រៃស អញ្ចឹងពួកអង្គភាពមីងវាទៅធ្វើការនៅហ្នឹង តែវាមិនមែនជាប់គុកដូចខ្ញុំទេណា៎ វាទៅធ្វើការហ្នឹងវាខ្សឹបប្រាប់ថាមានចំរុះច្រើនណាស់ពីនិរតីពីអីមកអញ្ចឹង ខ្ញុំថារឿងគេខ្ញុំមិនដឹងទេ តែវាខ្សឹបប្រាប់យើង ។

សុជា:  មីងយើងចាប់ផ្តើមទិតៀនម៉ិញខ្ញុំសួរមីងពីរឿងនៅ គេដកពីកន្លែងមីងធ្វើការនៅកន្លែងភស្តុភារយាមឃ្លាំងគ្រាប់ហ្នឹង ចុះមីងអ្នកដែលមកប្រាប់មីងថាមានគេផ្លាសមកពីភូមិភាគផ្សេង១ទៀតហ្នឹងអ្នកហ្នឹងឈ្មោះអីដែរ?

នោះ  មីងមិនចាំទេ ព្រោះកាលហ្នឹងគេដកមីងមកព្រៃសហ្នឹងគេដកតែមីងមួយទេណា៎ ព្រោះយុទ្ធនារីដែលនៅក្នុងកងហ្នឹងមិនមានអ្នកណាមកទេ ។

សុជា:  ចុះអ្នកដែលទៅប្រាប់មីងថាមានអ្នកមកផ្សេង?

នោះ  អ្នក១ ដែលនៅក្នុងកងហ្នឹងគេជួបមីងហ្នឹងគេជួបសំណេះសំណាលគ្នាលេងទៅ ។

សុជា:  មីងអត់ចាំឈ្មោះគេទេ?

នោះ  ចា៎! មិនចាំទេ ។

សុជា:  ហើយដល់ពេលមីងដកមកហ្នឹង ចុះគ្រួសារមីង?

នោះ  គ្រួសារមីងគេយកទៅមុនមីងហើយ ។ តែមុននឹងចូលមកដល់ព្រៃសហ្នឹងគេយកយើងទៅម៉ាកន្ទាក់ពីលើព្រៃសហ្នឹង ដូចថាមុនដល់ព្រៃសគេយកយើងទៅម្តុំ ច្បារអំពៅ ម្តុំគេហៅកន្លែងលត់ដំដែរ ។ គេឲ្យយើងទៅដាំដំណាំនៅហ្នឹង ប្តីខ្ញុំនៅហ្នឹង ដល់ហើយគេ បញ្ជូនយើងទៅជុំប្តីផ្សាហើយ គេដកចេញពីអង្គភាពមកហ្នឹងអ្នាស់អត់ទាន់ដល់ព្រៃសភ្លាម ទេណា៎ យើងទៅជួបជុំប្តីយើងបានប៉ុន្មានខែដែរបានគេដកប្តីខ្ញុំចេញទៅ យើងជូនឡើងឡាន ឡើងអីមកហ្នឹងធម្មតា ដល់បានពីរបីថ្ងៃក្រោយបានគេបញ្ជូនយើងមកតាមក្រោយ តែយើងមិន

ដឹងថាប្ដីយើងទៅណាទេ តែយើងដឹង ព្រោះយើងខស្សាហ៍ទទួលព័ត៌មានអ្នក ដែលយកទៅលត់ដំណឹងយើងអាចដឹងខ្លះហើយព័ត៌មានហ្នឹង អញ្ចឹងយើងចាប់ប្រយត័ខ្លួនហើយ ។

សុជាៈ ចុះប្ដីមីងមានដឹងថាគេដកពីមូលហេតុអីទេ?

នៅៈ ដឹង ព្រោះក្នុងហ្នឹងដឹងត្រង់ថា គាត់គ្រាន់តែខ្សឹបប្រាប់ខ្ញុំថា យើងប្រហែលជាមិនសុខទេ មិនសុខដោយសារកាលហ្នឹងគេចាប់ ធុច នៅតំបន់ខត្ដរហ្នឹងអ្ហាស់ ភូមិភាគខត្ដរហ្នឹងគេចាប់ គេថាគេចាប់ឈ្មោះ ធុច នៅខត្ដរហើយ អញ្ចឹងយើងនៅក្នុងខត្ដរហ្នឹង យើងចេញពីហ្នឹងមកក៏ប្រហែលជាមិនសុខដែរ អញ្ចឹងគ្រាន់តែប្ដីខ្ញុំប្រាប់ថាឲ្យយើងប្រយ័តខ្លួន ប្រយត្ន័ពាក្យប្រយ័ត្នសំដីអីអញ្ចឹង ។ តែបានប៉ុន្មានថ្ងៃក្រោយមកគេឲ្យប្ដីខ្ញុំទៅកន្លែងហ្នឹង ។

សុជាៈ ដូចមីងនិយាយប្រាប់ខ្ញុំថាគាត់នៅស្ពឺជីក្រែង, ចំការលើហ្នឹងនែ៎ គាត់មកពីខត្ដរអញ្ចឹង?

នៅៈ ចា៎! ហ្នឹងភូមិភាគខត្ដរណា៎ ។

សុជាៈ គាត់ឈ្មោះ មឿន ហ្នឹង?

នៅៈ ចា៎!

សុជាៈ អញ្ចឹងរឿងគាត់ហ្នឹងទាក់ទងជាមួយហ្នឹងរឿង ធុច នឹងរឿងគាអឿនប្រធានកងពល៣១០ នៅភូមិភាគខត្ដរហ្នឹង?

នៅៈ ចា៎! ហ្នឹងហើយគាត់នៅក្នុងកងពល៣១០ កាលពីមុនមិនទាន់ចូលមកភស្ដុភារជាមួយគ្នាហ្នឹងគាត់នៅកងពលហ្នឹងណា៎ ។

សុជាៈ ហើយកាលហ្នឹងមានដឹងរឿងថាមូលហេតុបានជាគេចាប់ ធុច, ចាប់?

នៅៈ មិនដឹងទេ គ្រាន់តែដឹងថាគេចាប់ ។

សុជាៈ ចាប់បានប៉ុន្មានបានគេចាប់ដកប្ដីមីង?

នៅៈ ប្រហែលជាម៉ាខែក្រោយ ។

សុជាៈ ម៉ាខែក្រោយ?

នៅៈ ចា៎!

សុជាៈ ចុះដល់ពេលគេដកមីងទៅ វាទាក់ទងនឹងប្ដីមីងដែរឬក៏វាមានទាកទងនឹងរឿងអីផ្សេងទៀត?

នៅៈ មិនដឹង ព្រោះយើងមិនដឹងថាយើងមានកំហុសអីបានគេបញ្ជូនយើងទៅព្រៃស តែមីងពេលដែលមីងមកជួបប្ដីមីងហ្នឹងគេហៅម៉ុំវត្ដកសាន្ដ១ ម៉ុំហ្នឹងគេដាំដំណាំច្រើន ហើយ

អន្លក់ភាពវាមានអន្លក់ភាពភស្តុភារហ្នឹងសំរាប់ផ្គត់ផ្គង់មក អ្នកនៅភ្នំពេញហ្នឹងណា៎ មីងចង់និយាយថាអ្នកនៅហ្នឹងគេដាំដំណាំ ដាំបន្លែអញ្ចឹងសំរាប់បេះបន្លែហ្នឹងសំរាប់ផ្គត់ផ្គង់អ្នកនៅភ្នំពេញហ្នឹងអ្នកស៎ ។ អញ្ចឹងគេឲ្យយើងទៅៗ ដាំដំណាំហ្នឹង ។

សុជាៈ នៅម្តុំណាហ្នឹង?

នៅៈ ម្តុំវត្តកំសាន្ត ។

សុជាៈ នៅខាងណាភ្នំពេញ?

នៅៈ នៅច្បារអំពៅ អាផ្លូវមួយតាមមាត់ទន្លេហ្នឹងទៅត្បូង ។

សុជាៈ ត្បូងព្រែកប្រាព្រែកអីហ្នឹង?

នៅៈ មិនដឹងទីណាទេ តាំងពីហ្នឹងមកមីងមិនដែលទៅដែរ តែគ្រាន់តែចាំផ្លូវ ។ ម្តុំហ្នឹងមានដៃម៉ាក់ប្រាងធំៗណាស់ ។

សុជាៈ អញ្ចឹងគេដកមីងអញ្ចឹង ។

នៅៈ ទៅដាំដំណាំ ។

សុជាៈ ទៅដាំដំណាំ ហើយគេចាប់ប្តីមីងទៅរៀនសូត្រ?

នៅៈ ទៅរៀន ។

សុជាៈ គេឲ្យទៅរៀន?

នៅៈ ចា៎! ម៉ាឡាន ហើយយើងក៏រៀបចំខោអាវ កាលហ្នឹងយើងចេញពីអន្លក់ភាពយើងទៅជុំគ្នាម៉ាសាហើយណា៎ ហើយយើងរៀបខោអាវឲ្យគាត់ហើយយើងជូនគាត់ឡើងឡាន នៅតាមផ្លូវអីអញ្ចឹងធម្មតា ។ តែគាត់ដឹងខ្លួនថាគាត់ប្រហែលជា គាត់និយាយថាប្រហែលជាគាត់ទៅជាប់គុកហើយ អញ្ចឹងគាត់តាំងចិត្តថាគាត់មិនរត់ទេកាលហ្នឹងយើងមានផ្ទៃពោះហើយ ផ្ទៃពោះ៨ខែជាង ហើយអញ្ចឹងគាត់ថាគាត់មិនរត់ទេបើរត់ខ្ញុំត្រូវស្លាប់ អញ្ចឹងគាត់ថាគាត់ទៅគាត់មិនរត់ទេ ដើម្បីជីវិតខ្ញុំហើយនិងកូន អញ្ចឹងទៅយូរដែរប្រហែជាម៉ាខែប្លុកកន្លះខែបានគេបញ្ជូនខ្ញុំទៅទៀត ដល់បញ្ជូនខ្ញុំទៅទៀតគេបញ្ជូនទៅតែពីរនាក់ទេឈ្មោះធឿន ស្រីដែរ ។

សុជាៈ ស្រីហ្នឹងគាត់មានគ្រួសារហើយនៅ?

នៅៈ មានហើយ ។

សុជាៈ គ្រួសារគាត់អ្នកខត្តរដែរ?

នៅៈ គ្រួសារគាត់អត់ដឹងនៅណាទេ តែដឹងថាគាត់មានផ្ទៃពោះដូចខ្ញុំអញ្ចឹងដែរប្រហែលខ្ញុំដែរ តែគាត់ផ្ទៃពោះច្រើនជាងខ្ញុំ ។ ដល់អញ្ចឹងទៅគេបញ្ជូនយើងទៅដល់ តែគេឲ្យស្រោមសំបុត្រយើងមួយ ឲ្យយើងកាន់រាងខ្លួនទៅ គេប្រគល់ឲ្យយើង ជូនដល់ហ្នឹងគេឲ្យយើង កាន់ស្រោមសំបុត្រហ្នឹងទៅកន្លែងហ្នឹង ។

សុជាៈ ទៅកន្លែងណា?

នៅៈ ទៅអាកន្លែងពេទ្យឆ្លូតនៅអាម្តុំព្រែកត្នោតហ្នឹង ទីចាត់ការគេនៅហ្នឹង ។

សុជាៈ អញ្ចឹងពេលដែលគេដកប្ដីមីងគេដកមីងទៅច្បារអំពៅទៅដាំបន្លែហើយនៅហ្នឹងបានប៉ុន្មានខែ?

នៅៈ ប្រហែលជាម៉ៅខែជាង ។

សុជាៈ ម៉ៅខែជាងអ្វី?

នៅៈ ជាពីខែចុះ ព្រោះនៅយូរដែរ ។

សុជាៈ អញ្ចឹងប្រហែលជា ៣ខែគេដកទៅគាខ្មៅទៀតហ្នឹង?

នៅៈ ចាំ! ប្រហែលជានៅហ្នឹង ២ខែហើយនៅហ្នឹងដាំដំណាំហ្នឹងប្រហែលជា២ខែ ។

សុជាៈ ចុះមីងអីដែលទៅជាមួយមីងដែលថាជាសេនាធិការ ខាងឃ្លាំងទៅគាត់ទៅជុំមីងនៅគាខ្មៅហ្នឹងដែរទេ?

នៅៈ ពីណាគេ?

សុជាៈ មីងអីមួយថាគេដកគាត់មានផ្ទៃពោះនោះ?

នៅៈ ជុំគ្នាតើ តែគាត់នៅខាងជួសជុលកាំភ្លើង អត់នៅក្រុមជាមួយខ្ញុំទេតែនៅក្នុងចង្ក្រមភស្តុភារហ្នឹងដែរ ។

សុជាៈ ចុះដល់ពេលគេដកទៅហ្នឹង គាត់ទៅដល់គាខ្មៅព្រៃសអីហ្នឹងជាមួយគ្នា?

នៅៈ ទៅជាមួយគ្នា ។ ទៅដាំដំណាំជាមួយគ្នាតែដល់ពេលគេដកទៅព្រៃសហ្នឹងជាមួយគ្នាដែរ ។

សុជាៈ ចុះមានដឹងថាគាត់ជាប់ពាក់ពន្ធ័រឿងអីទេ?

នៅៈ យើងគ្រាន់តែកាលហ្នឹងគេប្រាប់យើងថា ពេលដែលខ្ញុំទៅដល់ហ្នឹងខ្ញុំសួរថា តែយើងដឹងហើយដឹងថាកន្លែងហ្នឹងគេលត់ដុំហើយណាស់ យើងដឹងមុនហើយ ។ អញ្ចឹងយើងសួរគេថាហេតុអីបានជាបញ្ជូនខ្ញុំមកកន្លែងហ្នឹងអញ្ចឹង? ខ្ញុំសួរគេអញ្ចឹងថាហេតុអី? ខ្ញុំសួរមេប្រធាន

នៅហ្នឹង ស្រី ។ វាឆ្លើយប្រាប់ខ្ញុំថាមូលហេតុដែលគេបញ្ជូនមកកន្លែង ហ្នឹងគេយកមៅឲ្យលត់ដី ព្រោះយើងធ្លាប់នៅទីក្រុងណ៎ា គេថាអញ្ចឹង ។

សុជាៈ ចុះពីមុនដែលគេចាប់មីងមក មីងមានលឺឈ្មោះព្រៃសអីហ្នឹងដែរទេ?

នៅៈ ឮ ធ្លាប់ដឹងដែរ ។

សុជាៈ ចុះកន្លែង ដឹងថាកន្លែងហ្នឹងតែម្តង?

នៅៈ ចា៎! ដល់គេឲ្យយើងទៅហ្នឹងយើងដឹងខ្លួនហើយ ព្រោះយើងធ្លាប់បានចូលប្រជុំគេប្រាប់ថាកន្លែង ស២១ តែគេមិនប្រើពាក្យព្រៃសព្រៃអីទេកាលហ្នឹងអ្លាស៎ គេច្រើនប្រើ ពាក្យលេខ ។

សុជាៈ ស២១?

នៅៈ ចា៎!

សុជាៈ ចុះស្គាល់អាកន្លែងមួយទៀតបោះ ស២១ ហ្នឹង?

នៅៈ ស២១ វាមាន ខ្ញុំស្គាល់បានតែព្រៃស ហើយហ្នឹងកន្លែងស៊ឹងជ្រៅ កន្លែងក១៨ កន្លែងព្រៃកន្លោតហ្នឹង ស្គាល់បានពីរកន្លែងហ្នឹងទេ ។ ហើយមុំមួយទៀតគេហៅ បាគូ ស៊ឹងបាគូបីកន្លែងហ្នឹង ។

សុជាៈ ចុះទួលស្លែង?

នៅៈ ទួលស្លែងអត់ដឹង អត់ដែលស្គាល់ទេ ។

សុជាៈ អត់ដែលឮទេ?

នៅៈ ឮៗ តែយើងអត់ស្គាល់ គ្រាន់តែឮ ។

សុជាៈ ហើយវាទាក់ទងគ្នាដែរទេរឿងព្រៃស ហើយហ្នឹងទួលស្លែងហ្នឹង កាលឮហ្នឹង?

នៅៈ យើងៗ ដឹងថាព្រៃស ហើយហ្នឹងកន្លែងព្រៃកន្លោត និងស៊ឹងបាគូ វាជាសាខារបស់ ស២១ ។

សុជាៈ ទួលស្លែងហ្នឹង?

នៅៈ ចា៎! យើងគ្រាន់តែដឹង តែយើងអត់បានទៅដល់ទួលស្លែងទេ តែយើងដឹង ។

សុជាៈ វាខុសគ្នាម៉េចរឿងអ្នកទៅព្រៃស ទៅទួលស្លែង ទៅបាគូរ ទៅតាខ្មៅហ្នឹង?

នៅៈ វាតាមខ្ញុំដឹងប្រហែលជាទៅតាមកំរិតទោសដែលគេកំណត់ ។

សុជា៖ អាទោសណាដាក់នៅណា ៗ ?

នៅ៖ បើតាមខ្ញុំដឹងឧទាហរណ៍ដូច ក១៨ មុំស៊ីនបាគូ មុំស៊ីនជ្រៅ មុំមន្ទីរពេទ្យព្រែកត្នោតហ្នឹងវា គ្រាន់តែជាប់ការសង្ស័យមន្ទិល ជាប់ពាក់ព័ន្ធនិន្នាការពីអ្នកនេះពីអ្នកនោះមក សកម្មភាព យើងមិនធ្ងន់ធ្ងរដូចជានៅព្រៃសទេ បើនៅព្រៃសតែម្តងយើងធ្វើសកម្មភាព ប្រឆាំងគេ តែយើងនៅមុំដូចបាគូ ដូចស៊ីនជ្រៅគ្រាន់តែគេចាប់កសុតាងយើងមិនទាន់បាន គ្រាន់តែ សង្ស័យ គេយកយើងទៅដើម្បីស្រាវជ្រាវ តែមីងកាលហ្នឹងដូចជាមិនមាន អារម្មណ៍អី គ្រាន់តែយើងដឹងខ្លួនអញ្ចឹងយើងចាំថាយើងមិនគិតអីទេ យើងគិតតែធ្វើការឲ្យ គេទៅ ហើយយើងតែមីងកាលហ្នឹងមាត់ឆៅដែរ ។

សុជា៖ ឆៅម៉េចទៅ?

នៅ៖ មាត់ឆៅថាយើងមិនខ្លាច យើងដឹងថាស្អែកស្លាប់ហើយអញ្ចឹងថ្ងៃហ្នឹងនិយាយឲ្យអស់ចិត្ត ។

សុជា៖ និយាយថាម៉េច?

នៅ៖ យើងនិយាយប្រឆាំងតវ៉ាគេអ៊ីដែលគេនិយាយមកដែលគេប្រើមៅមិនសមរម្យ យើងត យើងប្រកែក ។

សុជា៖ មីងនិយាយនៅណា ពេលមីងនៅណា?

នៅ៖ ពេលមីងនៅ កាលហ្នឹងនៅៗអគ្គភាពហ្នឹងគេដាំសណ្តែកធ្វើចំការអ្លូវ ដាំសណ្តែកដាំពោត ដាំល្ពៅ ហើយនីមួយៗចំនួនគេឲ្យយើងស្ទូងអីអញ្ចឹង ។ អញ្ចឹងនៅក្នុងអគ្គភាពហ្នឹងសុទ្ធ តែ ស្រីៗអី ។

សុជា៖ នៅតាខ្មៅហ្នឹង? អ្វីនៅច្បារអំពៅ?

នៅ៖ នៅឯតាខ្មៅ.......គេហៅស៊ីនជ្រៅ ។ ស្គាល់ទេ? មុំហ្នឹងមុំស៊ីនហ្នឹងគេដាំចំការ តែនៅស៊ីន បាគូក្បែរព្រៃសហ្នឹងគេធ្វើស្រែ តែដំបូងមីងនៅដាំចំការ ។

សុជា៖ នៅដាំចំការហ្នឹងយូរទេ?

នៅ៖ ដូចជាមុនចាប់អារម្មណ៍ទេព្រោះការមីងនៅហ្នឹងវាពោះធំ តែមីងឆ្លងទន្លេនៅហ្នឹង ។

សុជា៖ អញ្ចឹងមីងទៅនៅកន្លែងតាខ្មៅហ្នឹងបានប៉ុន្មានខែដែរបានគេបញ្ជូនទៅព្រៃសចំ?

នៅ៖ ប្រហែលជា៦ខែព្រោះមីងទៅហ្នឹងមានផ្ទៃពោះ៥ខែ ហើយមីងឆ្លងទន្លេនៅហ្នឹង អញ្ចឹង យើងបានន័យថា៥ខែ ។

សុជាៈ ឆ្លងទន្លេនៅតាខ្មៅហ្នឹង?

នៅៈ អត់ទេ ឆ្លងនៅកន្លែងលត់ដំហ្នឹងតែម្តង វាមានពេទ្យឆ្មបវានៅហ្នឹងមួយ ។

សុជាៈ នៅណា នៅស្ទឹងបាគូហ្នឹង?

នៅៈ នៅស្ទឹងជ្រៅ អញ្ចឹងពេលមីងឆ្លងទន្លេបានកន្លះខែបានគេបញ្ជូនមីងទៅព្រៃស ។ អញ្ចឹងមីងមីងបីកូនកាត់វាលទៅហ្នស៎ អត់មានស្អីជូនទេណាយើងដើពីស្ទឹងជ្រៅកាត់វាលទៅព្រៃសហ្នឹងឆ្ងាយណាស់ណា៎ ។

សុជាៈ កាត់បីង?

នៅៈ ចា៎! អញ្ចឹងដល់ពេលទៅដល់ហ្នឹងតែ៣ថ្ងៃទេគេបញ្ជូនឲ្យមកវិញ ។

សុជាៈ ឲ្យមកណាវិញ?

នៅៈ ឲ្យមកស្ទឹងជ្រៅវិញ ។

សុជាៈ ធ្វើការនៅស្ទឹងជ្រៅហ្នឹង?

នៅៈ ចា៎! ស្ទឹងជ្រៅហ្នឹងមីងកូនបានម៉ាខែជាងហើង មីងគេឲ្យនៅមើលកុមារ ។

សុជាៈ នៅមើលកុមាររហូតដល់វៀតណាមចូល?

នៅៈ ទេដល់មើលកុមារហើយកូនយើងបានជាបីបួនខែ បានគេឲ្យយើងទៅធ្វើស្រែនៅស្ទឹងបាគូស្ទឹងបាគូនៅជិតព្រៃសហ្នឹងអ្ហាស៎ ។

សុជាៈ ហើយមានស្គាល់ទេប្រធានអគ្គភាពគេឈ្មោះអី?

នៅៈ ឈ្មោះ រី ។

សុជាៈ ឈ្មោះ រី?

នៅៈ ចា៎! ស្រី ។

សុជាៈ នៅណាដែរ រី ហ្នឹង?

នៅៈ នៅៗនិរតី កាលនៅហ្នឹងមីងស្គាល់ពេទ្យដែលនៅអគ្គភាពហ្នឹងឈ្មោះវ៉ាន់ ។ ពេទ្យហ្នឹងខ្វាក់ភ្នែកម្ខាង តែកាលហ្នឹងយើងនិយាយទៅថាផលយើងដែរណា៎ វាខស្បូនលួចទៅចាក់ថ្នាំឲ្យយើងក្នុងចំការអ្ហាស៎ ព្រោះថាមីងអត់សូវជាទេកាលហ្នឹង ព្រោះដៃយើងទើបតែត្រូវរបួសទើបតែជា អញ្ចឹងយើងមានតែដៃម្ខាងទេដៃហ្នឹងយើងអត់ទាន់ប្រើកាបានទេ អញ្ចឹងយើងទៅដកសំណាប់យើងក្តាប់សំណាបអត់ទាន់កើត ។ អញ្ចឹងវាឲ្យយើងចាំចំការ មើលកូន

ក្មេងអីអញ្ចឹង យើងមានប្រើការតែដៃម្ខាងអញ្ចឹងមិនអាចទៅស្ទូងដកបាន ដល់ពេលថ្ងៃក្រោយទៅដៃយើងក៏ធ្វើចលនាបានទៅវាឲ្យទៅធ្វើស្រែ ។

សុជា៖ ហើយអ្នក វ៉ាន់ ហ្នឹង ពេទ្យហ្នឹងគេចិត្តល្អជាមួយមីងដែរ?

នៅ៖ ចិត្តល្អណាស់ ដូចថាគេលួចទៅចាក់ថ្នាំនៅពេលដែលយើងទៅ រំពាត់មួយយើងដើមើលកុំឲ្យក្របីគោចូល ។

សុជា៖ នារី រី ហ្នឹងគ្រប់គ្រងនៅព្រៃស រឺនៅស្ទឹងជ្រៅ?

នៅ៖ អត់ទេនៅស្ទឹងជ្រៅ ។

សុជា៖ នៅស្ទឹងជ្រៃ ។ ចុះនៅព្រៃស?

នៅ៖ អត់ស្គាល់ ។

សុជា៖ មីងធ្វើស្រែរហូតដល់ពេលវៀតណាមចូលមក ឬក៏មានផ្លាស់ប្តូរអីទៀតដែរទេ?

នៅ៖ អត់ទេនៅព្រៃសហ្នឹង ។

សុជា៖ អត់ផាស់ទេ ធ្វើនៅហ្នឹងរហូតណ៎?

នៅ៖ រហូតដល់វៀតណាមចូល អញ្ចឹងកូនយើងស្លាប់ពេលដែលយើងទៅធ្វើនៅព្រៃស នៅម្តុំព្រៃសហ្នឹង តែយើងមិននៅក្នុងចង្កោមរង្វង់ព្រៃសទេ យើងនៅស្ទឹងបាគូផ្ទះដោយខ្លួន ។

សុជា៖ នៅហ្នឹងមូលហេតុអីបានកូនមីងស្លាប់?

នៅ៖ យើងបាននិយាយពីដំបូងហើយវាកើតកញ្ជ្រឹល ។ គេយកទៅដេកពេទ្យ វាអត់ឲ្យម៉ែ ទៅទេ ដល់ពេលបានបីថ្ងៃបាន ដូចថាកូនហ្នឹងលួងវាមិនស្ងៀមវាចេះតែយំអីអញ្ចឹង វាឲ្យយើងទៅវាមកយក ឃើញឡានវាមកយកយើងនៅតាមភ្លឺស្រែហ្នឹង ក៏យើងទៅចុះកូនហើយហ្នឹងម៉ែ ។ ដល់ពេលទៅយើងមិនបានចាប់អារម្មណ៍ថាវាលាប់វាជោ ដោះយើងព្រោះពេលដែលវាទៅហ្នឹងយើងចេះតែច្របាច់ទឹកដោះចោល ដើម្បីថ្ងៃ ណាមួយវានឹងបានជោវិញ ដល់ពេលវាជោទៅលាប ។

សុជា៖ លាប់កញ្ជ្រឹល?

នៅ៖ លាប់កញ្ជ្រឹល ។

សុជា៖ មើលយូទេបានស្លាប់?

នោះ៖ ទៅបានតែពីរថ្ងៃ ឧទាហរណ៍ពេលយើងទៅដល់យើងឃើញកូនមិនឲ្យជៅក្នាម មិនចាប់អារម្មណ៍ថាវាជៅដោះយើងលាប់ទេណា៎ តែអាកព្រឺលដែលវាកើតហ្នឹងវាហើរអស់ហើយ ។

សុជា៖ កូនមីងបានម៉ានខែដែរហើយ?

នោះ៖ ម៉ាខួប ។

សុជា៖ ក្នុងឆ្នាំ៧៨អីដែរ?

នោះ៖ ចា៎! ប្រហែលជាចុងឆ្នាំ ៧៨ ។

សុជា៖ មីងមានស្គាល់ប្រធានធំគ្រប់គ្រងនៅព្រៃសហ្នឹងទេ?

នោះ៖ អត់ស្គាល់ តែយើងស្គាល់តែ ឌុច យើងធ្លាប់ឃើញវាទៅហ្នឹង ។

សុជា៖ ឌុច ហ្នឹង?

នោះ៖ ចា៎!

សុជា៖ រាងម៉េចឌុចហ្នឹង?

នោះ៖ ឌុច ហ្នឹងយើងដឹងថាឈ្មោះឌុចអញ្ចឹងតែម្ដង យើងមិនដឹងថាឈ្មោះគេស្អីទៀតទេ យើងអត់ដឹងទេ ។

សុជា៖ ឌុច ។ ចឹបានគេទៅហ្នឹងមីង?

នោះ៖ គេទៅមើល ។

សុជា៖ គេប្រធានហ្នឹង?

នោះ៖ ចា៎! យើងមិនដឹងថាគេទៅធ្វើអីទេ តែគេទៅមើល ។

សុជា៖ រាងរៅមីងចំណាំបានទេរាងឌុចហ្នឹង?

នោះ៖ វាខ្មៅហើយខ្ពស់ ហើយមុខរាងជ្រុងកាលហ្នឹង ។

សុជា៖ ចឹបានមីងដឹងថាឈ្មោះគាត់ឈ្មោះឌុច?

នោះ៖ អ្នកនៅ ពេទ្យវ៉ាន់ហ្នឹងប្រាប់ខ្ញុំ ។

សុជា៖ ពេទ្យវ៉ាន់ហ្នឹង?

នោះ៖ ចា៎! គេថាហ្នឹងហើយប្រធាន ស២១ គេថាមេធំហើយ គេថាហ្នឹងមេធំ ។

សុជា៖ ពេលហ្នឹងមីងនៅចំងាយប៉ុន្មានមើលឃើញគាត់?

នៅៈ ពេលគេដើតាមភ្លឺស្រែ យើងនៅស្ងួន ។

សុជាៈ យើងស្ងួនជាប់ភ្លឺហ្នឹងដែរ?

នៅៈ ចាំ!

សុជាៈ គាត់មាននិយាយមានអីទេ?

នៅៈ អត់មាននិយាយទេ គ្រាន់តែដើមើលហើយទៅហួសទៅ តែដែលនៅហ្នឹងប្រាប់យើងតែពេទ្យហ្នឹងក៏ស្ងួនជាមួយយើងដែរ គ្រាន់តែថាមុខងារគេពេទ្យ ។

សុជាៈ ហើយដល់ពេលឌុចហ្នឹងទៅអីអញ្ចឹងគេមានទាហានមានអីទៅទេ?

នៅៈ អត់ឃើញទៅទេ តែម្នាក់ឯងទេ ។

សុជាៈ អត់មានអង្គរក្សអីការពារទេ?

នៅៈ អត់មានទេ អាហ្នឹងយើងនិយាយតាមជាក់ស្តែង តែឡានគេនៅឯឆ្ងាយហើយ តែមកស្រែហ្នឹងគេមានតែម្នាក់ឯងទេដើមក ។

សុជាៈ គាត់ខស្សរាហ៍មកទេ?

នៅៈ ខស្សរាមកដែរ ។

សុជាៈ មកប៉ុន្មានថ្ងៃ? មីងឃើញបានប៉ុន្មានដង?

នៅៈ ពេលមីងឃើញនៅឆ្នាំ៧៨ អាឆ្នាំទឹកធំហ្នឹងវាបាក់ទំនប់ស្ទឹងបាគូហ្នឹង ឃើញមកដូចជាមកបញ្ជាឲ្យទប់ឲ្យអីអញ្ចឹង ។

សុជាៈ គាត់មកនិយាយថាម៉េចខ្លះពេលមកបញ្ជាឲ្យទប់អញ្ចឹង?

នៅៈ កាលហ្នឹងកំលាំងនារីយើងមិនអាចទប់ទំនប់ហ្នឹងបាន ដូចថាចុះទឹកកំពង់តែហូរខ្លាំងអីអញ្ចឹងទៅយើងកំលាំងនារីមិនអាចបោះបង្គោលចុះកន្លែងបាក់ទឹកហ្នឹង វាហូរខ្លាំងមិនអាចចុះទៅបានអញ្ចឹងគេឲ្យកំលាំងប្រុសៗមកបោះស្នឹងហ្នឹងមកហើយ យើងកំលាំងនារីហ្នឹងយើងកែបដីហ្នឹងដាក់បាវទប់ដើម្បីទប់ទំនប់ហ្នឹង ឆ្នាំ៧៨ ។

សុជាៈ ចុះមីង ឌុច ហ្នឹហគេប្រធានធំអញ្ចឹងគេអត់មានថ្នាក់នៅក្រោមហ្នឹងដូចថា សាខារបស់ស២១ហ្នឹងវាមានច្រើនផ្នែអញ្ចឹង ផ្នែកដូចថានៅតាខ្មៅផង នៅព្រៃសផង នៅណាផងអញ្ចឹងឌុចហ្នឹងអ្នកគ្រប់គ្រងទាំងអស់ហ្នឹងតែម្តង ឬក៏គេមានចែកក្រុមគេផ្សេងៗទៀតដែរ?

នោះ៖ វាមានក្រុមហើយឧទាហរណ៍ដូច នាងរី ដែលប្រធាននៅស៊ីនជ្រោហ្នឹងគឺជាអ្នកនាំពាក្យ អ្នកមើលខុសត្រូវហើយ អញ្ចឹងគេមិនអាច ឌុចហ្នឹងមិនមែនមកគ្រប់គ្រងផ្ទាល់ទេ វាប្រយោលឧទាហរណ៍ថាយើងមានលំដាប់ថ្នាក់ប្រធានក្រុម ប្រធានកងអីអញ្ចឹង ។

សុជា៖ ឈ្មោះ រី ហ្នឹងគេនៅគ្រប់គ្រងរហូត អត់មានផ្លាស់ប្តូរអីទេ?

នោះ៖ អត់មានផ្លាស់ប្តូរអីទេ តាំងពីខ្ញុំទៅឃើញនៅហ្នឹង ។

សុជា៖ រហូតដល់បែកវៀតណាមចូលមក?

នោះ៖ ចាំ!

សុជា៖ ចុះដែលឮឈ្មោះ ហ៊ុយ រឺទេ?

នោះ៖ ឮដែរតែមិនស្គាល់ទេ ។

សុជា៖ មិនដែលឃើញទេ?

នោះ៖ មិនដែលឃើញទេ ធ្លាប់ឃើញតែឈ្មោះ ឌុច ហ្នឹង ។

សុជា៖ អញ្ចឹង ឌុច ហ្នឹងមីងឃើញបើគិតទៅប្រហែលម៉ានដង?

នោះ៖ ចុងក្រោយដែលខ្ញុំច្បាស់ហ្នឹង ខ្ញុំធ្លាប់ទទួលការសួរចម្លើយពី ឌុច នោះម្តង ។ ក្រោយពី ៧៩ ហើយយើងថ្ងៃ ៧មករាហ្នឹងយើងមិនវៀតណាមចូលភ្នំពេញហ្នឹង យប់ហ្នឹងយប់ថ្ងៃ ៧មករាហ្នឹងគេឲ្យយើងចេញ ចេញទៅទាំងអស់គ្នាជាមួយ អៀង សារី ជាមួយអីហ្នឹងទៅដើរ អ្នកនៅហ្នឹងគេដើរពីរភ្នំពេញមក ហើយយើងនៅហ្នឹងប្រមូលគ្នាយើងទៅពីៗកន្លែងហ្នឹងទៅតែម្តង តាមស៊ីនបាគូហ្នឹង អ្នកព្រៃសមកអីអញ្ចឹងទៅៗម៉ាខ្សែទៅរាប់ម៉ឺនរាប់ពាន់នាក់ណាំ យប់ យប់ថ្ងៃ៧ មករាហ្នឹងខ្ញុំគ្រាន់តែចាំតែប៉ុណ្ណឹងទេ ។

សុជា៖ ហើយ ឌុច សួរនាំម៉េចខ្លះ?

នោះ៖ យប់ហ្នឹងយើងមិនបានឃើញទេតែថ្ងៃក្រោយទេ បានយើងដឹងថាពួកមេធំៗទៅជាមួយយើងដែរ យើងដើរយប់យើងមិនអាចស្គាល់ទេ ។

សុជា៖ អត់បានសួរអីណាអ្វី?

នោះ៖ យប់ហ្នឹងយប់ដែលបានចេញយើងមិនដឹងថាអ្នកណាៗខ្លះទេ គ្រាន់តែដឹងថាភ្នំពេញគេវ៉ៃបែកហើយយើងត្រូវតែចេញទៅលិចអញ្ចឹងឧទាហរណ៍ ដល់ថ្ងៃក្រោយបានយើងដឹង តែយើងព្យាយាមរត់ចេញពីអគ្គភាពហ្នឹង តែយើងរត់មិនរួចៗ ដល់រត់មិនរួច ឧទាហរណ៍

យើងគេចចេញពីអង្គភាពហ្នឹងហើយគេចេះតែតាមទាន់ គេមានសេះពីរបីសំរាប់គៀង យើងឲ្យទៅជាមួយគេអញ្ចឹង តែយើងព្យាយាមរត់ដែរតែរត់វាមិរួច ដល់ពេលគេទាន់អញ្ចឹងគេហៅយើងទៅសួរ តែកាលហ្នឹងយើងព្រឹត្តិការណ៍ ៧៩រួចហើយ ។

សុជា: គាត់សួរ ឌុចហ្នឹងហៅទៅសួរ?

នៅ: ហៅទៅសួរនៅម្តុំ ម្តុំជិតឱរាល់, ថ្មពួក, ម្តុំភ្នំគេហៅភ្នំចារាយ ។ ស្គាល់មីង ស្គាល់ភ្នំចារាយហ្នឹងនៅស្រុកកំពង់ត្រឡាចលើ កំពង់ឆ្នាំង ។

សុជា: ចូលព្រៃហើយអាហ្នឹង?

នៅ: ចា៎! ចូលព្រៃហើយ តែគេហៅយើងទៅសួរដោយយើងរត់ចេញពីកង ។

សុជា: ឌុច ហ្នឹងអ្នកសួរផ្ទាល់?

នៅ: ចា៎!

សុជា: គាត់សួរថាម៉េចខ្លះ?

នៅ: គេសួរ តែយើងអត់ដឹងរឿងយើងមិនដឹងមានពាក្យអីឆ្លើយ វាគ្រាប់តែយកកាំភ្លើងខ្លីហើយយើងអង្គុយលើគ្រែយើងឈរក្បែរហ្នឹង វាយកកាំភ្លើងខ្លីដកពីចង្កេះមកហើយភ្ជុងត្រង់សៀតផ្កាយើងធ្វើដូចរបៀបកំញ៉ោញ យើងដឹងហើយ ។ ប៉ុន្តែវាសួរថា សួរឈ្មោះយើងហើយយើងក៏ប្រាប់វា វាថាមកនៅហ្នឹងប៉ុន្មានខែ ប៉ុន្មានថ្ងៃ ហើយខ្ញុំថា ពីរឆ្នាំហើយ យើងឆ្លើយថាខ្ញុំមកនៅហ្នឹងពីរឆ្នាំ ហើយវាបើកភ្នែក ម៉េចក៏នៅបានយូរមែស? ខ្ញុំថា ខ្ញុំដឹង? ហើយវាគ្រាន់តែចោទទៀតថាមិនដែលទេមិនដែលមានពីណា នៅយូរអញ្ចឹងទេ នៅតែម៉ាអាទិត្យអស់ហើយត្រូវបញ្ជូនទៅណាទៀត ។ ខ្ញុំថាខ្ញុំមិនដឹងខ្ញុំទៅ ណាទៀតបើគេមិនបញ្ជូនឲ្យខ្ញុំទៅណាទៀត? ហើយវាឆ្ងល់ថាហេតុអីបានមិត្តនារីឯងនៅ បានយូរមែស បានដល់ទៅ២ឆ្នាំ ។

សុជា: គាត់សួរមីងតែម្នាក់ឯងទេ?

នៅ: សួរតែម្នាក់ឯងទេ តែកាលហ្នឹងមីងដូចជាមិនតក់ស្លុតទេ ។ វាថាតាំងពីចេះសួរចម្លើយមិនដែលពីណាឆ្លើយសើចដាក់វាទេ «មិនដែលមិនដែលមានអ្នកឆ្លើយសើចដាក់ខ្ញុំទេទើបតែមិត្តនារីឯងមួយម៉េចក៏មិនតក់ស្លុត?» ខ្ញុំថាខ្ញុំមានរឿងអីតក់ស្លុតទេមិនដឹងមានរឿងអីផង ខ្ញុំឆ្លើយតាមត្រង់ព្រោះខ្ញុំមកហ្នឹងពីរឆ្នាំមែនតាំងពីរ៧៧ ខ្ញុំប្រាប់អញ្ចឹង ។

សុជាៈ អញ្ចឹងមូលហេតុដែលគាត់សួរយកទៅសួរហ្នឹងដោយសារមីងគេចចេញ?

នៅៈ ព្យាយាមរត់ចេញពីអង្គភាពហ្នឹងយើងដឹងហើយដើម្បីត្រឡប់មកផ្ទះវិញតែយើងរត់មិនរួច ។

សុជាៈ ចុះពីណាគេអ្នកទៅប្រាប់គាត់ឲ្យគាត់ហៅយកទៅសួរ?

នៅៈ ប្រធានកងហ្នឹងគេនៅគ្រប់គ្រងយើងរហូតណា៎ ។

សុជាៈ អញ្ចឹង?

នៅៈ ចា៎!

សុជាៈ នារី រី ហ្នឹងអ្នកទៅប្រាប់ឲ្យឌុចទៅសួរ?

នៅៈ ចា៎!

សុជាៈ គេមានឃោមមានអីទេពេលដែលសួរក្នុងព្រៃហ្នឹង?

នៅៈ ឃោម តែពេលដែលគេភ្ជុងយើង អាកាភ្ជុង អាកា៥៤ហ្នឹង កាំភ្លើងខ្លី តែមានអាកាបី ដើមភ្ជុងយើង លុតជង្គង់ភ្ជុងយើងរួចទៅហើយ តែមីងកាលហ្នឹងមានគំនិតមួយថា បើសិន ជាគ្មានអាកាភ្ជុងទេមីងយកកាំភ្លើងហ្នឹងបាញ់វិញហើយ តែមីងមិនអាចធ្វើបានទេ បើសិន ជាធ្វើយើងត្រូវងាប់ អញ្ចឹងយើងរក្សារជីវិតយើងដើម្បីរស់តទៅទៀតអញ្ចឹងយើង មិន អាចធ្វើបានទេ ។

សុជាៈ ចុះមីងថាមាន អៀង សារី មានអីមីងមានឃើញទេ?

នៅៈ យើងធ្លាប់ឃើញតែពេលនៅប្រជុំនៅអីភ្នំពេញកាលយើងមិនទាន់ទៅព្រៃស ។

សុជាៈ ប្រជុំនៅសេនាធិការកាលនៅសេនាធិការហ្នឹង?

នៅៈ ប្រជុំនៅស្តាតហ្នឹង ។ ប្រជុំកាលហ្នឹងដូចជាអាមេរិកវាទំលាក់គ្រាប់បែកនៅសៀមរាប ថ្កោលទោសអាមេរិចហ្នឹង ។

សុជាៈ មានអាមេរិកទំលាក់គ្រាប់បែកនៅសៀមរាបដែរ? ជំនាន់អាពតហ្នឹង?

នៅៈ ជំនាន់ ប្រហែលជាបែក៧៥ ហើយៗ ។

សុជាៈ នៅមានទំលក់នៅហ្នឹងទៀត?

នៅៈ ចា៎! មួង ។ ហើយយើងថ្កោលទោស ។

សុជាៈ ហើយ អៀង សារី អ្នកទៅនិយាយ ។

នៅៈ អៀង សារី, ប៉ុល ពត អីហ្នឹង ។

សុជាៈ អៀង សារី មាននិយាយដែរទេ?

នៅៈ មិនទេ តែកាលហ្នឹងខ្ញុំឃើញប៉ុលពតឡើងលើវេទិការហ្នឹងនិយាយហ្នឹង ហើយថ្ងៃដែលគេនិយាយទូលាយគេ និយាយពីបក្សពីអីហ្នឹងមិនចាំទេវាយូរឆ្នាំហើយ ។

សុជាៈ ចុះក្រៅពី អៀង សារី, ប៉ុល ពត អីមានស្គាល់ពីណាទៀតទេ មានឃើញខៀវសំផនទេ?

នៅៈ ឃើញ ។

សុជាៈ ឃើញខៀវ សំផន ដែរ?

នៅៈ ចាំ!

សុជាៈ ឃើញនៅណាដែរ?

នៅៈ ឃើញពេលដែលទៅប្រជុំ ។

សុជាៈ ប្រជុំនៅស្តាតហ្នឹង?

នៅៈ កាលហ្នឹងយើងមានសិទ្ធចូលប្រជុំជាមួយមេធំៗ គេហៅយើងទៅមុនយើង ពេលដែលយើងចូលទៅនៅភ្នំពេញដំបូងៗ ។

សុជាៈ ចុះឌុចហ្នឹងពេលដែលសួរចម្លើយមីងហើយគាត់អត់ធ្វើអីមីងទេ?

នៅៈ អត់ទេ ។

សុជាៈ គាត់គិតថាម៉េចបានជាគាត់ប្រលែងមីងមកវិញ?

នៅៈ ប្រលែងមកក៏មិនប្រលែងឲ្យយើងចេញទៅណាដែរ ឲ្យនៅក្នុងវង្វង់យើងហ្នឹងដដែល គ្រាន់តែគេមិនយកយើងទៅវ៉ៃចោល ទៅបាញ់ចោលអីទេ គ្រាន់តែហៅថាហេតុអីបានជាចង់គេចចេញពីអង្គភាព? ខ្ញុំថាវាគ្មានមូលហេតុអីដែលចង់គេចបើគ្រាប់នៅវឹតៗនៅលើក្បាលបើមិនឲ្យខ្ញុំក្រាបមិនឲ្យខ្ញុំរត់មិនឲ្យខ្ញុំលូនមិនឲ្យខ្ញុំពួន ធ្វើម៉េចអាណាទៅពាំងគ្រាប់ឈ្នះ ។

សុជាៈ គាត់មានសួរស្រុកកំណើតមីងនៅណាទេ?

នៅៈ មិនសួរទេ គ្រាន់តែសួរថាយើងមកកន្លែងហ្នឹងម៉ានថ្ងៃ ប៉ុន្មានខែអីអញ្ចឹង ។

សុជាៈ ធ្វើម៉េចបានមីងរត់ចេញមកវិញបាន?

នៅៈ មីងៗយូរណាស់ មីងទៅពេលហ្នឹងមីងនៅថ្មពួក-ស្រុកឱរាល់ហ្នឹង វាដូចថាគេវ៉ៃគ្នាកាន់តែខ្លាំងឡើងហើយយើងព្យាយាមគេចពីគ្រាប់ បែកពីគ្នាបន្តិចៗអញ្ចឹងទៅ បានយើងដាច់ទៅបាន គេនៅតែគៀរយើងចូលព្រៃ គិតទៅមីងនៅក្នុងព្រៃហ្នឹងបី បួន ខែ ។

សុជាៈ បានរត់ចេញមក?

នៅៈ បានៗមីងចេញមកដល់គិរីរម្យ គិតទៅនៅក្នុងព្រៃអត់មាអីស៊ី៣ខែ ។

សុជាៈ គិរីរម្យយើងកំពង់ស្ពឺហ្នឹង?

នៅៈ ហ្នឹងហើយភ្នំគិរីរម្យហ្នឹង ។

សុជាៈ ហើយបានជួបជាមួយវៀតណាមនៅហ្នឹង?

នៅៈ តែយើងវង្វេងក្នុងព្រៃហ្នឹង វាគ្មាននរណាមួយស្គាល់ផ្លូវយើងចេះតែវិលវល់នៅក្នុងព្រៃហ្នឹង ។

សុជាៈ ប៉ុន្មាននាក់?

នៅៈ ច្រើនរាប់រយ តែដល់យូៗទៅយើងបែកចេញពីគ្នាអស់ យើងសល់តែបីនាក់ ។

សុជាៈ បីនាក់ហ្នឹងបានមកដល់ផ្ទះដូចមីងដែរទេ?

នៅៈ មកដល់ផ្ទះវិញម្នាក់នៅស្វាយរៀងផាប់ៗនៅក្នុងព្រៃប្រុស អញ្ចឹងយើងរត់ចុះរត់ឡើងនៅសល់គ្នាតែបីអ្នកទេហើយម្នាក់ទៀតហ្នឹងម៉ៅដល់កំពង់ស្ពឺហ្នឹង គេមានអ្នកស្រុកគេសុំយកធ្វើជាកូនធម៌ទៅៗ ហើយយើងមកព្រៃវែងមក ។

សុជាៈ អញ្ចឹងប៉ុន្មានអ្នក ចុះពីរនាក់ទៀត?

នៅៈ ពីរអ្នកទៀត ម្នាក់ស្លាប់នៅក្នុងព្រៃ ។ នៅសល់ពីរនាក់ ។

សុជាៈ ហើយម្នាក់គេនៅកំពង់ស្ពឺទៅ ហើយមីងមកណេះមក?

នៅៈ ចា៎!

សុជាៈ មកដល់ឆ្នាំណាដែរម៉ៅដល់ហ្នឹង?

នៅៈ មកដល់ផ្ទះហ្នឹងក្រោយយើងចូលឆ្នាំហើយ ឆ្នាំ៨០, ៧៩, ៨០ បានមីងមកដក់ផ្ទះ ។ អញ្ចឹងមីងនៅឯព្រៃយូរដែរ ។

សុជាៈ ហើយមីងបានរៀបការនៅឆ្នាំណារៀបការម្តងទៀតហ្នឹង?

នៅៈ ប្រហែលជា៨៧ ។

សុជាៈ ៨៧?

នៅៈ ចា៎!

សុជាៈ មកដល់មីងធ្វើអីនៅផ្ទះហ្នឹង?

នៅៈ ធ្វើស្រែ ។

សុជាៈ នៅហ្នឹង?

នៅៈ អត់ទេ ខ្ញុំនៅព្រៃវែង ។

សុជាៈ នៅព្រៃវែងតែម្ដង?

នៅៈ ចា៎! ផ្ទះបងជីដូនមួយ ។

សុជាៈ ចុះមីងខ្ញុំសួរបកទៅក្រោយវិញកាលជំនាន់ធ្វើការនៅព្រៃស គេឲ្យធ្វើមួយថ្ងៃប៉ុន្មានពេល ទៅ?

នៅៈ ធ្វើស្រែ ពីព្រលឹមទល់ព្រលប់យើងសំរាកតែពេលហូបបាយ ។

សុជាៈ អញ្ចឹង?

នៅៈ ចា៎!

សុជាៈ ហើយដល់ពេលយប់មានទេ?

នៅៈ ពេលយប់យើងដេកៗ ផ្ទះអញ្ចឹងធម្មតាអញ្ចឹងតែគ្រាន់តែគេចាក់សោរ ។

សុជាៈ គេចាក់សោរ?

នៅៈ គេចាក់សោរហើយមុងដូចថាផ្ទះគេធំ១០ ឬក៏២០នាក់អីអញ្ចឹងទៅ ផ្ទះមួយនៅគ្នា ១០ ឬ២០នាក់អញ្ចឹងទៅតែមុងមួយៗម្នាក់អញ្ចឹងមក ។ មុងទល់ក្បាលទល់ជើងគ្នាអញ្ចឹងចង មុងទូចៗ ហើយគេនៅក្រោម ។

សុជាៈ គេណា? ពួកណា?

នៅៈ គេដែលនៅគ្រប់គ្រងហ្នឹងវានៅខាងក្រោម ។

សុជាៈ នៅធ្វើអី?

នៅៈ វានៅយាមយើង ហើយគេចាក់សោរទ្វា អញ្ចឹងយប់យើងមិនមានសិទ្ធិចុះដីទេ ។

សុជាៈ ចុះបើយើងបត់ដៃបត់ជើង?

នៅៈ កន្ថោរមួយៗម្នាក់នៅកន្លែងយើងហ្នឹង ។

សុជាៈ ចុងដើងយើងហ្នឹង?

នៅៈ ចុងដើងយើងហ្នឹង អាចមានពេលខ្វះកំពប់កន្ត្រោរក៏មាន ។

សុជាៈ ទៅលើពួកអ្នកនៅក្រោមហ្នឹងទៅ?

នៅៈ លើទៅ តែរនាបក្តារ ។

សុជាៈ ធ្វើម៉េចបើគេអត់ឲ្យយើងចុះហ្អីស? ខ្លាចយើងរត់ពេលយប់?

នៅៈ ចាំ! តែថ្ងៃពេលយើងទៅធ្វើការស្ទូងដកហ្នឹងក៏មានគេយាមដែរ ស្រីៗហ្នឹងវាកាន់កាំភ្លើង នៅលើភ្លឺហ្នឹងទ្រែតត្រួតនៅលើភ្លឺហ្នឹង ។

សុជាៈ ហើយបាយទឹកអីម៉េចទៅ?

នៅៈ បាយទឹក អឺ បាយទឹកកាលខ្ញុំនៅហ្នឹងមិនមានបញ្ហាអីទេយើងហូបគ្រប់គ្រាន់ណាំ ។

សុជាៈ ប៉ុន្មានពេលម៉ាថ្ងៃ?

នៅៈ បីពេល តែព្រឹកឡើងច្រើនហូបដំឡូងស្ងោរដំឡូងអីធម្មតា អាហារសំរ៉ន់ហ្នឹង ហូបហើយ បានយើងទៅស្ទូង ។

សុជាៈ ទៅដល់ហ្នឹងមានគេបង្រៀននយោបាយអីទេ ឌុចអីហ្នឹងដែលមកបង្រៀនទេ?

នៅៈ អត់ទេៗ ដឹងតែពីប្រើយើងតែម្តង អត់មានបង្រៀនអត់មានអប់រំនិយាយពីនេះពីនោះ អត់ទេ ។

សុជាៈ មីង បើនិយាយទៅដល់ព្រៃស ដល់តាខ្មៅអីអត់ដែលមានបានឡើងមកភ្នំពេញចូលរួមនៅ ស្តាតអីទេ?

នៅៈ អត់ទេៗចប់ហើយ ។

សុជាៈ ចុះកាលនៅស្តាតនៅអីហ្នឹង នៅសេនាធិការហ្នឹងខស្សារ៉ាហ៍ទៅ?

នៅៈ ខស្សារ៉ាហ៍ទៅ ។

សុជាៈ ហើយគេដែលហៅទៅទទួលភ្ញៀវទទួលអីទេ?

នៅៈ មិនដែលទេ ។

សុជាៈ អ៊ីជួបខៀវ សំផន ជួបអៀង សារី ជួបប៉ុល ពត ហ្នឹងច្រើនដែរទេ?

នៅៈ ពេលប្រជុំ ជួបពេលប្រជុំ ។

សុជាៈ ប្រជុំហ្នឹងម៉ាឆ្នាំប៉ុន្មានដង?

នោៈ វាមិនទៀងដែរខុសប្រាប់ហៅដែរតើ ។ ពេលមានកិច្ចការដែលគេដែលគេត្រូវផ្សព្វផ្សាយពីគោលការរបស់បក្សគេហ្នឹង គេហៅយើងគ្រាន់ទៅប្រាប់ទៅមូលហេតុដែលយើងធ្វើអញ្ចឹង ៗមកវិញអញ្ចេះៗអី តែយើងមិនមាននិយាយអីជជែក យើងមិនមានសិទ្ធអី ជជែកកែសំរួលអីក្នុងហ្នឹងទេ គ្រាន់តែយើងទៅស្តាប់គេ តែមីងមិនចាំទេ ។

សុជាៈ ប៉ុន្មានដងដែលបានចូលរួមទៅប្រជុំស្អាតហ្នឹង?

នោៈ មិនចាំទេព្រោះ ។

សុជាៈ ច្រើនជាងពីរដង រឺក៏បីដង?

នោៈ ច្រើន យើងនិយាយថាច្រើនអញ្ចឹងចុះព្រោះក្នុងហ្នឹងយើងនៅកន្លែងកស្តុភារហ្នឹងវាដឹងកិច្ចការហើយការគ្រប់គ្រងនារីនៅក្នុងក្រុមហ្នឹងដើម្បីឲ្យវាដំណើរការហ្នឹង គឺដូចថាបន្តិចហៅបន្តិចហៅខុទាហរណ៍អញ្ចឹង ។

សុជាៈ ហើយដល់ទៅជួប ខៀវ សំផន ជួបអៀង សារី អីហ្នឹងទៅញឹកញាប់ដែរ?

នោៈ ជួប ។

សុជាៈ ជួបម៉ានដង ជួបខៀវ សំផន អៀង សារី អីហ្នឹង?

នោៈ និយាយរឿងម៉ានដងមិនដឹងទេ តែដឹងថាបើប៉ុលពតខ្ញុំធ្លាប់ជួបម្តង ឃើញច្បាស់ម្តង ។

សុជាៈ ចុះមីងពេលដែលមីង គេចាប់ដកមីងទៅព្រៃសហ្នឹង មីងមានដឹងរឿងសភាពការអីនៅខាងតំបន់បូព៌ាយើងដែរទេ?

នោៈ ដឹង ។

សុជាៈ ដឹងដែរ?

នោៈ ដឹង ។

សុជាៈ ដឹងថម៉េចដែរ?

នោៈ ដឹងថាគេចាប់ៗ រិត កសាងកំលាំងមូលដ្ឋាននៅសហករណ៍ អញ្ចឹងបើសិនជាអ្នកណាមនការពាក់ព័ន្ធនិន្នាការមិនល្អហ្នឹងប្រហែលជាមិនសុខ ។

សុជាៈ ចុះទៅដល់នៅព្រៃសហ្នឹង រី អី ឌុច អីមាននិយាយអំពីរឿងអ្នកដែលចេញប្រភពពីបូព៌ាទេ?

នោៈ អត់និយាយទេ ។

សុជាៈ អត់និយាយទេ ។

នៅៈ ចា៎! យើងដឹងខ្លួនយើងកាលដែលយើងមិនទាន់ចូលព្រៃស ដែលយើងធ្លាប់ឆ្លងកាត់ការប្រជុំជាមួយមេធំៗ ជាមួយអង្គភាពធំៗដែលយើងពិភាក្សាគ្នាទៅយើងដឹងតាមហ្នឹងទេ ។

សុជាៈ អ! អញ្ចឹងព្រៃស រឿងតំបន់បូព៌ានេះកើតរឿងមុនពេលដែលគេចាប់ប្ដីមីងទៀត?

នៅៈ ចា៎!

សុជាៈ មុន ឬក្រោយ?

នៅៈ ព្រោះដល់ពេលឆ្នាំ ៧៧ ដើមឆ្នាំ ៧៧ហ្នឹងគេចាប់តាមដានប្រវត្តិរូប ចាប់តាមដានប្រវត្តិរូប ហើយដំបូងមីងមានឈ្មោះថាមកតាមដានប្រវត្តិរូប តាមផ្ទះអីអញ្ចឹងតែដល់ក្រោយមកប្រាប់ថា ដូរឈ្មោះហើយឲ្យអ្នកផ្សេង ។

សុជាៈ ចុះមីងបានចុះមកទេ?

នៅៈ ចាស៎! មីងអត់បានទេ ។ អញ្ចឹងមីងចាប់ដឹងថាប្រហែលជាមានបញ្ហាអីហើយ នៅឯផ្ទះខ្ញុំអ្នក អញ្ចឹងយើងអាចដឹងហើយ អញ្ចឹងយើងដឹងៗថាឈ្មោះណាមួយដែលត្រូវទៅតាមដានប្រវត្តិរូបនោះយើងទៅខ្សឹបអ្នកនោះថា បើទៅដល់បូព៌ា ធ្វើម៉េចទៅដល់ផ្ទះខ្ញុំសួរសុខទុក្ខ អ្នកផ្ទះខ្ញុំឲ្យដឹង រួចមកប្រាប់ខ្ញុំផង ខ្សឹបៗ ។

សុជាៈ ហើយគេមកប្រាប់ម៉េចដែរ?

នៅៈ ពេលដែលគេដឹងអញ្ចឹងគេមកវិញគេមកខ្សឹបប្រាប់ខ្ញុំ ចុះធម្មតាយើងកាលហ្នឹងគេអត់ទាន់ចាប់អារម្មណ៍យើងប៉ុន្មានទេណា៎ តែយើងដឹងដែនការមុនយើងប្រាប់អ្នកដែលទៅតាមដានប្រវត្តិរូបឲ្យគេប្រាប់យើងផង ។

សុជាៈ គេប្រាប់ថាម៉េចទៅ?

នៅៈ គេៗប្រាប់ថាគ្រួសារយើងនៅឯផ្ទះពិបាកណាស់ នៅតតាមសហករណ៍ហ្នឹង ហើយវាពាក់ព័ន្ធ បើផ្ទាល់ខ្លួនខ្ញុំវាពាក់ព័ន្ធត្រង់ប្ដីបងខ្ញុំ បងស្រីខ្ញុំ ដែលគាត់នៅដេរកន្លែងតំបន់គាត់មានប្ដីមកពីហាណូយ អញ្ចឹងគេចាប់ប្ដីបងខ្ញុំហ្នឹងទៅ អញ្ចឹងវាជាប់ពាក់ព័ន្ធអញ្ចឹងហើយទីមួយ ទីពីរយើងធ្លាប់នៅក្រុង តែយើងទៅជាច់យូរហើយយើងអត់ ដឹងទេ ។

សុជាៈ អញ្ចឹងការដកមីងពីរឿងពីភស្តុភារម៉ៅព្រៃស មកពីតាខ្មៅមកអីហ្នឹងវាជាប់ទាក់ទងរឿងគ្រួសារមីងនៅឯស្រុកនេះ ឬក៏ជាមួយប្ដីមីងដែលគាត់ខាងខត្តរនេះ?

នៅៈ តាមៗដឹងប្រហែលជាពាក់ព័ន្ធរឿងគ្រួសារខ្ញុំច្រើនជាងប្តី ព្រោះប្តីរឿងគេផ្សេងណា៎ ហើយដកយើងហ្នឹងរឿងផ្សេង ទីមួយមកពីយើងមានបងថ្លៃជាអ្នកមកពីហាណូយ ដែលកាលហ្នឹងគេមិនប្រកាន់ថា អ្នកមកពីក្រោមកពីហាណូយអីអញ្ចឹង យើងមិនដឹងប្រវត្តិគេម៉េចៗទេ ហើយទីពីរកាលដែលមីងនៅអង្គភាពស៨០ហ្នឹង មីងប្រឆាំងគេម្តង ត្រង់ភ្លើងឆេះម្តុំលូទួលគោក ហើយភ្លើងឆេះហ្នឹងមិនដឹងជាមកពីណាទេ ហើយឃ្លាំងប្រេង ត្រង់កែងហ្នឹងវាមានប្រេងមួយ ហើយវាឆេះហើយឆេះម្តុំហ្នឹងសុទ្ធតែគ្រាប់ ហើយអញ្ចឹងដល់ពេលយើងតាមស្អិតសួរនាំហ្នឹងមានអ្នកមេយើងហ្នឹង មេអង្គភាពយើងហ្នឹង ជិះឡានតាមហ្នឹងគេឃើញថាគាត់ហ្នឹងបោះកន្ទុយបារី តែយើងថាភ្លើងហ្នឹងមានអ្នកបោះ កន្ទុយបារីទៅបានជាភ្លើងហ្នឹងវាឆេះ តែវាមិនទាន់ឆេះដល់ឃ្លាំងទេ វាទើបតែឆេះសំរាម តាមប្រឡាយតែយើងពន្លត់ទាន់ៗ

សុជាៈ ហើយមីងជដែក ហើយរាយការណ៍ប្រាប់អញ្ចឹងទៅ?

នៅៈ ចា៎! យើងតាមអញ្ចឹងទៅ វាថាយើងតាមដានប្រវត្តិវា អញ្ចឹងយើងៗ

សុជាៈ គេហ្នឹងធំជាងមីង? ឈ្មោះអីគេមីង?

នៅៈ ឈ្មោះ ធីម ខ្ញុំថាមុិញហ្នឹងៗ អញ្ចឹងពេលដែលយើងជដែកថាមិនមានអ្នកមកពីណាទេតាមព័ត៌មាន យើងប្រាប់ត្រង់ៗថាបងអែងហ្នឹងបោះកន្ទុយបារីទៅបានវាឆេះ វាគ្មាននរណាលួចដុតទេៗ អ្នកដែលបោះទៅក៏មិនចាប់អារម្មណ៍ថាវាគ្រាន់តែបោះទៅវាឆេះនោះទេៗ កាលហ្នឹងបើមិនពន្លត់ទាន់ទេអាចឆេះនៅតែបន្តិចទៀតដល់ឃ្លាំងគ្រាប់ អាវំសេវគេអិនគេវាល្មោភឆេះណាស់ណា៎ តែអត់អីទេ បើសិនជាឆេះផ្ទុះភ្នំពេញហ្នឹង មិនចាំបាច់អាណាវ៉ៃទេៗ

សុជាៈ ចុះកាលហ្នឹងគេចាប់ មានដឹងរឿងគេចាប់ សោ ភីម, ចាប់ ចាន់ ចក្រី ចាប់អីទេ?

នៅៈ ដឹង គេឱ្យឹបប្រាប់ៗ

សុជាៈ កាលហ្នឹងគេចាប់ ខាងចាន់ ចក្រី ខាងអីខាងសោ ភីម ហ្នឹងគេចាប់មុន ខាងសោ ភីមហ្នឹងគេចាប់មុនចាប់រឿងធុចអីហ្នឹងឬក៏ក្រោយ?

នៅៈ មិនចាំទេ មិនដឹងថាពីណាចាប់មុនពីណាចាប់ក្រោយទេ តែគ្រាន់ថាគេឱ្យឹបប្រាប់ថា តាភីម បាត់ខ្លួន ចាន់ ចក្រី បាត់ខ្លួន តាធុចភូមិភាគឧត្តរបាត់ខ្លួនតែយើងមិនដេញដោលមូល

ហេតុអីទេ ព្រោះយើងមិនមាន ដូចថាកាដលហ្នឹងយើងមិនមានសិទ្ធអីដដែករកបុសរកគល់ទេព្រោះយើងការពារខ្លួនយើងដែរ ។

សុជាៈ ហើយមិនដឹងដឹងថានរណាមុននរណាក្រោយអត់ទេ?

នៅៈ ចា៎! អត់ទេ មិនដឹងទេមិនចាប់អារម្មណ៍ ។

សុជាៈ តែពេលដែលគេចាប់ប្ដីមីងហ្នឹង សោ ភឹម គេចាប់ហើយឬនៅ?

នៅៈ គេចាប់ហើយ ចា៎! គេចាប់ហើយ ៗកាលហ្នឹងគេនៅតាមដានប្រវត្តិរូបយុទ្ធជន យុទ្ធនារីនៅតាមអង្គភាពមួយៗ គេមានក្រុមគេទៅតាមដល់ៗផ្ទះអីអញ្ចឹង អ្នកណាជាប់ពាក់ព័ន្ធអីអញ្ចឹងគេមកវាយការហើយ ។

សុជាៈ ចុះបងថ្លៃមីងដែលមកពីវៀតណាមហ្នឹងគាត់ឈ្មោះអីគេ?

នៅៈ មិនចាំឈ្មោះទេ ។

សុជាៈ បងស្រីមីងឈ្មោះអី?

នៅៈ បងស្រីខ្ញុំឈ្មោះ ជា ។

សុជាៈ ហើយប្ដីគាត់ធ្វើថ្នាក់អី?

នៅៈ ក្នុងហ្នឹងវានៅក្នុងចង្កោមគណៈតំបន់២០ហ្នឹង តែយើងនិយាយថាគណៈអញ្ចឹងវាមានលេខា វាមានអនុ វាមានសមាជិកអញ្ចឹង តែគាត់មិនមែនលេខាទេ នៅក្នុងអចិន្ត្រៃយ៍ហ្នឹង ។

សុជាៈ មីងកាលជំនាន់ហ្នឹងមីងមានដែលឃើញគេសម្លាប់មនុស្សផ្ទាល់ភ្នែកអីទេ?

នៅៈ មីងមិនដែលឃើញទេ ។

សុជាៈ អត់ដែលឃើញទេ ។ ចុះដែលឃើញគេធ្វើទារុណកម្មមនុស្សទេ?

នៅៈ កាលមីងនៅស៊ឹងជ្រៅហ្នឹងមីងគ្រាន់តែដឹងថាអ្នកដែលទៅនៅស៊ឹងជ្រៅហ្នឹង អស់ហើយ១០ថ្ងៃត្រូវបាត់ខ្លួន ។ មីងជួបមនុស្សថ្មីមករហូត ។

សុជាៈ ចុះមានដែលដើរទៅឃើញរណ្ដៅសាកសព ឃើញខ្មោចឃើញអីទេ?

នៅៈ អត់ដែលឃើញទេ គ្រាន់តែឃើញគេតំរង់ជួរយកឡើងឡានហ្នឹងមីងធ្លាប់ឃើញ ។ ហើយអ្នកដែលឡើងឡានទៅហ្នឹងមីងខ្សឹបសួរថាទៅណា កាលនៅស៊ឹងជ្រៅដល់បាន១០ថ្ងៃ ឡានមកយកម្ដងអីអញ្ចឹងទៅហើយខ្ញុំខ្សឹបសួរពេទ្យគេបញ្ជូនទៅណា គេថាទៅអូរខ្វេះ ។ អូរខ្វេះ

នៅណាមិនដឹងផងហ្នឹង គេថានៅម្តុំភ្នំស្រួចឯណាណោះមិនដែលស្គាល់ព្ទុតែឈ្មោះ ហើយខ្ញុំសួរថាទៅធ្វើអីហើយអ្នកហ្នឹងគ្រវីក្បាលមិនប្រាប់យើងទេ តែមើងធ្លាប់ឃើញគេ ។ ឧទាហរណ៍ថាឡានគេដាក់នៅមុខពេទ្យ ។

សុជាៈ គេបញ្ជូនមនុស្សឡើងឡានហ្នឹង?

នៅៈ ចា៎! ដើរទៅទាំងខ្សែ ។

សុជាៈ គេអត់មានចាប់ចងចាប់អីទេ?

នៅៈ អត់ទេគេបណ្តើរ ។

សុជាៈ បណ្តើរយកទៅ?

នៅៈ ចា៎! តែស្រីៗ ។

សុជាៈ ហើយមានៗមនុស្សអ្នកដែលមកហ្នឹងគេទាហានគេមានកាំភ្លើងអីទេ?

នៅៈ អត់ទេ ។

សុជាៈ អត់ទេ?

នៅៈ ចា៎! តែឡានគេនៅទីនោះទេយើងអត់ឃើញទេ អញ្ចឹងខ្ញុំសួរថាពួកប៉ុន្មាននាក់ហ្នឹងទៅបានអីទៅ គេថានោះឡាននៅឯថ្នល់ណែកអញ្ចឹងអ្នាស់ នៅមុខវត្តអ្នក ។

សុជាៈ ចុះទៅអាកន្លែងព្រៃសហ្នឹងមានដែលឃើញឡានគេទៅហៅមនុស្សពីស្រែមកទេ?

នៅៈ ឃើញ ។

សុជាៈ ឃើញដែរ?

នៅៈ ខ្ញុំធ្លាប់គេហៅឡើងឡានពីរដងដែរ ។

សុជាៈ អ្នាកមើលនិយាយបន្តិចមើ ឡើងឡានហើយម៉េចក៏រួចខ្លួនមក?

នៅៈ មិនដឹងម៉េច ដឹងជាវាម៉េច ឧទាហរណ៍ថាយើងកំពង់តែស្ទូង! កំពុងតែដកថ្ងៃហ្នឹង កំពុងតែដកហើយធម្មតាយើងដកដីស្រុកហ្នឹងវាជាប់ យើងមួរជើងខោវាប្រឡាក់ស្រម៉ុកអីអញ្ចឹងគេបក់ដៃហៅឈ្មោះយើងមក យើងហើយខ្ញុំថាលាងខ្លួនសិនអ្ហី? គេថាមិនបាច់ទេអញ្ចឹង ប្រឡាកឡានហើយណា៎ ប្រឡាក់ៗទៅគង់តែគេលាងទេ អញ្ចឹងពេលដែលយើងទៅដល់កន្លែងឡានហ្នឹងគេមិនឲ្យយើងថយក្រោយទៅលាងខ្លួនទៅ លាងដីចេញទេ គេឲ្យយើងឡើងទាំងដីទៅលើឡានហើយយើងប្រកែក បើគេមិនឲ្យយើង ក៏សុខចិត្តឡើងទៅអង្គុយ

លើឡានដែរ តែគេមិនឲ្យមកលាងខ្លួនទេ យើងថាសុំគេទៅលាង ខ្លួនសិនទេប្រឡាក់ឡានអស់ហើយ ដល់អញ្ចឹងពេលដែលយើងឡើងទៅអង្គុយលើឡានហ្នឹង ស្រាប់តែពេទ្យវ៉ាន់ហ្នឹងពេទ្យដែកចំណាំលួចចាក់ថ្នាំឲ្យខ្ញុំហ្នឹងវា ស៊ីញ៉ូដៃថាន្នកបងនោះចុះមកវិញ ប្រទ្បុំត្រកូលទេមិនមែនត្រកូលបងឯងទេ ។ ដល់អញ្ចឹងទៅក៏ចុះទៅក៏ហីទៅ ។

សុជាៈ ពីរដងចុះម្តងទៀត?

នៅៈ ម្តងទៀតក៏អញ្ចឹងដែរ ។ នៅតែប្រទ្បុំត្រកូលដូចគ្នា ។

សុជាៈ អញ្ចឹងអានាកមកយកនិងពេទ្យវ៉ាន់ហ្នឹងមានទំនាក់ទំនងអីនឹងគ្នាដែរជាមួយពេទ្យហ្នឹង?

នៅៈ មិនដឹងដែរ ឧទាហរណ៍កាលដែលយើងព្រឹត្តិការណ៍៧៩បែកភ្នំពេញហើយហ្នឹង អាឌុចហ្នឹងវាហៅយើងទៅសួរចម្លើយហ្នឹង កាលហ្នឹងយើងព្យាយាមរត់ដែរតែរត់មិនរួចវាហៅយើងទៅសួរ ។ មុិញខ្ញុំចង់និយាយពីអីទេភ្លេចហើង?

សុជាៈ ចង់និយាយពីរឿងពេទ្យ វ៉ាន់ ។

នៅៈ តែពេល១ ដែលកាលហ្នឹងយើងប្រើពាក្យថានីរសារ នីរសារហ្នឹងមានសេះមួយ ចៃដន្យអីអានីរសារហ្នឹងវាស្គាល់ខ្ញុំកាលពីសង្គ្រាមត្រៀមសមរភូមិ ស្រាប់វាវគ្គអ៊ើថា អ្នកបងទេខ្ញុំថាមិនបាច់អ្នកអីទេទៅណា វាថាទៅណាកគេឲ្យមកនាំបងឯងទៅមេធំ វាថា បងឯងកុំចង់នៅកន្លែងដហ្នឹងគ្មានអីហូបទេ ទៅកន្លែងខ្ញុំមិនខ្វះទេ ខ្ញុំថាអ៊ើមិនបាច់ភូតបងទេ អូនអ្ហើយខ្ញុំថាមិនបាច់ភូតទេ ដល់ហៅវាហៅខ្ញុំជិះសេះខ្ញុំថាមិនចេះជិះទេសុខចិត្តដើរ ដើរឆ្ងាយដើរជិនម៉ោព្រឹកបានដល់កន្លែងវាហ្នឹង ។

សុជាៈ ចុះវ៉ាន់ហ្នឹងមានជួបគ្នាទៀតទេ?

នៅៈ លែងជួបគ្នាហើយដល់យើងដាច់ទៅ ។

សុជាៈ ហើយវ៉ាន់ហ្នឹងហើយនឹងអ្នកដែលមកចាប់ វ៉ាន់ហ្នឹងគាត់មានតួនាទីជាពេទ្យហ្នឹងធំដែររឺនៅក្នុងអង្គភាព?

នៅៈ ទេខ្ញុំឃើញគាត់ទៅសួងទៅដកជាមួយយើងដែរស្ពាយថ្នាំពេទ្យ ។

សុជាៈ ចុះត្រង់ដែលគាត់ហៅឡើងមក ហៅចុះមកនោះ?

នៅៈ តែខ្ញុំគ្រាន់តែបញ្ឈាក់មើលត្រកូលហើយថាមិនមែនត្រកូលហ្នឹងទេ តែយើងមិនដែលទៅជិតស្និតសួរនាំអីទេ គ្រាន់តែថាដូចថាមានចិត្តមួយអាណិតយើងអីអញ្ចឹង ។

សុជាៈ ប្រុសអ្នែស គាត់ប្រុស?

នៅៈ ស្រីទេ ។

សុជាៈ មីងបានឆ្លងកាត់របបខ្មែរក្រហមមីងយល់ថារបបហ្នឹងយ៉ាងម៉េចដែរ?

នៅៈ ខ្ញុំនិយាយថាបើសិនជាគេអនុវត្តតាមទ្រឹស្តីហ្នឹងខ្ញុំថាល្អដែរ តែដល់ពេលហើយអាទ្រឹស្តីហ្នឹងនិយាយផ្សេង ដល់អាពេលធ្វើហ្នឹងវាផ្សេងវាមិនដូចគ្នា អញ្ចឹងអាពាក្យប្រជាធិបតេយ្យហ្នឹងវា ។

សុជាៈ វាខុស?

នៅៈ វាខុស ដល់ពេលធ្វើវាមិនរឿងអញ្ចុងទេ មិនរឿងតាមពាក្យនៅតាមឯកសារហ្នឹងទេ ។

សុជាៈ ចុះមីងតាមគំនិតមីងមកដល់ឥឡូវ ដូចថាពីមុនមកមីងយើងស្ម័គ្រចិត្តចូលបដិវត្តន៍ ចូលអីអញ្ចឹងហើយដល់ពេលក្រោយមក បដិវត្តន៍ហ្នឹងមានបានជួយយើងដែរទេ ដូចថាសំលាប់បងប្អូនគ្រួសារយើងទៀត អញ្ចឹងមីងគិតថាមានវិប្បដិសារីអីទេដែលបានចូលរួម ហើយចុងក្រោយវាអត់បានលទ្ធផលអីល្អ មកយើងវិញ ។

នៅៈ ខ្ញុំមានអារម្មណ៍មួយ គ្រាន់តែឮពាក្យថាបក្សហ្នឹងខ្ញុំណាយខ្ញុំស្អប់ ។

សុជាៈ ឥឡូវហ្នឹង?

នៅៈ តែឥឡូវហ្នឹងខ្ញុំអត់មានចូលបក្សណាទេ ក្នុងសង្គមខ្ញុំរស់ជាមួយគេតែខ្ញុំមិនចូលបក្សណាទាំងអស់ ។

សុជាៈ ថ្មី?

នៅៈ ព្រោះវាឆ្អែត ។

សុជាៈ ឆ្អែតចិត្ត?

នៅៈ វាគ្មានបានលទ្ធផលអីទេ គឺយើងខាតៗ ពេលវេលាប៉ុន្មានឆ្នាំ គិតមើលណា៎ ។ សឹងថាជីវិតខ្លួនឯងមួយហ្នឹងមិនរស់ទៀត ។

សុជាៈ ជំនាន់ហ្នឹងមានកន្លែងណាល្អ មីងគិតថាមើលទៅល្អ?

នៅៈ អាហ្នឹងល្អមិនល្អវាអាស្រ័យលើអ្នកអនុវត្ត ។

សុជាៈ អ្នកអនុវត្តន៍?

នោៈ ខ្ញុំៗគិតថា ដែលចំណូលចិត្តផុនខ្ញុំដែលខ្ញុំមករស់នៅក្នុងសង្គមហ្នឹង ហើយខ្ញុំមិនចូលបក្សសម្ព័ន្ធណាទេ ខ្ញុំមិនចូលទេមានគេមកអូសទាញឲ្យខ្ញុំចូលព្រោះ យើងនិយាយថាយើងពូកែនិយាយអីអញ្ចឹង ឧទាហរណ៍ ពូកែឃោសនាពូកែភូតយើងថាអញ្ចឹងចុះ គេមកអូសទាញយើងចូលជាសមាជិក ខ្ញុំថាខ្ញុំមិនចូលទេហើយខ្ញុំក៏មិនស្អប់ដែរ តែខ្ញុំឈប់ហើយខ្ញុំរៀនហើយ ខ្ញុំបាក់ស្បាតខ្ញុំនិយាយប្រាប់គេត្រង់ រហូតមានអ្នកខ្លះយកក្រដាស់មកឲ្យខ្ញុំផ្ដិតហ្នឹងខ្ញុំថាទេខ្ញុំមិនស្អប់ទេ តែខ្ញុំមិនផ្ដិតទេ តែខ្ញុំបំរើការងាររធម្មតាជាមួយសង្គម តែដំបូងដែលខ្ញុំចូលៗចូលខាងសិទ្ធិមនុស្ស តែខ្ញុំមិនទាន់ដឹងលក្ខណសិទ្ធិមនុស្សហ្នឹងម៉េចៗទេ គ្រាន់តែខ្ញុំដឹងថាសិទ្ធិមនុស្សវាជាមនុស្សអធ្យាក្រិត មិនចូលបក្សសម្ព័ន្ធណាវាជាមនុស្សការពារសិទ្ធិនិងផលប្រយោជន៍ឲ្យប្រជាជនអញ្ចឹងខ្ញុំចូល តែក្រៅពីហ្នឹងខ្ញុំអត់ចូល ។

សុជាៈ ចុះមីងរាល់ថ្ងៃមីងដែលនិយាយរឿងរ៉ាវ ដូចមីងនិយាយប្រាប់ខ្ញុំប្រាប់កូនចៅដែរទេ?

នោៈ និយាយដែរតែខ្ញុំមិននិយាយអស់ទេ និយាយតែចំណុចដែលខ្ញុំលំបាកខ្ញុំវេទនា ឧទាហរណ៍ថាពេលដែលខ្ញុំទៅនៅព្រៃយៀកណាមចូលខ្ញុំអត់បាយ ខ្ញុំពិបាកនៅលើភ្នំនៅក្នុងព្រៃម៉េចៗខ្ញុំប្រាប់ ។

សុជាៈ ហេតុអីបានមីងប្រាប់?

នោៈ ខ្ញុំចង់រំលឹកពីការឈឺចាប់លទ្ធផលនៃការទទួលពីបដិវត្តន៍ផុនខ្ញុំហ្នឹងគឺបានលទ្ធផលអាហ្នឹងលទ្ធផលដែលខ្ញុំទទួលបាន ។

សុជាៈ គេថារឿងហ្នឹងគួតែបំភ្លេចចោល ឬក៏និយាយទៅថ្ងៃក្រោយ?

នោៈ ខ្ញុំយល់ឃើញថាត្រូវតែមានឯកសារដើម្បីទុកឲ្យជំនាន់ក្រោយ ដើម្បីកសាងសង្គមមួយឲ្យល្អ បើសិនជាយើងបំបិទចោលដោយគ្មានឯកសារ ដោយគ្មានការបំភ្លឺពីអ្នកធ្លាប់ឆ្លងកាត់ ឧទាហរណ៍ដូចខ្ញុំអីអញ្ចឹងវាសាបសូន្យហើយ ។

សុជាៈ មានពីណាគេដែលមកសួរនាំមីង?

នោៈ មិនដែលទេ ។

សុជាៈ អញ្ចឹង?

នោៈ អញ្ចឹងដឹងថាយើងធ្លាប់រស់នៅជំនាន់ខ្មែរក្រហមធ្លាប់ធ្វើការ គេមិនបានមកសួរលំអិតថាម៉េចៗទេតែគេដឹងៗ ។

សុជាៈ ចុះមីងពេលខ្ញុំមកសួរខ្ញុំអញ្ចឹងមីងមានអារម្មណ៍ថាម៉េចដែរ?

នៅៈ ខ្ញុំមិនមានអារម្មណ៍ម៉េចទេ ខ្ញុំមើលផ្លូវដែរព្រោះមីងមកពីស្វាយរៀងវិញពួកកូនប្រាប់ថាមកជួបខ្ញុំថ្ងៃ២០អីអញ្ចឹងកាលហ្នឹង ថ្ងៃប៉ុន្មានទេថាមកជួប ។ ខ្ញុំថាអ្ហើបើថ្ងៃ២០ មិនមកអត់ជួបទៀតហើយកូនអើយ មីងចង់ជួបដែរដើម្បីទំលាយឲ្យទៅដើម្បីឲ្យគេទុកជាឯកសារសំរាប់ជំនាន់ក្រោយ បើសិនជាមីងទុកនៅនឹងខ្លួនឯងហ្នឹង មីងចង់សរសេរតែសរសេរវាបានតែតិចៗវាអត់ទៅជាផ្លូវការគ្រាន់តែដឹងថា យើងចង់ចាំថាថ្ងៃនេះខែនេះអីអញ្ចឹងតាមពិត ឧទាហរណ៍ដូចឥឡូវហ្នឹងយើងមានការបើកការកាត់ទោសខ្មែរក្រហម តាមខ្ញុំស្តាប់ព័ត៌មានគឺគេត្រូវរ៉ូវគ្នាអស់ហើយណាស់ កាលមុនយើងចោទពីរឿងខុះលុយតែឥឡូវមិនមានខុះទេ តាមចិត្តមីងៗចង់ឲ្យគេកាត់ទៅណា៎ទោះបីមនុស្សហ្នឹងជិតស្លាប់ក៏ដោយឧទាហរណ៍អញ្ចឹងណា៎ កាត់ទៅហើយតាមគោលការណ៍យើងគេយកតែក្បាលមាស៊ីនធំៗលើទេណា៎ កាត់ទៅ ។

សុជាៈ ចុះមីងគេគាត់របៀបហ្នឹងគេយកតែមេខ្លោងធំៗ ទៅអញ្ចឹងមីងយល់ថាយ៉ាងម៉េចដែរដូចថាវាយុត្តិធម៌ដែរទេ?

នៅៈ អាហ្នឹងវាព្រោះការគ្រប់គ្រងហ្នឹងពេល ឧទាហរណ៍ថាពេលគ្រួសារមួយមានបញ្ហា អ្នកគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ។

សុជាៈ ចុះដូចថាអ្នកប្រព្រឹត្ត ជនដៃដល់នៅរស់ នៅធម្មតាអញ្ចឹង ហើយគេកាត់តែលើអញ្ចឹងវា?

នៅៈ ជនដៃដល់ក៏វាបានបញ្ជាពីហ្នឹងមកដែរ ហើយខ្ញុំមិនជឿថាអ្នកហ្នឹងមិនដឹងខ្ញុំមិនជឿទេ ។

សុជាៈ អញ្ចឹង?

នៅៈ ខ្ញុំអត់ជឿទេ ។

សុជាៈ អញ្ចឹងមីងគិតថាការកាត់ទោសហ្នឹងវាមានប្រយោជន៍?

នៅៈ ប្រយោជន៍ច្រើនៗថា សំខាន់បំផុតគឺសំខាន់សំរាប់មេរៀនអ្នកដឹកនាំក្រោយ ជំនាន់ក្រោយកុំឲ្យធ្វើអំពើអញ្ចឹងទៀត គួតែពេលណាដែលយើងធ្វើអំពើអញ្ចឹងទៀតគេនឹងកាត់ទោស ។ គេចារក្នុងប្រវត្តិសាស្រ្តតកូនតចៅគឺនៅតែមាន ឈ្មោះយើងអាក្រក់រហូត ជឿអញ្ចឹងខ្ញុំជឿអញ្ចឹង ។

សុជាៈ ចុះសំរាប់ការអភិវឌ្ឍន៍សំរាប់ដូចថាពេលដែលមានតុលាការហើយកាត់ទោសហើយ អញ្ចឹង វាអាចមានការអភិវឌ្ឍន៍ប្រទេសជាតិយើងប្រសើជាងឥឡូវទេ ឬក៏យ៉ាងម៉េចតាមមីងគិត ទៅ?

នៅៈ តាមខ្ញុំគិតវាអាចប្រសើព្រោះពេលណាដែលយើងកាត់ៗទោស ហើយហ្នឹងមនុស្សយើង ហ្នឹងវាលែងមានគំនិតគុំគ្នា ។

សុជាៈ ហើយមីងយល់យ៉ាងម៉េចដែរពាក្យថាយុត្តិធម៌មីង?

នៅៈ យុត្តិធម៌ហ្នឹងគឺត្រឹមត្រូវ វាដូចថា រកសច្ចៈ រកការពិត យើងចង់និយាយថាការពិតហ្នឹង យុត្តិធ៌មហ្នឹង?

សុជាៈ មីងដែលលឺពីរឿងតុលាការដែលគេបង្កើតកាត់ទោសខ្មែរក្រហមកាលពីឆ្នាំ ៨០, ៧៩, ៨០ មីងដែលឮទេ គេហៅតុលាការប្រជាជន កាលហ្នឹងគេកាត់ទោស អៀង សារី ហើយ និង ប៉ុល ពត ពីរឿងហ្នឹង តែគេធ្វើនៅភ្នំពេញទេតែដូចថា អ្នកដែលគេចោទ ហ្នឹងអត់ បានចូលខ្លួនមកតុលាការ មីងដែលឮទេ?

នៅៈ មីងកាលហ្នឹងមីងមិនសូវបានតាមដាននយោបាយ ឬក៏ស្តាប់វិទ្យុអីប៉ុន្មានទេណា៎ ទើបតែ មោះឥឡូវមីងតាមដានជាប់ ទោះបីមីងមិនបានទៅផ្ទាល់មាត់ក៏មីងស្តាប់មីងដឹង អំពីរបៀប គេបង្កើតសាលាក្តីហ្នឹងយ៉ាងម៉េចៗ ហើយវាមានផលប្រយោជន៍អីអាហ្នឹងរឿងគេទេតែ រឿងមីងៗ ក៏យល់ឃើញថាវាត្រឹមត្រូវហើយយុត្តិធម៌ហើយ ទោះបីថាមនុស្សហ្នឹងជិត ស្លាប់ យើងដឹងហើយណាមេធំៗវាចាស់ជរាអស់ហើយ ក៏យើងត្រូវតែធ្វើឲ្យបានដែរ ។ អញ្ចឹងយើងគិតថាមកដល់ឥឡូវនេះយើងឃើញថាមេធំ ប៉ុល ពត ស្លាប់បាត់ហើយ អញ្ចឹងវានៅសល់រាយរងច្រើន ឧទាហរណ៍ដូចជា ខៀវ សំផន ដូចជា អៀង សារី ដូចជា នួន ជា ពិសេស ឌុចដែលខ្ញុំធ្លាប់ស្គាល់ ដែលធ្លាប់សួរចម្លើយខ្ញុំហ្នឹង ។ អញ្ចឹង យើងគិតថាពេលហ្នឹងវាឃោរឃៅណាស់ណា៎ ឃោរឃៅត្រង់ថាវាសួរមកយើងបញ្រ្ជាស វិញថាហេតុអីបានមិត្តនារីឯងនៅបានយូរម្ល៉េះ? ខ្ញុំថាខ្ញុំដឹងយូរ មិនយូរអ្នកខាងហ្នឹងទេ ដែលៗត្រូវដឹងខ្ញុំឆ្លើយហើយសើច ហើយវាថាមិនដែលពីណាឆ្លើយសើចដាក់វាទេ ខ្ញុំនៅ ចាំពាក្យហ្នឹងខ្ញុំនៅចាំអត់ភ្លេចទេ វាថាមិនដែលចេះសួរចម្លើយសើចដាក់វាទេ ឲ្យតែមកគឺ

គេថាបាក់លោងទន់ជង្គង់ បាក់ឆ្អើយមិនរួចចង់សន្ធប់ ចង់ផាប់មុនគេវៃប្រហារទៀត ណោះ ។

សុជាៈ ហើយមីងគេថាការដាក់ទោសទៅលើពួកហ្នឹង គួតែដាក់កំរិតណាឲ្យសមទៅនឹងអ្វីដែលពួកហ្នឹង បានធ្វើប្រជាជនរងទុក្ខវេទនាកាលពីជំនាន់ខ្មែរក្រហម?

នៅៈ យើងមិនដឹងថាដាក់កំរិតណាទេអាហ្នឹងស្រេចនឹងច្បាប់គេធ្វើទៅណា៎ ខ្ញុំចង់និយាយអញ្ចឹងចុះ ព្រោះសំណាងដែលយើងទាមទានោះវារកកាត់ថ្ងៃមិនបាន ។ ឧទាហរណ៍ក្មួយឯងគិតមើល យើងកុំនិយាយថាយើងមើតែមួយរង្វង់គ្រួសារមីងចុះមីង នៅតែម្នាក់ឯងគត់ទេហើយ ពីណាមិនឈឺចាប់ណា៎ ហើយរហូតខ្លួនពិការហើយយើងឆ្លាតត្រូវរស់ដើម្បីសង្គម ដើម្បី ប្រវត្តិសាស្ត្រ ដើម្បីប្រទេសជាតិយើងត្រូវរស់ដោយយើងមិនគិតថាគុំគួនអានេះ អានោះ ទេប៉ុន្តែបើគេកាត់អញ្ចឹងវាពិសេសហើយ ដើម្បីឆ្លើយតបទៅអ្នកដែលបាត់ខ្លួនទៅ ។

សុជាៈ ចុះបើសិនជាមីងដឹងឧទាហរណ៍ថាអ្នកដែលសម្លាប់ប្តីមីង ឬក៏បងប្អូនមីងអីគេមកនៅជិតខាង មីងអី មីងមានចង់សងសឹកទេ?

នៅៈ ទេ មីងមិនមានគំនិតគុំគួនទេ ។

សុជាៈ អញ្ចឹង?

នៅៈ ចា៎! មីងថាឧទាហរណ៍ថាយើងប្រើពាក្យថាអហោសកម្ម បើថាបានកាត់ទោសហើយ យើងចាប់ដៃគ្នាកសាងប្រទេសទៅធ្វើម៉េចបានជាហួសទៅហើយ បានគេកាត់ទោសហើយ អញ្ចឹងយើងប្រឹងកសាងប្រទេសយើងធ្វើម៉េចឲ្យបានជឿនលឿនទៅ ។

សុជាៈ ចុះបើសិនជាគេហ្នឹងមានកូនចៅ ជនដៃដល់ដែលធ្វើបាបគ្រួសារមីងឧទាហរណ៍ទេណា៎ គេមានកូនចៅមកលេងជាមួយកូនចៅមីងអីអញ្ចឹង មីងបញ្ចេះមិនឲ្យកូនចៅមីងទៅលេងជា មួយកូនចៅគេ ឬក៏ម៉េចដែរ?

នៅៈ មីងមិនមានគំនិតអញ្ចឹងទេកន្លងមកមីងគិតថាគេក៏ចង់រស់ដូចយើង គេជាមនុស្សដូចយើង ។

សុជាៈ ចុះឧទាហរណ៍មួយទៀតបើសិនជាតុលាការមិនបង្កើតឡើងទេ មីងសង្ឃឹមថាមីងចង់ឲ្យមាន តុលាការហ្នឹងកើតឡើង ព្រោះទុកជាមេរៀនមួយទៅថ្ងៃក្រោយទៅអីអញ្ចឹង ថាពួកហ្នឹង បានធ្វើឲ្យប្រទេសជាតិហ្នឹងវាមានបញ្ហាច្រើនមកអញ្ចឹង ចុះបើថ្ងៃក្រោយទៅអត់មានតុលា ការហ្នឹងវិញ តើមីងយល់យ៉ាងម៉េច?

នៅៈ ចុះថាបើសិនជាថ្ងៃក្រោយដំណាក់កាលនេះដែលយើងថាកើតបានហើយ តែវាបែជាកើតមិនបានវិញ មិនបាបធ្វើវិញប្រទេសខ្មែរយើងមិនលឿនទេ ការគ្រប់គ្រងហ្នឹងអាចឃោរឃៅឈានទៅហួសុីសដូចជំនាន់ប៉ុល ពត អញ្ចឹង វាអត់មានច្បាប់ណាគំរាមកៀបអ្នកដឹកនាំហ្នឹងទេ ។

រ៉ាន់ៈ មុនហ្នឹងលឺមីងនិយាយថា ពេលខ្ញុំមកសួរដំបូងមីងថាអត់សូវចង់និយាយ ហើយខ្ញុំចង់ដឹងហេតុផលសំខាន់ដែលមីងអត់ចង់និយាយ? ដំបូងមីងនិយាយថាការពិតអត់ភ្លេចទេតែអត់ចង់និយាយ គឺខ្ញុំចាប់អារម្មណ៍ អាពាក្យកន្លែងហ្នឹង ។

នៅៈ មិនចង់និយាយយើងចង់និយាយថានិយាយទៅក៏វាអត់បានការអី យើងចង់និយាយអញ្ចឹងប៉ុន្តែបើសិជានិយាយទៅគេកត់ត្រាជាឯកសារដើម្បីទុកសំរាប់ជាប្រវត្តិ អាហ្នឹងមីងមិនបដិសេធន៍ទេណា៎មីងនិយាយ ។

រ៉ាន់ៈ បាទ! តែធម្មតាមីងខ្សឹបរ៉ាប់និយាយប្រាប់កូនដែរអត់?

នៅៈ មីងនិយាយតែអ្វីដែលលំបាក ពិសេសមីងនិយាយពេលក្រោយព្រឹត្តិការណ៍ ៧៩ ពិសេសពេលមីងនៅក្នុងគុកព្រៃសសលំបាកពលកម្មម៉េចម៉ាហ្នឹង ហើយពេលដែលវៀតណាមចូលគេកៀរយើងទៅនៅក្នុងព្រៃអញ្ចឹង មីងនិយាយពីលទ្ធផលនៃការធ្វើបដិវត្តន៍យើងបានត្រឹមប៉ុណ្ណឹង ហើយបូកបំណុលដែលយើងធ្វើបដិវត្តន៍ហ្នឹងដើម្បីរំដោះប្រទេសជាតិ ដើម្បីកសាងប្រទេសជាតិ ដើម្បីឲ្យមានភាពស្មើគ្នានិងការបញ្ចេញមតិយើងដឹងហើយកាលហ្នឹង គេដាក់ឈ្មោះប្រទេសជាកម្ពុជាប្រជាធិបតេយ្យ អញ្ចឹងយើងឮតែពាក្យប្រជាធិបតេយ្យហ្នឹងវាណាស់ណាហើយ គេធ្វើម៉េចខ្លះមិនអញ្ចឹងអ្ហែស?

សុជាៈ បាទ!

នៅៈ ដល់ពេលយើងធ្វើបដិវត្តន៍យើងចង់បានឲ្យវាល្អតែដល់ពេលលទ្ធផលចុងក្រោយ ម៉ាជាប់គុកម៉ាអត់បាយនៅព្រៃ បិសនឹងងាប់ខ្លួនហើយងាកមកក្រោយវិញគ្រួសារនៅក្រោយត្រូវគេបញ្ជូនទីណាត់ទីណែងបែក ដូចថាមនោសញ្ចេតនាអីអញ្ចឹង ។ គិតទៅមីង ខ្ញុំចង់និយាយថាតាំងពីមីងបែកពីផ្ទះឆ្នាំ៧៤មីងមិនដែលស្គាល់ផ្ទះយ៉ាំម៉េចទេ សូម្បីតែយើងបញ្ជូន គេបញ្ជូនមីងទៅភ្នំពេញមិនឆ្លងកាត់ព្រៃវែងហ្នឹង មកដេកនៅវត្តនៅព្រៃវែងហ្នឹងម៉ាយប់ មីងសុំគេទៅលេងផ្ទះមួយយប់ត្រឹមព្រែកប្ញស្សីហ្នឹង ដែលយើងជិះមិនបានម៉ាម៉ោងផងហ្នឹងគេអត់

ឲ្យទៅទេ ។ គេថាចុះបើឲ្យយើងទៅអ្នកផ្សេងរាប់រយ ត្រូវតែទៅដែរ? អញ្ចឹងគេបិទទាំងអស់ ។

រ៉ាន់: មីងរាល់ថ្ងៃនេះ អ្នកជិតខាងអីមីងអ្នកស្រុក មានសួរនិយាយពីរឿងខ្មែរក្រហម រំលឹកពីរឿងខ្មែរក្រហមទេរាល់ថ្ងៃ?

នៅ: ភាគច្រើនគេមិនរំលឹកទេគេថា ជំនាន់ខ្មែរក្រហមអ្នកដែលមានអាយុឆ្លងកាត់ហ្នឹងអ្នកណាមួយក៏ជាមិនរួចអញ្ចឹងអ៊ីដែលគេដឹងៗរួចទៅហើយ ។

រ៉ាន់: អញ្ចឹងក្នុងន័យមួយថាគេដឹងរឿងហ្នឹងហើយគេមិនចង់និយាយគេចេញមកទេ ទៅតាមហេតុផលអីបើតាមមីងដឹង ភាគច្រើនហេតុផលដោយសារគេ ដោយសាគាត់ពិបាកពេកគាត់មិនចង់រំលឹក ឬក៏ដោយសារឿងហ្នឹងវាយូរហើយតាមមីងគិត?

នៅ: តាមខ្ញុំបើខ្ញុំវិញខ្ញុំបើជួបគ្នាឯង ខុទាហរណ៍ថាអ្នកដែលធ្លាប់នៅអន្តភាពជាមួយគ្នាអញ្ចឹងយើងច្រើនរំលឹកថាយើងអញ្ចេះៗមិនគួរធ្វើអញ្ចឹងសោះណា៎ ដោយយើងមានអាបញ្ញាគិតហ្នឹងវាមិនដល់ដូចគេ អញ្ចឹងយើងទៅតាមគេអូសទាញ អញ្ចឹងឥឡូវហ្នឹងធ្វើម៉េច កុំឲ្យគេអូសទាញដូចកាលហ្នឹងទៀត មុននឹងគេអូសទាញបានយើងពិចារណាសិនថាតើយើងធ្វើហ្នឹងវាត្រឹមត្រូវតាមរបបប្រជាធិបតេយ្យដែររឺក៏អត់ យើងជជែកប្រៀបធៀបអញ្ចឹង ។

រ៉ាន់: តែខ្ញុំចង់សួរមីងថារាល់ថ្ងៃនេះដូចយើងកាល ពីមុនមកបែកភូមៗយើងនាំគ្នានិយាយអាពេលភូមៗយើងជួបមុខគ្នាយើងខស្បរាហ៍និយាយពីរឿងខ្មែរក្រហម តែកន្លងមករយៈពេល៣០ឆ្នាំនេះ ជិត៣០ឆ្នាំនេះពេលដែលយើងជួងឬក៏យើងជួបគ្នាហ្នឹង តើយើងមានរំលឹកពីរឿងហ្នឹងទៀតដែរអត់? បើសិជាអត់រំលឹកអាហ្នឹងខ្ញុំសួរថាដោយសារ រយៈពេលយូពេក ឬក៏ដោយសារមីងឈឺចាប់ពេកមិនចង់រំលឹកវា?

នៅ: ចង់និយាយថាដូចមីងនិយាយម៉ិញអញ្ចឹង មីងរំលឹកដែរប៉ុន្តែលុះត្រាតែអ្នកហ្នឹងធ្លាប់នៅជាមួយយើងស្គាល់ចិត្តស្គាល់ថ្លើមគ្នាពីហ្នឹងមកដោយចាស់សក់ស្កូវរាងខ្លួន ហើយកាលហ្នឹងយើងមិនសុទ្ធតែយុវវ័យណា៎ អាយុ២០ជាង ២១, ២២កំពុងពេញកំលាំងគេប្រើហើយអញ្ចឹងឥឡូវហ្នឹងរាងៗខ្លួនមានចៅហើយ អញ្ចឹងពេលដែលអ្នកហ្នឹងធ្លាប់នៅជាមួយគ្នាអញ្ចឹងបានយើងរំលឹកប្រវត្តិដែលយើងនៅខ្សែរត្រៀមវាពិបាកកបាល់ហោះវាទំលាក់ម៉េច យើងធ្វើម៉េច យើងអត់បាយម៉េចយើងធ្វើម៉េចអញ្ចឹង យើងហូបម៉េចអញ្ចឹង យើងរំលឹក

ដើម្បីយើងដាស់តឿនខួរចិត្តយើងឲ្យនឹកឃើញរឿងចាស់ៗ តែបើជាមួយអ្នកផ្សេង យើងមិនស្គាល់យើងមិននិយាយទេៗ

សុជា: អញ្ចឹងអគុណមីងច្រើនមីងណា៎ៗ

នៅ: ចា៎!

ចប់